**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# អាជ្ញាធរជាតិអប្សរា

ស្រាវជ្រាវដោយ៖

និស្សិតឈ្មោះ: **អ៊ី ពេញបូរ**

**ទួន ចាន់ម៉ាលីណា**

សាស្ត្រាចារ្យណែនាំ

**បណ្ឌិត អ៊ុន សកក្កដា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៦

ឆ្នាំចូលសិក្សា ២០១២

ឆ្នាំសរសេរសារណា ២០១៦

# អារម្ភកថា

នៅក្នុងការសិក្សាថ្នាក់សាកលវិទ្យាល័យមិនថានៅក្នុងប្រទេសអភិវឌ្ឍ ឬប្រទេសដែលកំពុងអភិវឌ្ឍឡើយ នៅមុនពេលទទួលបានសញ្ញាបត្រ ដើម្បីបញ្ចប់ការសិក្សាត្រូវធ្វើសារណា និក្ខេបបទ ឬការចុះធ្វើកម្មសិក្សា ដើម្បីបញ្ជាក់ពីសមត្ថភាពផ្ទាល់របស់ខ្លួនដែលបានឆ្លងកាត់ការសិក្សាបណ្តុះបណ្តាលកន្លងមក និងដើម្បីទុកជាឯកសារដល់អ្នកសិក្សា និងអ្នកស្រាវជ្រាវជំនាន់ក្រោយៗទៀត។

ដោយអនុវត្តតាមគោលការណ៍របស់ក្រសួងអប់រំ យុវជន និងកីឡា និងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច យើងខ្ញុំបានទទួលការអនុញ្ញាតពីសាកលវិទ្យាល័យក្នុងការសរសេរសារណាមួយនៅក្រោមប្រធានបទ **"តួនាទី និងភារកិច្ចរបស់អាជ្ញាធរជាតិអប្សរា"** ដែលកើតចេញពីការខិតខំប្រឹងប្រែង និងឆន្ទៈនៃការស្រលាញ់ទៅលើប្រធានបទនេះ។ ដោយឆ្លងកាត់តាមការអប់រំពីសំណាក់សាស្ត្រាចារ្យជាច្រើន គឺពិតជាស្រលាញ់នូវការសិក្សា និងមានស្មារតីទទួលយកពុទ្ធិល្អៗដើម្បីយកមកអភិវឌ្ឍខ្លួន។ ជាងនេះទៅទៀត គឺយើងខ្ញុំពិតជាចង់ចែករំលែកនូវចំណេះដឹងតាមរយៈការស្រាវជ្រាវ ក៏ដូចជាមានបំណងចង់រក្សាទុកនូវស្នាដៃដល់អ្នកសិក្សាជំនាន់ក្រោយដែលចង់ស្វែងយល់ពីប្រធានបទខាងលើនេះ។ ក្នុងន័យដើម្បីបំពេញសារណាមួយឲ្យកាន់តែមានប្រសិទ្ធភាព និងមានលក្ខខណ្ឌពេញលេញប្រកបដោយខ្លឹមសារ យើងត្រូវខិតខំប្រឹងប្រែងព្យាយាម និងយកចិត្តទុកដាក់នៅក្នុងការស្រាវជ្រាវក្នុងបណ្តាអត្ថបទជាច្រើន ក្នុងនោះរួមទាំងទទួលបានការពន្យល់ណែនាំផ្សេងៗយ៉ាងក្បោះក្បាយពីសំណាក់លោកសាស្ត្រាចារ្យផ្សេងៗ ជាពិសេសគឺលោកសាស្ត្រាចារ្យបណ្ឌិត **អ៊ុន សកក្កដា** ក្នុងការចំណាយពេលវេលាដ៏មានតម្លៃ ដើម្បីចែករំលែកចំណេះដឹង ក៏ដូចជាបទពិសោធន៍ដល់យើងខ្ញុំ។

យើងខ្ញុំជឿជាក់ថា ស្នាដៃខាងលើនេះប្រាកដជាមានកំហុសឆ្គងដោយប្រការណាមួយជាក់ជាពុំខានទាំងអក្ខរាវិរុទ្ធ ទាំងអត្ថន័យក្នុងវិស័យច្បាប់ ដោយហេតុតែវាគឺជាស្នាដៃដំបូងរបស់យើងខ្ញុំដែលទទួលបានក្រោយពីការសិក្សានៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ ជាថ្មីម្តងទៀត ក្នុងនាមយើងខ្ញុំជាអ្នករៀបរៀងផ្ទាល់នៅក្នុងសារណានេះ យើងខ្ញុំសូមទទួលយកនូវការរិះគន់ កែលម្អក្នុងន័យអភិវឌ្ឍនូវបណ្តាការខ្វះខាត និងកំហុសខុសឆ្គងទាំងអស់ ដើម្បីឲ្យស្នាដៃមួយនេះអាចក្លាយជាចំណែកមួយនៃជំនួយស្មារតីដល់និស្សិតជំនាន់ក្រោយៗទៀត។

## សេចក្តីថ្លែងអំណរគុណ

ជាបឋម នាងខ្ញុំឈ្មោះ **អ៊ី ពេញបូរ** និងនាងខ្ញុំឈ្មោះ **ទួន ចាន់ម៉ាលីណា** ជានិស្សិតថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ ជំនាន់ទី១៦ ផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា២០១៣-២០១៦។ កូនសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ៖

**លោកឪពុក អ៊ី ស៊ីម លោកឪពុក ទួន ចាសនា**

**អ្នកម្តាយ ហេង ផាត អ្នកម្តាយ អ៊ុយ ចាន់ម៉ាលី**

កូនសូមសម្តែងនូវមហាកតញ្ញូតាធម៌ជាអនេកប្បការចំពោះលោកអ្នកមានគុណទាំងពីរដែលបានផ្តល់កំណើតឱ្យយើងខ្ញុំ និងខិតខំបីបាច់ថែរក្សាបានអប់រំទូន្មានប្រៀនប្រដៅឱ្យពួកយើងខ្ញុំបានដើរផ្លូវល្អត្រឹមត្រូវតាមគន្លងនៃព្រះពុទ្ធសាសនា។ ព្រះគុណដ៏មហាបវរនេះគឺ ធ្វើឱ្យកូនចងចាំមិនអាចបំភ្លេចបានឡើយ។ កូនសូមលោកហត្ថគោរពប្រណិបតន៍ផ្ញើស្នាដៃនេះជូនចំពោះបុព្វាចារ្យទាំងពីរជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់។

ថ្វីត្បិតតែការចងក្រងឯកសារនេះជាស្នាដៃតូចមួយក៏ពិតមែន តែវាជាសក្ខីភាពមួយបញ្ជាក់ថា កូនមិនបានបណ្តោយឱ្យពេលវេលាកន្លងទៅដោយឥតប្រយោជន៍នោះឡើយ។ កូនសូមបួងសួងដល់ទេវតាវត្ថុស័ក្តិសិទ្ធិទាំងឡាយតាមថែរក្សា និងការពារលោកអ្នកមានគុណទាំងពីរគ្រប់ទីកន្លែង កូនសូមជូនពរឱ្យលោកអ្នកមានគុណទាំងពីរមានសុខភាពល្អ និងមានជន្មាយុយឺនយូរ។

ឯកឧត្តម **លុយ ចណ្ណា** សាកលវិទ្យាធិការ ព្រមទាំងសាកលវិទ្យាធិការរង ព្រឹទ្ធបុរសអស់លោក លោកស្រីសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំជួយបង្ហាត់បង្រៀនដល់យើងខ្ញុំអស់ពីកម្លាំងកាយចិត្ត ចាប់ពីឆ្នាំសិក្សាថ្នាក់មូលដ្ឋានរហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រនេះប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ។

លោកសាស្ត្រាចារ្យបណ្ឌិត **អ៊ុន សកក្កដា** ដែលបានដឹកនាំបង្ហាត់បង្ហាញពីគំនិតវិធីសាស្ត្រល្អៗទាក់ទងនិងប្រធានបទ រួមទាំងចំណាយពេលវេលាដ៏មានតម្លៃរបស់លោកតាំងពីដើមរហូតដល់បញ្ចប់ការស្រាវជ្រាវមួយនេះ។ វាពិតជាមិនមានអត្ថិភាពឡើយ បើគ្មានការជួយជ្រោមជ្រែងពីសំណាក់លោកសាស្ត្រាចារ្យនោះទេ។

ជាទីបញ្ចប់

យើងខ្ញុំសូមគោរពជូនពរឱ្យលោកអ្នកមានគុណទាំងពីរដែលបានរៀបរាប់ខាងលើនេះព្រមទាំងឯកឧត្តម សាកលវិទ្យាធិការ និងសាស្ត្រាចារ្យទាំងអស់ ជាពិសេសគឺលោកសាស្ត្រាចារ្យបណ្ឌិត **អ៊ុន សគន្ធជា** សូមឱ្យមានសុខភាពល្អបរិបូរណ៍ និងជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

# មាតិកា


ទំព័រ

សេចក្តីផ្តើម........................................................................................................ ១

១ លំនាំបញ្ហា........................................................................................................ ១

២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........................................................................ ១

៣ គោលបំណងនៃការស្រាវជ្រាវ............................................................................. ២

៤ ទំហំ និង ដែនកំណត់នៃការស្រាវជ្រាវ................................................................ ២

៥ សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ .................................................................... ២

៦ វិធីសាស្រ្តស្រាវជ្រាវ ............................................................................................... ៣

៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ .................................................................................. ៣

ជំពូកទី១៖ ទិដ្ឋភាពទូទៅ ............................................................................................. ៤

១.១ គោលបំណងក្នុងការការពារប្រាសាទបុរាណ...................................................... ៥

១.១.១ ការការពារ និង អភិរក្សប្រាសាទបុរាណ ................................................. ៦

១.១.២ ការបណ្តុះបណ្តាលអំពីប្រាសាទបុរាណ ................................................... ៧

១.២ រចនាសម្ព័ន្ធ និងធនធានហិរញ្ញវត្ថុរបស់អាជ្ញាធរ............................................. ៩

១.២.១ រចនាសម្ព័ន្ធ........................................................................................ ៩

❖ រចនាសម្ព័ន្ធដឹកនាំ ................................................................................ ៩

➢ ក្រុមប្រឹក្សាភិបាល................................................................................ ៩

➢ ប្រធានអគ្គនាយក................................................................................. ១១

➢ អគ្គនាយករង....................................................................................... ១៣

❖ រចនាសម្ព័ន្ធរដ្ឋបាល ............................................................................. ១៣

➢ រដ្ឋបាលកណ្តាល ................................................................................. ១៣

➢ នាយកដ្ឋានរដ្ឋបាលបុគ្គលិកហិរញ្ញកិច្ចនិងទំនាក់ទំនងសាធារណៈ ១៣
➢ នាយកដ្ឋានរមណីយដ្ឋាន និងបុរាណវិទ្យា......................................១៥
➢ នាយកដ្ឋានវប្បធម៌ និងស្រាវជ្រាវ.................................................១៨
➢ នាយកដ្ឋាននគរូបនីយកម្ម និងអភិវឌ្ឍន៍តំបន់សៀមរាប អង្គរ......១៨
➢ នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គរ ............................................ ២០
➢ នាយកដ្ឋានប្រជាសាស្ត្រ និងការងារអភិវឌ្ឍ.................................. ២១
➢ នាយកដ្ឋានទឹក និងព្រៃឈើ...........................................................២២
➢ អង្គភាពអន្តរាគមន៍ចំរុះបង្ក្រាបបទល្មើសព្រៃឈើ គ្រប់គ្រងដីធ្លី និងទប់ស្កាត់អំពើអនាធិបតេយ្យ នៅតំបន់សៀមរាប អង្គរ ............ ២៣

១.២.២ ធនធាន និងហិរញ្ញវត្ថុរបស់អាជ្ញាធរអប្សរា .................................... ២៣

❖ ប្រភពចំណូលទូទៅ ......................................................................... ២៣

❖ ប្រភពចំណូលដោយឡែក.................................................................. ២៤

ជំពូកទី២៖ តួនាទី និងភារកិច្ច........................................................................................... ២៦

២.១ បេសកកម្ម និងសមិទ្ធផល ........................................................................ ២៦

២.១.១ បេសកកម្ម ........................................................................................ ២៦

២.១.២ សមិទ្ធផលរបស់អាជ្ញាធរជាតិអប្សរា.................................................... ៣២

➢ ការបង្កើតរមណីយដ្ឋានធម្មជាតិ................................................. ៣៣
➢ មណ្ឌលលំនៅស្ថានខ្មែរ ..........................................................៣៤
➢ កិច្ចការសំណង់..........................................................................៣៥
➢ ការរៀបចំ និងការគ្រប់គ្រងដែនដី ...............................................៣៦
➢ កិច្ចការពារថែរក្សាប្រាសាទបុរាណ ..............................................៣៨
➢ ការអភិរក្សព្រៃឈើ ....................................................................៣៨
➢ ហេដ្ឋារចនាសម្ព័ន្ធ និងកិច្ចការពារបរិស្ថាន ..........................................៣៩
➢ កសិកម្ម និង សហគមន៍ ..............................................................៤០
➢ ទេសចរណ៍ និង វប្បធម៌ ...............................................................៤១

- ការគ្រប់គ្រងទឹក ...... ៤១
- សណ្តាប់ធ្នាប់ និងសន្តិសុខសង្គម ...... ៤២
- កិច្ចសហប្រតិបត្តិការអន្តរជាតិ ...... ៤២
- ការបង្កើតសារមន្ទីរ ...... ៤៣

២.២ បញ្ហាប្រឈម និងដំណោះស្រាយ ...... ៤៤

២.២.១ បញ្ហាប្រឈម ...... ៤៥

២.២.២ ដំណោះស្រាយ ...... ៤៩

សន្និដ្ឋាន ...... ៥៣
អនុសាសន៍ ...... ៥៥
ឯកសារយោង
ឧបសម្ព័ន្ធ

# សេចក្តីផ្តើម

## ១ លំនាំបញ្ហា

វប្បធម៌ គឺជាសៀវភៅមួយក្បាលដែលផ្ទុកដោយកំណត់ត្រាប្រវត្តិសាស្ត្រ ទំនៀមទម្លាប់ សាសនា និងប្រពៃណីរបស់យើង។ វិស័យទេសចរណ៍ គឺជាអ្នកបោះពុម្ពដែលក្នុងនោះភ្ញៀវទេសចរគឺជាអ្នកអាន និងមគ្គុទ្ទេសក៍ទេសចរណ៍គឺជាអ្នកអត្ថាធិប្បាយ បកស្រាយសៀវភៅមួយក្បាលនេះ ឱ្យបានទូលំទូលាយដល់ភ្ញៀវទេសចរគ្រប់ជាតិសាសន៍។ ស្របគ្នានេះដែរការថែរក្សា ការការពារ ការអភិរក្ស នូវសម្បត្តិបេតិកភ័ណ្ឌទាំងអស់នោះ គឺជាកត្តាមួយដ៏ចាំបាច់បំផុត។ ដោយឃើញពីភាពចាំបាច់នៃតម្រូវការខាងលើនេះ ទើបរដ្ឋាភិបាលនៃរដ្ឋទាំងនោះត្រូវតែបង្កើតនូវស្ថាប័នផ្សេងៗ ដើម្បីធ្វើការការពារទៅលើសម្បត្តិវប្បធម៌បេតិកភ័ណ្ឌទាំងអស់នោះឱ្យបានគង់វង្សយូរអង្វែង ដើម្បីទុកជាកេរ្តិ៍តំណែលដល់កូនចៅជំនាន់ក្រោយ។ ចំពោះប្រទេសយើងក៏មិនខុសពីបណ្តាប្រទេស ដែលស្ថិតនៅលើសកលលោកប៉ុន្មានដែរ ពោលគឺប្រទេសកម្ពុជាយើងសំបូរទៅដោយសម្បត្តិបេតិកភណ្ឌជាច្រើនអនេក ស្ទើរតែពាសពេញប្រទេស ជាពិសេសគឺ ប្រាង្គប្រាសាទបុរាណដែលពិភពលោក បានធ្វើការកោតសរសើរពីភាពប៉ិនប្រសព្វ និងគំនិតច្នៃប្រឌិតរបស់បុព្វបុរសជំនាន់ដើមក្នុងការកសាងប្រាសាទបុរាណទាំងអស់នោះ ដែលយើងឃើញមានក្បូរក្បាច់រចនាយ៉ាងល្អវិចិត្រ ដែលបានបង្ហាញពីទំនៀមទម្លាប់ ប្រពៃណី សកម្មភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនខ្មែរនៅសម័យកាលនោះ ក៏ដូចជាយុត្តិសាស្ត្រនៅក្នុងការធ្វើសឹកសង្គ្រាមវាទទីទឹកដី ភាពអង់អាចពីរជ្ជកាលនៃស្តេចមួយជំនាន់ទៅស្តេចមួយជំនាន់ទៀតដែលបានបន្សល់ទុកមកដល់សព្វថ្ងៃ។

ខេត្តសៀមរាប គឺជាទឹកដីមួយនៃព្រះរាជាណាចក្រកម្ពុជា ដែលសម្បូរទៅដោយប្រាង្គប្រាសាទបុរាណយ៉ាងច្រើន ហើយមានអានុភាពទាក់ទាញនូវភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិ ជាច្រើនមកទស្សនានូវអច្ឆរិយភាពដ៏រុងរឿងរបស់ទីក្រុងសម័យបុរាណនៃស្តេចជំនាន់មុន ដែលបានធ្វើការកសាងឡើង ។ ឆ្លងកាត់ពីសម័យកាលមួយទៅមួយ ដោយសារតែប្រទេសយើងបានឆ្លងកាត់នូវសង្គ្រាមរ៉ាំរ៉ៃ ការបំផ្លិចបំផ្លាញ ការខូចខាត បាក់បែក

ទ្រុឌទ្រោម នៃប្រាសាទជាច្រើនទសវត្សកន្លងមក ទើបរាជរដ្ឋាភិបាលបានបង្កើតនូវស្ថាប័នផ្សេងៗនៅក្នុងគោលដៅដើម្បីថែរក្សា ការពារ អភិរក្សអភិវឌ្ឍតំបន់អង្គរនោះឱ្យមាន ភាពគង់វង្សស្ថិតស្ថេរ ដែលអាជ្ញាធរនោះមានឈ្មោះថា **អាជ្ញាធរជាតិអប្សរា** ។

**២ ចំណោទបញ្ហានៃការស្រាវជ្រាវ**

ប្រធានបទដែលយើងបានធ្វើការស្រាវជ្រាវនេះ ពិតជាមានសារៈប្រយោជន៍ជាច្រើនដល់សិស្ស និស្សិតបញ្ញវ័ន្ត និងសារណៈជនទាំងអស់ ដើម្បីធ្វើការស្វែងយល់អំពីអាជ្ញាធរមួយនេះថាបង្កើតមកក្នុង គោលបំណង ដើម្បីធ្វើអ្វី? ថែរក្សាទៅលើអ្វី? បានសម្រេចនូវសមិទ្ធផលអ្វីខ្លះ ? មានតួនាទី និង ភារៈកិច្ចអ្វីខ្លះ? មានដំណោះស្រាយយ៉ាងណាខ្លះ ចំពោះបញ្ហាប្រឈមដែលបានជួបប្រទះកន្លងមក បន្ទាប់ពីស្ថិតនៅក្រោមការដឹកនាំ និង ការគ្រប់គ្រងកន្លងមករបស់ខ្លួន? ដែលបញ្ហាទាំងនេះសុទ្ធតែជាកត្តាចម្បងៗដែលយើងទាំងអស់គ្នា គួរតែធ្វើការសិក្សាស្វែងយល់ជាមួយនិងការស្រាវជ្រាវមួយនេះ ដើម្បីទទួលបានចំនេះដឹងពីចំនុចនេះបន្ថែមទៀត ។

**៣ គោលបំណងនៃការស្រាវជ្រាវ**

គោលបំណងនៃការស្រាវជ្រាវដ៏សំខាន់បំផុតនេះ គឺដោយសារតែយើងនៅពុំទាន់បានយល់ច្បាស់ពីស្ថាប័នមួយនេះ និងដោយសារតែការសង្កេតឃើញថា កំណើនយ៉ាងឆាប់រហ័សរបស់ភ្ញៀវទេសចរណ៍យ៉ាងច្រើនកុះករពីសំណាក់ជុំវិញពិភពលោក ជារៀងរាល់ថ្ងៃ ដែលបានធ្វើការទស្សនាប្រាង្គប្រាសាទក្នុងទឹកដីនៃខេត្តសៀមរាប ទើបធ្វើឱ្យយើងចង់ដឹងថា វាស្ថិតនៅក្រោមការដឹកនាំគ្រប់គ្រងរបស់ស្ថាប័នណា? មានតួនាទីនិងភារកិច្ចអ្វីខ្លះ? ព្រមទាំងមានយុត្តិសាស្រ្តយ៉ាងណានៅក្នុងការរៀបចំ និងគ្រប់គ្រងដើម្បីឱ្យតំបន់នេះកាន់តែមានភាពលេចធ្លោបំផុតក្នុងពិភពលោកនេះ។ មួយវិញទៀត គោលបំណងនៃការស្រាវជ្រាវរបស់យើង គឺចងក្រងនូវឯកសារពាក់ព័ន្ធនិងស្ថាប័នមួយនេះ ទុកឱ្យអ្នកសិក្សាជំនាន់ក្រោយធ្វើការស្វែងយល់បន្ថែមទៅលើចំណេះដឹងរបស់ពួកគេ ។

**៤ ទំហំ និង ដែនកំណត់នៃការស្រាវជ្រាវ**

ដោយសារតែអាជ្ញាធរអប្សរា គឺជាអាជ្ញាធរមួយដែលគេបង្កើតឡើងក្រោមវិធានដោយឡែកមួយ ដើម្បីធ្វើការរៀបចំតំបន់អង្គរ

ដូចនេះវាពិតជាមានចក្ខុវិស័យ និងបេសកកម្មជាច្រើន នៅក្នុងការរៀបចំ និងកិច្ចសហប្រតិបត្តិការជាមួយបណ្តាក្រសួង និងស្ថាប័នដទៃទៀត។ ដោយសារមើលឃើញពីភាពទូលំទូលាយខ្លាំង ដូចនេះហើយទើបយើងបានធ្វើការកំណត់នូវព្រំដែន ដោយគ្រាន់តែលើកយកពីតួនាទីភារកិច្ច និងសមិទ្ធផលដែលសម្រេចបានរបស់អាជ្ញាធរនេះមកធ្វើការស្រាវជ្រាវបង្ហាញតែប៉ុណ្ណោះដើម្បីឱ្យមានភាពស៊ីជម្រៅ និងលម្អិតងាយស្រួលដល់អ្នកអាននៅក្នុងការស្វែងយល់ពីចំណុចសំខាន់ៗដែលយើងចង់បង្ហាញ។

**៥ សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ**

ស្នាដៃនៃការស្រាវជ្រាវមួយនេះបានជួយដល់អ្នកសិក្សា ឱ្យយល់ដឹងពីអាជ្ញាធរមួយនេះបានច្បាស់ទៅលើគោលបំណងនៃការបង្កើតឡើង និងសិក្សាឱ្យកាន់តែស៊ីជម្រៅលើចក្ខុវិស័យនៃការធ្វើបេសកកម្មរបស់អាជ្ញាធរនោះ។ បន្ទាប់ពីបានយល់ច្បាស់លាស់ពីបញ្ហាខាងលើនេះរួចមក យើងជឿជាក់ថាពួកគេនិងអាចទទួលបាននូវចំណេះដឹងមួយជាក់លាក់ស្តីពីអាជ្ញាធរមួយនេះ ហើយក៏បានយល់ច្បាស់ពីអត្ថប្រយោជន៍នៃប្រាង្គប្រាសាទបុរាណខ្មែរទាំងអស់ ដែលមានតម្លៃមិនអាចកាត់ថ្លៃបាន។ ម្យ៉ាងវិញទៀត វាក៏ជាការចូលរួមចំណែកក្នុងការផ្សព្វផ្សាយទៅដល់ជនរួមជាតិទាំងអស់ ឱ្យបានយល់ដឹងពីអត្តសញ្ញាណជាតិខ្លួនចេះអភិរក្ស ថែរក្សាការពារនូវកេរ្តិ៍តំណែលពីដូនតា និងលើកស្ទួយនូវសម្បត្តិវប្បធម៌ទាំងនោះឱ្យកាន់តែរុងរឿង ។

**៦ វិធីសាស្ត្រស្រាវជ្រាវ**

ការស្រាវជ្រាវមួយនេះដើម្បីអាចសម្រេចទៅបាន យើងបានធ្វើការពិគ្រោះ និងពិភាក្សាស្វែងរកឯកសារ ពីសាស្ត្រាចារ្យនានា ដែលក្នុងនោះរួមមានទាំងសៀវភៅ របាយការណ៍ផ្សេងៗ លិខិតគតិយុត្តនានា ស្តីពីការបង្កើតការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរមួយនេះ។ លើសពីនេះទៅទៀតយើងក៏បានស្រាវជ្រាវបន្ថែមនៅតាម គេហទំព័រអ៊ីនធើណេត និងវេបសាយមួយចំនួន ដែលបង្កើតដោយស្ថាប័នមួយចំនួនដែលពាក់ព័ន្ធដើម្បីឱ្យស្របនិងការវិវត្តន៍ជាក់ស្តែង ។

**៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ**

ចំពោះការសិក្សាស្រាវជ្រាវខាងក្រោមនេះ គឺយើងបានបែងចែកជា ២ ជំពូកសំខាន់ៗ ដែលជំពូកទី១ បានធ្វើការរៀបរាប់ពីទិដ្ឋភាពទូទៅដែលផ្តោតទៅលើការបង្កើតអាជ្ញាធរនេះក្នុងគោល បំណងអ្វី មានរចនាសម្ព័ន្ធនិង ធនធានហិរញ្ញវត្ថុយ៉ាងដូចម្តេច? ចំណែកឯក្នុងជំពូកទី២ និយាយអំពីតួនាទី និងភារកិច្ចរបស់អាជ្ញាធរអប្សរា និងសមិទ្ធផលដែលសម្រេចបានរួមទាំងបញ្ហាប្រឈមទាំងឡាយដែលបានជួបប្រទះកន្លងមក ។

## ជំពូកទី១៖

## ទិដ្ឋភាពទូទៅ

នៅឆ្នាំ១៩៩១ប្រទេសយើងនៅមានសង្គ្រាមផ្ទៃក្នុង នៅមានបញ្ហាអសន្តិសុខក្នុងតំបន់អង្គរ ក៏ដូចជាតំបន់ផ្សេងៗទៀតក្នុងប្រទេសយើង ដូច្នេះហើយការការពារតំបន់អង្គរយើងពុំអាចធ្វើបានពេញលេញគ្រប់គ្រាន់នៅឡើយទេ។ ប្រាង្គប្រាសាទរបស់យើង ដែលមានអាយុកាលយូរមកហើយ ត្រូវរងគ្រោះដោយសារគ្រោះធម្មជាតិ ប្រាសាទត្រូវដើមឈើដុះពាសពេញបង្កជាគ្រោះថ្នាក់។ នៅពេលដែលមានសភាពដូចនោះ ព្រះករុណាព្រះបាទសម្តេចនរោត្តមសីហនុ អតីតព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាក្នុងពេលដែលព្រះអង្គ ជាព្រះប្រធាននៃក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ទ្រង់បានធ្វើការអំពាវនាវដើម្បីឱ្យមានការការពារ និងទប់ស្កាត់នូវភាពវិនាសដែលកើតមានជាងបីទសវត្សទៅហើយមកលើប្រាសាទនានានៅតំបន់អ

ង្គរ ។ ក្រោយមកព្រះអង្គក៏បានជួបនិងលោកអគ្គនាយកយូណេស្កូ សុំដាក់បញ្ចូលអង្គរក្នុងបញ្ជីបេតិកភណ្ឌពិភពលោក។ ដោយមើលឃើញពីតម្លៃដ៏មហាសាលនៃសម្បត្តិមរតកអង្គរ និងភាពវិនាសដែលបាននិងកំពុងលេបត្របាក់នូវស្នាដៃដ៏វិចិត្រត្រកាលនេះ នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩២ អង្គរបានជាប់ចំណាត់ថ្នាក់នៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក នៃអង្គការយូណេស្កូជាបណ្តោះអាសន្ន ដែលវាខុសពីនីតិវិធីនៃការចុះបញ្ជីបេតិកភណ្ឌលោក ។

អាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ (អាជ្ញាធរជាតិអប្សរា ឬ អ.ជ.អ) ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៩៥ ដើម្បីការឆ្លើយតបជាពិសេសទៅនឹងលក្ខខណ្ឌមួយក្នុងចំណោមលក្ខខណ្ឌនានានៃការចុះបញ្ជីរមណីយដ្ឋានអង្គរក្នុងបេតិកភណ្ឌពិភពលោក ដែលបានធ្វើឡើងក្នុងខែធ្នូ ឆ្នាំ១៩៩២ នៅទីក្រុងសាន់តាហ្វេ (មិចស៊ីកូថ្មី) នៃសហរដ្ឋអាមេរិក។ លើសពីនេះទៀត នៅក្នុងសម័យប្រជុំលើកទី១៩ របស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោក នាខែធ្នូ ឆ្នាំ១៩៩៥ នៅទីក្រុងប៊ែរឡាំង សេចក្តីប្រកាសស្តីពីការបង្កើតអាជ្ញាធរជាតិអប្សរា ដោយរាជរដ្ឋាភិបាលកម្ពុជា ត្រូវបានទទួលការសាទរការពេញចិត្តយ៉ាងខ្លាំង ពីសំណាក់សហគមន៍អន្តរជាតិ។ ការចូលជាបេតិកភណ្ឌពិភពលោក គឺវាពិតជាមានដំណាក់កាលច្រើនដែលត្រូវអនុវត្ត ហើយវាក៏ជាមុខមាត់ថ្មីមួយដែរសម្រាប់ប្រទេសជាតិ ប្រជាជនដែលមានមហាសំណាងបានក្លាយជាម្ចាស់នៃសម្បត្តិបេតិកភណ្ឌដ៏មានតម្លៃមួយនេះ និងក៏បាននាំចំណាប់អារម្មណ៍ឱ្យពិភពលោកបានស្គាល់ពីប្រទេសជាតិយើងផងដែរ ។

ដើម្បីឱ្យអង្គរក្លាយជាបេតិកភណ្ឌពិភពលោកអចិន្ត្រៃយ៍ ក្នុងរយៈពេលបីឆ្នាំកម្ពុជាយើងត្រូវបំពេញនូវកាតព្វកិច្ចដែលបានដាក់ដោយអង្គការយូណេស្កូ[1] ៖

- ការបង្កើតនីតិក្រមសម្រាប់ការពារឱ្យបានត្រឹមត្រូវ
- កម្រិតព្រំដែនអចិន្ត្រៃយ៍ដោយផ្អែកលើគម្រោងរបស់ UNDP
- បង្កើតតំបន់ទ្រនាប់រវាងឧទ្យាននិងក្រុងសៀមរាប
- បង្កើតភ្នាក់ងារជាតិមួយសំរាប់ការពារបេតិកភណ្ឌដែលមានចំនួនសមស្រប

[1] គេហទំព័រ អ៊ីនធើណិត *អាជ្ញាធរជាតិអប្សរា*

- បង្កើតស្ថាប័នអភិរក្ស និងសម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍន៍រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ ហៅកាត់ថា ICC ។

ជាបឋម ដើម្បីឱ្យមានភាពងាយស្រួលដល់អ្នកសិក្សា និងអ្នកអានក្នុងការស្វែងយល់ និងឆាប់ទទួលបាន ជាដំបូងយើងនិងនិយាយអំពី **គោលបំណងក្នុងការការពារប្រាសាទ(១.១)** និងបន្តនិយាយពី **រចនាសម្ព័ន្ធ និងធនធានហិរញ្ញវត្ថុរបស់អាជ្ញាធរ(១.២)** ។

## ១.១ គោលបំណងក្នុងការការពារប្រាសាទបុរាណ

ដោយមើលឃើញពីសក្តានុពលដ៏ខ្លាំងក្លានៃតំបន់អង្គរ ទើបអង្គការយូណេស្កូបានតម្រូវឱ្យកម្ពុជាបង្កើតអាជ្ញាធរជាតិមួយ ដើម្បីការពាររមណីយដ្ឋាន និងចាត់ចែងតំបន់អង្គរ ដែលហៅកាត់ថា **អាជ្ញាធរអប្សរា** ក្នុងគោលបំណងបញ្ចៀសនូវវិវាទសមត្ថកិច្ចនៃក្រសួងនានា ដែលពាក់ព័ន្ធនឹងការចាត់ចែងចំពោះផលប្រយោជន៍ពីតំបន់អង្គរ។ ឆ្លើយតបទៅនឹងលក្ខខណ្ឌនេះនាថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ព្រះមហាក្សត្រនរោត្តម សីហនុ បានចេញព្រះរាជក្រឹត្យបង្កើតអាជ្ញាធរអប្សរា ។ ដោយមានបដិវាទកម្មរវាងព្រះរាជក្រឹត្យបង្កើតអាជ្ញាធរអប្សរា នឹងព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខខណ្ឌគតិយុត្តិនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល ទើបមានព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/៨១ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៩ ដើម្បីកែសម្រួលព្រះរាជក្រឹត្យបង្កើតអាជ្ញាធរអប្សរា នៅឆ្នាំ១៩៩៥ ព្រមទាំងបានបង្កើតនូវភាពច្បាស់លាស់មួយនៃការរៀបចំរចនាសម្ព័ន្ធអាជ្ញាធរអប្សរា និងកំណត់បេសកកម្មឱ្យអាជ្ញាធរនេះ។

ការការពារសម្បត្តិបេតិកភណ្ឌមួយឱ្យបានគង់វង្សថ្លៃថ្លា យើងគប្បីធ្វើការស្វែងយល់ពីយន្ត-ការនៃ **ការការពារ និងអភិរក្សប្រាសាទបុរាណ(១.១.១)** និង **ការបណ្តុះបណ្តាលអំពីប្រាសាទបុរាណ(១.១.២)** ។

### ១.១.១ ការការពារ និង អភិរក្សប្រាសាទបុរាណ

ការការពារ និងអភិរក្សយើងធ្វើការការពារទៅលើតម្លៃបេតិកភណ្ឌដែលយើងមានចាប់តាំងពីបុរាណមកធ្វើយ៉ាងណាការពារ

និងអភិវឌ្ឍឱ្យវានៅតែមានលក្ខណៈល្អក្នុងការទាក់ទាញការចាប់អារម្មណ៍ពីទេសចរណ៍បរទេស។ រាជរដ្ឋាភិបាលកម្ពុជា បានយកចិត្តទុកដាក់ជាពិសេសទៅនឹងការងាររបស់អាជ្ញាធរជាតិអប្សរា និងភាពជោគជ័យប្រតិបត្តិការការពារ ព្រមទាំងលើកតម្លៃរមណីយដ្ឋានអង្គរ ។ ក៏ប៉ុន្តែការលើកតម្លៃរមណីយដ្ឋានអង្គរនោះមិនអាចសម្រេចបានគ្រប់ជ្រុងជ្រោយនោះទេ ប្រសិនបើសកម្មភាពនៃការអភិរក្សមិនមានគម្រោងអភិវឌ្ឍច្បាស់លាស់ភ្ជាប់មកជាមួយ ដើម្បីលើកតម្លៃបេតិកភណ្ឌអរូបីដែលពិតជាមានទំនាក់ទំនងយ៉ាងខ្លាំង ជាមួយអត្តសញ្ញាណនៃតំបន់អង្គរ និងសមាសធាតុសំខាន់ៗដទៃទៀត ដែលមានគុណប្រយោជន៍ដល់ការរីកចម្រើនរបស់ប្រជាជន ។ នៅបុរាណកាលអង្គរជាទីក្រុងមួយនៃកម្ពុជាដែលនៅទីនោះមានភាពអ៊ូអរខ្លាំង ព្រោះមានប្រជាជនរស់នៅច្រើន ប៉ុន្តែដោយឆ្លងកាត់ច្រើនសម័យកាល មានសង្គ្រាមរ៉ាំរ៉ៃផង រួមទាំងការបំផ្លិចបំផ្លាញពីគ្រោះធម្មជាតិផងបានធ្វើឱ្យប្រាសាទមានការខូចខាតច្រើន ហើយក៏ប៉ះពាល់ដល់ការរស់នៅរបស់ប្រជាពលរដ្ឋផងដែរ ប៉ុន្តែរហូតមកដល់បច្ចុប្បន្នគេក៏នៅតែឃើញមានប្រជាជនរស់នៅលើទឹកដីអង្គរនៅមានដដែល ទោះបីជាមានការលំបាកក្នុងជីវភាពរស់នៅយ៉ាងណាក៏ដោយ។ ម្យ៉ាងវិញទៀតទោះមានការដាក់កំហិតឱ្យអនុវត្តនូវបទដ្ឋានបេតិកភណ្ឌដែលតម្រូវឡើងដោយអាជ្ញាធរក៏ដោយ ក៏ប្រជាពលរដ្ឋនៅក្នុងតំបន់ការពារនោះ នៅតែបន្តរស់នៅជាមួយប្រពៃណីទំនៀមទម្លាប់របស់ពួកគេការរស់នៅបែបនេះក៏ជាមធ្យោបាយចាំបាច់ ក្នុងការបង្ហាញពីទំនៀមទម្លាប់ប្រពៃណីនៃការរស់នៅ និងការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាជនដែលរស់នៅទីនោះផងដែរ។

ចំណែកឯការអភិរក្សប្រាសាទបុរាណខ្មែរវិញ នៅក្នុងនោះកិច្ចការពារ អភិរក្ស និងអភិវឌ្ឍបេតិកភណ្ឌក៏មិនសំដៅត្រឹមការជួសជុសតែប្រាង្គប្រាសាទនោះទេ គឺជួសជុលគ្រប់អ្វីដែលជាតម្លៃនៃបេតិកភណ្ឌដូចគ្នា បើប្រាសាទរលំហើយគ្មានការថែរក្សាបានល្អនោះតម្លៃនៃបេតិកភណ្ឌក៏ធ្លាក់ចុះ ដោយឡែកបើប្រាសាទជួសជុលបានល្អ មានការថែរក្សា និងអភិរក្សបានល្អហើយ តែផ្តោតទៅលើបរិស្ថានជុំវិញប្រាសាទវិញពេញដោយសំណង់ថ្មីៗ បាត់បង់ព្រៃឈើ រួមទាំងហេដ្ឋារចនាសម្ព័ន្ធបុរាណរងនូវការប៉ះពាល់នោះ តម្លៃនៃវប្បធម៌នេះក៏ធ្លាក់ចុះដូចគ្នាដែរ។ ហេតុដូច្នេះហើយ កិច្ចការ ពារ និងគ្រប់គ្រងរមណីយដ្ឋានអង្គរបេតិកភណ្ឌពិភពលោកត្រូវតែមានការចូលរួមយ៉ាងយកចិត្តទុក

ដាក់ពីគ្រប់ស្ថាប័នពាក់ព័ន្ធទាំងជាតិ និងអន្តរជាតិរួមនឹងប្រជាជនផងដោយខានពុំបានទេ ។ នៅក្នុងរយៈពេល២០ឆ្នាំនៃការងារជួសជុល អភិរក្ស និងអភិវឌ្ឍប្រកបទៅដោយចីរភាពនៅរមណីយដ្ឋានអង្គរ ជាពិសេសដោយសារតែមានការយកចិត្តទុកដាក់ខ្ពស់ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា ដែលមាន **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខ និងការដឹកនាំចង្អុលបង្ហាញដោយផ្ទាល់ពី **ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន** ឧបនាយករដ្ឋមន្ត្រី ជារដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិអប្សរា ព្រមទាំងការចូលរួមពីបណ្ដាប្រទេសជាមិត្តផងដែរ រមណីយដ្ឋាននេះបានក្លាយខ្លួនជាគោលដៅទេសចរណ៍លេខ១ នៅលើពិភពលោកក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ[2]។ ការលេចធ្លោទាំងនេះពិតជាបង្ហាញពីសក្ដីភាពការរីកចម្រើនឥតឈប់ឈរនៃសេដ្ឋកិច្ចជាតិ ហើយរមណីយដ្ឋានអង្គរក៏បានដើរតួនាទីជាប្រភពចំណូល ដ៏មានសក្ដានុពលមួយក្នុងការចូលរួមចំណែកលើកកម្ពស់សេដ្ឋកិច្ចជាតិឱ្យមានការរីកលូតលាស់កាន់តែឆាប់រហ័សបន្ថែមទៀត ។ លើសពីនេះទៅទៀត ដើម្បីឱ្យការការពារនិង អភិរក្សនោះកាន់តែមានប្រសិទ្ធភាពខ្ពស់នោះ គឺត្រូវតែមានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និតជាមួយនិងក្រសួងស្ថាប័ននានាដែលពាក់ព័ន្ធ ដើម្បីសហការគ្នាអភិវឌ្ឍន៍តំបន់នេះឱ្យបានគ្រប់ជ្រុងជ្រោយ។ ការការពារ និងអភិរក្សធ្វើឡើងបានដោយគេត្រូវស្គាល់ពីលក្ខណៈធម្មជាតិរបស់ថ្ម ក៏ដូចជាយល់ពីដំណើរនៃការសឹករិចរិលរបស់ប្រាសាទផងដែរ ការអភិរក្សនេះធ្វើយ៉ាងណាឱ្យវាដូចទៅនិងសម័យកាលមុនដែលបុព្វបុរសយើងបានកសាង ប៉ុន្តែវាក៏ត្រូវបានការ ពារដោយបច្ចេកទេសវិទ្យាសាស្ត្រមួយចំនួនផងដែរ ដើម្បីជួយទ្រទ្រង់ឱ្យប្រាសាទកាន់តែរឹងមាំទៅពេលអនាគតយូរអង្វែង ជាក់ស្ដែងយើងអាចឃើញហើយថាការងារអភិរក្ស ជួសជុល និងគ្រប់គ្រងរមណីយដ្ឋានអង្គរដែលជាតំបន់បេតិកភណ្ឌពិភពលោក បានទទួលលទ្ធផលល្អជាច្រើនមកហើយ។ ហើយកន្លងមកអាជ្ញាធរជាតិអប្សរាធ្លាប់បានបើកវគ្គបណ្ដុះបណ្ដាលស្ដីពី ការងារអភិរក្សនេះក៏ច្រើនហើយដែរ ចំណែកលទ្ធផលវិញក៏ទទួលបានផ្លែផ្កាល្អផងដែរ។

[2] សៀវភៅកិច្ចការពាររមណីយដ្ឋានអង្គរ និងបញ្ហាដីធ្លី ខែឧសភា ឆ្នាំ២០០៥

## ១.១.២ ការបណ្តុះបណ្តាលអំពីប្រាសាទបុរាណ

ការបណ្តុះបណ្តាលអំពីប្រាសាទបុរាណ គឺជាការបង្កើននូវចំណេះដឹងផ្សេងៗដែលពាក់ព័ន្ធនិងតម្លៃនៃប្រាសាទបុរាណខ្មែរ ព្រមទាំងអប់រំពីអ្វីដែលជាផលប៉ះពាល់ដល់តម្លៃនៃបេតិកភណ្ឌជាតិដ៏ថ្លៃថ្លាមួយនេះ។ ចំណែកឯគោលដៅសំខាន់ គឺធ្វើឡើងដើម្បីលើកកម្ពស់ដល់ការយល់ដឹងរបស់សាធារណៈជន សិស្សនិស្សិត ភ្នាក់ងារ និងមន្ត្រីបុគ្គលិកពាក់ព័ន្ធ ប្រជាពលរដ្ឋ ភ្ញៀវទេសចរពីគុណតម្លៃបេតិកភណ្ឌ និងកាតព្វកិច្ចរបស់អាជ្ញាធរជាតិអប្សរានៅក្នុងកិច្ចការពារអភិរក្ស និងអភិវឌ្ឍប្រកប ដោយចីរភាព។ ដោយសារតែអាជ្ញាធរអប្សរា ជាស្ថាប័នមួយដែលធ្វើការគ្រប់គ្រងសំខាន់លើបញ្ហានេះក៏បានរៀបចំនូវគម្រោងនៃវគ្គបណ្តុះបណ្តាលជាច្រើនដូចជា វគ្គបណ្តុះបណ្តាលស្តីពីកិច្ចការពារនិងគ្រប់គ្រងរមណីយដ្ឋានអង្គរបេតិកភណ្ឌពិភពលោក (ដែលធ្វើឡើងថ្ងៃទី ០៨ មេសា ឆ្នាំ២០១៦) វគ្គសិក្សាកសាងសមត្ថភាពមន្ត្រីបុគ្គលិកបច្ចេកទេសអំពីផែនការមេ សម្រាប់ការអភិរក្សប្រាសាទនៅក្នុងតំបន់អង្គរ(នៅថ្ងៃទី០៧ មិនា ២០១៦) ព្រមទាំងវគ្គបណ្តុះបណ្តាលសមត្ថភាពអំពីការរៀបចំផែនការមេសម្រាប់ការអភិរក្សប្រាសាទនៅក្នុងតំបន់អង្គរពីសំណាក់អ្នកជំនាញបារាំង (នៅថ្ងៃទី០២ មិនា ២០១៦)[3]។ល។ មិនត្រឹមតែប៉ុណ្ណោះ អាជ្ញាធរនេះក៏បានបង្កើតនូវវគ្គសិក្សាមួយចំនួនសម្រាប់សិស្សានុសិស្សដូចជា រៀបចំទស្សនកិច្ចសិក្សាដល់និស្សិតបុរាណវិទ្យានៅតំបន់អង្គរ (ថ្ងៃទី០១-១០ ខែមីនា ឆ្នាំ២០១៦ អាជ្ញាធរជាតិអប្សរាក៏បានរៀបចំទស្សនកិច្ចសិក្សាដល់និស្សិតឆ្នាំទី៤ ចំនួន៣០នាក់នៃមហាវិទ្យាល័យបុរាណវិទ្យា របស់សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ដើម្បីធ្វើការសិក្សាឈ្វេងយល់អំពីការងារអភិរក្ស ការគ្រប់គ្រងប្រាង្គប្រាសាទ និងបុរាណវិទ្យានៅក្នុងតំបន់អង្គរ ព្រមទាំងនៅរមណីយដ្ឋានកោះកេរ បេងមាលាទៀតផងដែរ ទទួលបន្ទុកទាំងស្រុងដោយអាជ្ញាធរជាតិអប្សរា)[4]។ នេះជាសកម្មភាពដែលអាជ្ញាធរជាតិអប្សរាតែងតែធ្វើជាប្រចាំ សម្រាប់ជួយដល់និស្សិតដែលសិក្សាផ្នែកបុរាណវិទ្យា ដើម្បីឱ្យពួកគេបានសិក្សាបន្ថែមទៅលើចំណេះដឹងនៅសាលា

[3] គេហទំព័រ អ៊ីនធើណិត *អាជ្ញាធរជាតិអប្សរា* (www.apsaraauthority.gov.kh)

[4] គេហទំព័រ អ៊ីនធើណិត *អាជ្ញាធរជាតិអប្សរា* (www.apsaraauthority.gov.kh)

និងមានប្រសិទ្ធភាពក្នុងការធ្វើការងារនាពេលអនាគត។ មិនត្រឹមតែប៉ុណ្ណោះ ចំពោះការបណ្តុះបណ្តាលនេះផងដែរ អាជ្ញាធរនេះបានធ្វើសកម្មភាពយ៉ាងពេញទំហឹង ដោយបានអញ្ជើញអ្នកជំនាញទាំងក្នុងប្រទេស និងក្រៅប្រទេសមកធ្វើការបង្ហាញពីបទបពិសោធន៍ក៏ដូចជារៀបចំនូវវគ្គបណ្តុះបណ្តាលផ្សេងៗដែលមានលោក SIMON Jean-Christophe ជាស្ថាបត្យករនិងជាអ្នកទទួលខុសត្រូវផ្នែកអធិការកិច្ចបេតិកភណ្ឌនៃប្រទេសបារាំង ព្រមទាំងជាអ្នកដែលរាជរដ្ឋាភិបាលបារាំងបញ្ជូនឱ្យមកធ្វើការនៅតំបន់អង្គរ និងបានចូលរួមបង្កើតស្ថាប័នអាជ្ញាធរជាតិអប្សរានាឆ្នាំ១៩៩៥។ លោក SIMON បានប្រាប់ពីគោលបំណងនៃវគ្គសិក្សានេះថា ធ្វើឡើងដើម្បីបង្កើនសមត្ថភាពចំណេះដឹងជំនាញអំពីការរៀបចំផែនការមេសម្រាប់អភិរក្សប្រាសាទ ការរៀបចំ និងគ្រប់គ្រងប្រាសាទដល់មន្ត្រីបុគ្គលិកនៃអាជ្ញាធរជាតិអប្សរាដែលពាក់ព័ន្ធដោយផ្តោតសំខាន់ទាំងទ្រឹស្តី និងការអនុវត្តជាក់ស្តែងនៅប្រាសាទព្រះគោ និងប្រាសាទបាគង។ លោកបន្តទៀតថា បើរៀបចំផែនការមេក្នុងការអភិរក្សប្រាសាទបានល្អ នឹងអាចដោះស្រាយបញ្ហាក្នុងការអភិរក្សប្រាសាទបញ្ហាទាក់ទងនឹងតំបន់អភិរក្សជុំវិញប្រាសាទ បញ្ហាសេដ្ឋកិច្ចប្រជាពលរដ្ឋមូលដ្ឋាននៅជុំវិញប្រាសាទ ដែលអាចជួយឱ្យអាជ្ញាធរជាតិអប្សរារៀបចំគ្រប់គ្រងនូវគោលនយោបាយទេសចរណ៍ឱ្យទទួលបាននូវសេវាល្អពេញលេញមួយ។ ក្រៅពីនោះក៏ទាក់ទងនឹងការអប់រំរបស់សិស្សនិស្សិតផងដែរ ព្រោះប្រាសាទជាផ្នែកមួយនៃការអភិវឌ្ឍន៍[5]។

## ១.២ រចនាសម្ព័ន្ធ និងធនធានហិរញ្ញវត្ថុរបស់អាជ្ញាធរ

ជាការពិតណាស់ រចនាសម្ព័ន្ធ និងធនធានហិរញ្ញវត្ថុ វាពិតជាមានភាពចាំបាច់ណាស់ដើម្បីធ្វើឱ្យស្ថាប័នមួយនេះ អាចលេចចេញជារូបរាងបានប្រកបទៅដោយលក្ខណៈគតិយុត្ត។ ដូចនេះហើយ ជាដំបូងយើងគប្បីគួរយល់អំពី **រចនាសម្ព័ន្ធ(១.២.១)** និង **ធនធានហិរញ្ញវត្ថុរបស់អាជ្ញាធរនោះ(១.២.២)** ។

### ១.២.១ រចនាសម្ព័ន្ធ

[5] គេហទំព័រ អ៊ីនធើណិត *អាជ្ញាធរជាតិអប្សរា* (www.apsaraauthority.gov.kh)

ជាគោលការណ៍នៅគ្រប់ក្រសួង ឬស្ថាប័នដែលបានបង្កើតឡើងតែងតែមាននូវរចនាសម្ព័ន្ធផ្ទាល់របស់ខ្លួនដែលអនុវត្តទៅតាមច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃស្ថាប័ននោះដែលបានធ្វើការកំណត់ទុកដើម្បីរៀបចំបង្កើតនូវស្ថាប័នមួយដែលពោរពេញទៅដោយលក្ខណៈគតិយុត្តតាមច្បាប់។ ចំណែកធនធានហិរញ្ញវត្ថុវិញ គឺអាជ្ញាធរនេះមានស្វ័យភាពហិរញ្ញវត្ថុផ្ទាល់សម្រាប់ដំណើរការប្រតិបត្តិការរបស់ខ្លួន។

- **រចនាសម្ព័ន្ធដឹកនាំ**

ចំណែកឯការគ្រប់គ្រងជារចនាសម្ព័ន្ធដឹកនាំនេះ មានសមាសភាពថ្នាក់ដឹកនាំដូចជាក្រុមប្រឹក្សាភិបាល ប្រធានអគ្គនាយក និងអគ្គនាយករង។

- **ក្រុមប្រឹក្សាភិបាល**

បន្ទាប់ពីបានបង្កើតអាជ្ញាធរអប្សរាកាលពីខែកុម្ភៈ ឆ្នាំ១៩៩៥រួចមក ក្រុមប្រឹក្សាភិបាលត្រូវបានបង្កើតឡើងក្នុងគោលបំណងគ្រប់គ្រងកិច្ចការសំខាន់ៗរបស់អាជ្ញាធរជាតិអប្សរា។ នៅក្នុងនេះផងដែរ អាជ្ញាធរនេះមានស្វ័យភាពផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ។

សមាជិកក្រុមប្រឹក្សាភិបាលរួមប្រជុំយ៉ាងតិច៦ដងក្នុង១ឆ្នាំ តាមការកោះអញ្ជើញរបស់សហប្រធានដែលជាអ្នកកំណត់របៀបវារៈ។ ក្រុមប្រឹក្សាភិបាលត្រូវមានប្រជុំក្នុងខែបន្ទាប់ បើសិនជាការកោះអញ្ជើញត្រូវបានសុំដោយសមាជិកចំនួន១ភាគ៤នៃសមាជិកទាំងអស់។ ក្នុងការអនុម័តផ្សេងៗ ត្រូវកំណត់តាមសម្លេងភាគច្រើននៃសមាជិកនៃអង្គប្រជុំ ។ ក្នុងករណីមានសម្លេងស្មើគ្នា សម្លេងរបស់សហប្រធានមានឧត្តមានុភាពក្នុងការអនុម័ត។ មិនតែប៉ុណ្ណោះ សហប្រធានអាចអញ្ជើញរាល់សមាជិកណាក៏ដោយដើម្បីឱ្យចូលរួមក្នុងអង្គប្រជុំក្នុងករណីដែលខ្លួនយល់ថាវត្តមានបុគ្គលនោះមានប្រយោជន៍សម្រាប់ការងារនេះ[6]។

អាជ្ញាធរអប្សរា ត្រូវបានគ្រប់គ្រងដោយក្រុមប្រឹក្សាភិបាលដែលមានសមាសភាពចេញពីអន្តរក្រសួងហើយសមាសភាពទាំងនោះមានដូចជា៖

ក្រុមប្រឹក្សាភិបាលរបស់អាជ្ញាធរអប្សរាមានសមាសភាព១១រូប[7]៖

[6] ព្រះរាជក្រឹត្យបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅកាត់ថា អាជ្ញាធរ "អប្សរា" នស/រកត/០២៩៥/១២, ១៩ កុម្ភៈ ១៩៩៥, មាត្រា៧។

[7] ព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការកែសម្រួលបទប្បញ្ញត្តិមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរអប្សរាដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថា អាជ្ញាធរ "អប្សរា" មាត្រា៩ថ្មី។

- ប្រធានអគ្គនាយកអាជ្ញាធរអប្សរា ១នាក់
- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ១នាក់
- តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ១នាក់
- តំណាងក្រសួងមហាផ្ទៃ ១នាក់
- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១នាក់
- តំណាងក្រសួងទេសចរណ៍ ១នាក់
- តំណាងក្រសួងបរិស្ថាន ១នាក់
- តំណាងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ១នាក់
- តំណាងក្រសួងសាធារណៈការ និងដឹកជញ្ជូន ១នាក់
- អភិបាលកិច្ចសៀមរាប ១នាក់
- តំណាងបុគ្គលិកអាជ្ញាធរអប្សរា ១នាក់

សមាជិកក្រុមប្រឹក្សាភិបាល ត្រូវតែងតាំងឡើងដោយអនុក្រឹត្យ ហើយអាចរំលាយវិញដោយអនុក្រឹត្យនៅពេលណាក៏បាន។ ក្រុមប្រឹក្សាភិបាល មានអាណត្តិរយៈពេល៣ឆ្នាំ ហើយអាចបន្តអាណត្តិសារជាថ្មីបាល។ ចំណែកការបញ្ចប់អាណត្តិរបស់សមាជិកណាម្នាក់ អាចត្រូវធ្វើឡើងតាមសំណើរបស់ក្រសួងដែលសមាជិកនោះតំណាងឱ្យ។ រដ្ឋទទួលខុសត្រូវបទស៊ីវិលដែលពាក់ព័ន្ធទៅនឹងការបំពេញបេសកកម្មរបស់សមាជិកក្រុមប្រឹក្សា លើកលែងតែក្នុងករណីធ្វើខុសដោយចេតនា។ សមាជិកក្រុមប្រឹក្សាភិបាល ទទួលខុសត្រូវផ្ទាល់លើកំហុសព្រហ្មទណ្ឌដែលខ្លួនបានប្រព្រឹត្ត។

មិនត្រឹមតែប៉ុណ្ណោះ ក្រុមប្រឹក្សាភិបាល គឺជាអ្នកដឹកនាំ និងទទួលខុសត្រូវការងារធំៗរបស់អាជ្ញាធរអប្សរា។ ប្រធានក្រុមប្រឹក្សាភិបាលមានតួនាទី និងមុខតំណែងជាប្រធានអគ្គនាយកនៃអាជ្ញាធរអប្សរា ។

ក្រុមប្រឹក្សាភិបាល មានសិទ្ធិអនុម័ត[៦]៖

- ការតម្រង់ទិសរាល់សកម្មភាពរបស់អាជ្ញាធរអប្សរា

[៦] ព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរអប្សរាដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថា អាជ្ញាធរ "អប្សរា" មាត្រា៦។

- បទបញ្ជាផ្ទៃក្នុងរបស់អាជ្ញាធរអប្សរា
- របាយការណ៍ប្រចាំឆ្នាំដែលប្រធានអគ្គនាយកបានដាក់ជូន
- ទឹកប្រាក់បង់ថ្លៃឈ្នួល និងចំណូលគ្រប់បែបយ៉ាងដែលអាជ្ញាធរអប្សរាប្រមូលបាន
- ចំនួនទឹកប្រាក់ និងលក្ខខណ្ឌនៃការខ្ចីបុល
- រាល់បញ្ហាដែលប្រធាន និងអគ្គនាយកដាក់ឱ្យពិនិត្យ។

ប្រធានក្រុមប្រឹក្សា ឬប្រធានអគ្គនាយកមានតួនាទី និងភារកិច្ចដូចតទៅ[9]៖

- តំណាងរាជរដ្ឋាភិបាលនៅក្នុងកិច្ចប្រជុំគ្រប់ពិធី និងគ្រប់ការចរចារដែលពាក់ព័ន្ធនឹងតំបន់រមណីយដ្ឋានអង្គរ
- មានសិទ្ធិចុះហត្ថលេខាលើកិច្ចព្រមព្រៀងលើពិធីសារ និងលើកិច្ចសន្យាទាំងឡាយដែលទាក់ទងទៅនឹងរមណីយដ្ឋានអង្គរ ក្រោយពីទទួលបានការឯកភាពពីរដ្ឋមន្ត្រីក្រសួងអាណាព្យាបាលបច្ចេកទេស
- ជាអាណាបក័ដើមខ្សែនៃអាជ្ញាធរជាតិអប្សរា និងជាអ្នកពិនិត្យចំណូលប្រាក់ទូទាត់បំណុលចាត់ចែងធ្វើការទូទាត់ និងចេញបញ្ជាចំណាយ
- អាចផ្ទេរសិទ្ធិទៅឱ្យអាណាប័កផ្ទេរសិទ្ធិ ឬក៏បង្កើតឱ្យមានការព្រមព្រៀងជាមួយគណនេយ្យករនូវរជ្ជទេយ្យចំណូល ឬបុរេប្រទាន។

ប្រធានអគ្គនាយក ត្រូវបានតែងតាំង ឬបញ្ឈប់ពីតំណែងដោយព្រះរាជក្រឹត្យ ។

- **ប្រធានអគ្គនាយក**

ប្រធានអគ្គនាយក ជានាយកប្រតិបត្តិទូទៅដែលទទួលបន្ទុកដឹកនាំកិច្ចការទូទៅរបស់អាជ្ញាធរជាតិអប្សរា។ ប្រធានអគ្គនាយកអាជ្ញាធរអប្សរា ត្រូវតែងតាំងដោយអនុក្រឹត្យដែលមានអាណត្តិ៣ឆ្នាំហើយអាចបន្តបានមួយអាណត្តិទៀត។ ប្រធានអគ្គនាយកមានតួនាទី និងមុខតំណែងជាប្រធានក្រុមប្រឹក្សាភិបាលរបស់អាជ្ញាធរអប្សរា[10]។

ប្រធានអគ្គនាយក ជានាយកប្រតិបត្តិទូទៅដឹកនាំកិច្ចការរបស់អាជ្ញាធរជាតិអប្សរា និងមានភារកិច្ច៖

- ប្រធានអគ្គនាយកមានតួនាទី និងមុខតំណែងជាប្រធានក្រុមប្រឹក្សាភិបាល

---

[9]ព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការកែសម្រួលបទប្បញ្ញត្តិមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរអប្សរាដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថា អាជ្ញាធរ "អប្សរា" មាត្រា៥។

[10]ព្រះរាជក្រឹត្យ នស/រកត/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ មាត្រា១១(១)។

- ជានាយកប្រតិបត្តិទូទៅ ដឹកនាំកិច្ចការរបស់អាជ្ញាធរជាតិអប្សរា
- រៀបចំប្រជុំក្រុមប្រឹក្សាភិបាល
- ទទួលបន្ទុកសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងដាក់ដំណើរការនយោបាយដែលបានកំណត់ដោយក្រុមប្រឹក្សាភិបាល
- ប្រធានអគ្គនាយកសម្របសម្រួលគម្រោងបច្ចេកទេសទាំងឡាយ ដែលរៀបចំឡើងដោយនាយកដ្ឋានបច្ចេកទេស ហើយដែលអនុម័តដោយក្រុមប្រឹក្សាភិបាល
- តែងតាំង និងតម្លើងឋានៈបុគ្គលិកទៅតាមផែនការ ដែលអនុម័តដោយក្រុមប្រឹក្សាភិបាលដូចជាការជ្រើសរើស ការតែងតាំង តម្លើងឋានៈបណ្តុះបណ្តាល និងបំពាក់បំប៉នបន្ថែមផ្នែកពហុបច្ចេកទេសវិជ្ជាសម្រាប់បុគ្គលិក
- ទទួលខុសត្រូវការគ្រប់គ្រងសម្ភារៈ ដូចជាការរៀបចំថវិកា ការបែងចែកថវិកា និងការបញ្ជាចំណាយ ព្រមទាំងសម្របសម្រួលនៅរាល់គម្រោងបច្ចេកទេសទាំងឡាយ ដែលនាយកដ្ឋានបច្ចេកទេសនីមួយៗរៀបចំឡើង ហើយមានការអនុម័តដោយក្រុមប្រឹក្សាភិបាល
- ទទួលបន្ទុកអាណាប័កដើមខ្សែ។ ចំពោះតួនាទីនេះ ប្រធានអគ្គនាយកពិនិត្យ និងទូទាត់ប្រាក់ចំណូល ឬបុរេប្បទានល្ហឹកណា មានការយល់ព្រមពីភ្នាក់ងារគណនេយ្យ
- ជាតំណាងរដ្ឋាភិបាលនៅក្នុងគ្រប់កិច្ចចរចាប្រជុំ និងគ្រប់ពិធីដែលពាក់ព័ន្ធទៅនឹងតំបន់រមណីយដ្ឋានអង្គរ និងមានបុព្វសិទ្ធិតំណាងឱ្យអាជ្ញាធរអប្សរា នៅចំពោះមុខអាជ្ញាធរជាតិ ស្ថាប័នអន្តរជាតិ និងតតិយជន
- មានសិទ្ធិចុះហត្ថលេខានៅលើកិច្ចព្រមព្រៀងពិធីសារ លើកិច្ចព្រមព្រៀងទាំងឡាយដែលទាក់ទងនិងតំបន់រមណីយដ្ឋាន ក្រោយពីការទទួលបានការឯកភាពពីរដ្ឋមន្ត្រី ក្រសួងអាណាព្យាបាលផ្នែកបច្ចេកទេស
- ទទួលបន្ទុកប្រតិបត្តិសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងចាត់វាល់វិធានការចាំបាច់សម្រាប់ដំណើរការល្អនៃអាជ្ញាធរជាតិអប្សរា ដែលមានប្រធានអគ្គនាយកជាតំណាងនៅចំពោះមុខតុលាការ។

ដើម្បីបំពេញតួនាទី និងភារកិច្ចខាងលើនេះ ប្រធានអគ្គនាយកមានអ្នកជំនួយការអគ្គនាយករង០១រូប ដែលទទួលបន្ទុករដ្ឋបាលកណ្តាលនៅទីស្នាក់ការខេត្តសៀមរាប ក្នុងការគ្រប់គ្រងផ្នែករដ្ឋបាលហិរញ្ញវត្ថុ និងទំនាក់ទំនងផ្សព្វផ្សាយ។ អគ្គនាយករង៤រូបទៀត ទទួលបន្ទុកគ្រប់គ្រងនាយកដ្ឋាននីមួយៗ។

- **អគ្គនាយករង**

អគ្គនាយករងអាជ្ញាធរអប្សរាត្រូវបានតែងតាំងឡើង និងបញ្ចប់ដោយអនុក្រឹត្យតាមការស្នើសុំរបស់ក្រុមប្រឹក្សាភិបាល។ មិនត្រឹមតែប៉ុណ្ណោះ អគ្គនាយករងទាំងអស់មានចំនួន០៥រូប ដែលមានតួនាទីជាជំនួយការរបស់ប្រធានអគ្គនាយក។ ហើយក្នុងចំណោមអគ្គនាយករងទាំង០៥ នោះមានដូចជា ៖

- អគ្គនាយករង០១រូប

ដែលទទួលបន្ទុកកិច្ចការរដ្ឋបាលកណ្តាលនៅទីស្នាក់ការខេត្តសៀមរាប នៅក្នុងការគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុ ព្រមទាំងការទំនាក់ទំនងផ្សព្វផ្សាយ

- អគ្គនាយករង០៤រូបទៀត ទទួលបន្ទុកនាយកដ្ឋានមួយៗ

ក្នុងការគ្រប់គ្រងផ្នែកបច្ចេកទេសវិទ្យាសាស្ត្រ ឬគម្រោងអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច។ ដែលអគ្គនាយករងទាំង៥រូប ជាជំនួយការរបស់ប្រធានអគ្គនាយកផងដែរ។

- **រចនាសម្ព័ន្ធរដ្ឋបាល**

ទាក់ទងទៅនឹងរចនាសម្ព័ន្ធរដ្ឋបាលនេះ យើងនឹងធ្វើការសិក្សាអំពីរដ្ឋបាលកណ្តាល និងនាយកដ្ឋានផ្សេងៗរួមមាន ៖

- **រដ្ឋបាលកណ្តាល**

រដ្ឋបាល ទទួលបាននូវអំណាចក្នុងការចេញសេចក្តីសម្រេចរដ្ឋបាល។ សេចក្តីសំរេចនេះ អាចមានលក្ខណៈជាបទបញ្ញត្តិទូទៅ ឬមានឯកត្តភូត។ រដ្ឋបាលកណ្តាល ស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ប្រធាន មានអគ្គនាយករង ០១រូប ជាជំនួយការក្នុងការដឹកនាំកិច្ចការទូទៅរបស់អាជ្ញាធរអប្សរានៅខេត្តសៀមរាបដូចជា ការគ្រប់គ្រងបុគ្គលិក សម្ភារៈ ថវិកា និងសម្របសម្រួលបច្ចេក ទេសនានាដែលត្រូវអនុវត្ត។ មិនត្រឹមតែប៉ុណ្ណោះ រដ្ឋបាលកណ្តាលនោះមាន០៣ការិយាល័យគឺការិយាល័យរដ្ឋបាល ភ្នាក់ងារគណនេយ្យ និងការិយាល័យទំនាក់ទំនងផ្សព្វផ្សាយ។

- **នាយកដ្ឋានរដ្ឋបាល បុគ្គលិក និង ហិរញ្ញកិច្ច និងទំនាក់ទំនងសាធារណៈ**

នាយកដ្ឋានរដ្ឋបាល បុគ្គលិក និងហិរញ្ញកិច្ច និងទំនាក់ទំនងសាធារណៈ ដែលអគ្គនាយកដ្ឋាននេះមានតួនាទី និងភារកិច្ចដូចខាងក្រោម[11]៖

[11] អនុក្រឹត្យស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា លេខ១១៥ អនក្រ.បក, ១១ មិថុនា ២០០៤, មាត្រា៨។

- ទទួលលិខិតចូលពិនិត្យ បែងចែកលិខិតតាមខ្លឹមសារជូនប្រធានអគ្គនាយក អគ្គនាយករង នាយកដ្ឋាននានាចំណុះអគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា និងផ្ញើរចេញនូវលិខិតបទដ្ឋាននៃអាជ្ញាធរអប្សរាជូនក្រសួង និងអាជ្ញាធរដែលពាក់ព័ន្ធ
- គ្រប់គ្រង និងអនុវត្តនូវសិទ្ធិអំណាចតាមឋានានុក្រមលើបុគ្គលិកទាំងអស់នៃអគ្គនាយកដ្ឋានអាជ្ញាធរអប្សរា
- អនុវត្តតម្លៃតាមតារាងកំណត់ប្រាក់បៀវត្ស ប្រាក់កំរៃ និង ប្រាក់ឧបត្ថម្ភផ្សេងៗសំរាប់ការងារនីមួយៗរបស់មន្ត្រីរាជការ និងបុគ្គលិកនៅអគ្គនាយកដ្ឋានអាជ្ញាធរអប្សរា
- រៀបចំជាមួយនាយកដ្ឋានបច្ចេកទេសនានា នូវកម្មវិធីមួយស្តីពីការកំណត់តំណែងឯកទេស និងការបែងចែកធនធានមនុស្ស
- រៀបចំគម្រោងជាមួយនាយកដ្ឋានបច្ចេកទេសពាក់ព័ន្ធ ស្តីពីតម្រូវការសម្រាប់បណ្តុះបណ្តាលវិជ្ជាជីវៈដល់មន្ត្រីរាជការ និងបុគ្គលិក
- រៀបចំជាមួយនាយកដ្ឋានបច្ចេកទេសពាក់ព័ន្ធ និងសំណើសុំថវិកា ឬការផ្តល់ថវិកាសម្រាប់ការងារបន្ទាន់
- រៀបចំស្ថិតិលើការគ្រប់គ្រងមន្ត្រីរាជការ បុគ្គលិកព្រមទាំងធ្វើតារាងការងារដែលអគ្គនាយកដ្ឋានអាជ្ញាធរអប្សរា បានអនុវត្តកន្លងមក និងត្រូវអនុវត្តបន្តនៅពេលអនាគត
- ប្រមូលប្រាក់ចំណូល និងចាត់ចែងចំណាយ
- រក្សាទុក និងចាត់ចែងការប្រើប្រាស់មូលនិធិ និងរូបិយប័ណ្ណ
- កាន់កាប់បញ្ជីគណនេយ្យ និងរក្សាទុកនូវលិខិតយុត្តិការសម្រាប់បណ្ណសារ
- រៀបចំគណនេយ្យហិរញ្ញវត្ថុប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំរបស់អាជ្ញាធរជាតិអប្សរា
- គ្រប់គ្រងវេបសាយ របស់អគ្គនាយកដ្ឋានអាជ្ញាធរអប្សរា
- រៀបចំផែនការមេក្នុងការអភិរក្ស និងអភិវឌ្ឍតំបន់សៀមរាប អង្គរ ដើម្បីធ្វើការផ្សព្វផ្សាយទំនាក់ទំនងជាមួយនិងវិនិយោគិនផ្នែកឯកជន ឱ្យចូលមកវិនិយោគនៅក្នុងបុរីសណ្ឋាគារ និងតំបន់សៀមរាប អង្គរ

- សហការសម្របសម្រួលក្នុងការរៀបចំព័ត៌មាន ស្តីពីផែនការសកម្មភាពការងាររបស់នាយកដ្ឋាននីមួយៗ និងកម្មវិធីការងារដែលនាយកដ្ឋាននានាកំពុងដំណើរការ
- ប្រមូល និងធ្វើការចងក្រងឯកសារនានា ដែលទាក់ទងនិងសកម្មភាពប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំរបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរជាតិអប្សរា ដើម្បីផ្សព្វផ្សាយជូនសាធារណៈជន បណ្តាញសារព័ត៌មានជាតិ អន្តរជាតិ និងប្រព័ន្ធឃោសនានូវសកម្មភាពការងារ និងសមិទ្ធផលរបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា ដោយអនុលោមតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល
- ទទួលខុសត្រូវទៅលើការងារពិធីការ និងមគ្គុទេសក៏សម្រាប់បម្រើដល់គណៈប្រតិភូជាន់ខ្ពស់ជាតិ និងអន្តរជាតិ ដែលចូលមកទស្សនាតំបន់សៀមរាប អង្គរ
- ធ្វើរបាយការណ៍សរុប ស្តីពីសកម្មភាពការងាររបស់នាយកដ្ឋានសាមីប្រចាំខែ ត្រីមាស ឆមាស៩ខែ ប្រចាំឆ្នាំ និងរបាយការណ៍ស្តីពីសភាពការណ៍ចាំបាច់បន្ទាន់ យោងតាមរបាយការណ៍ដែលគ្រប់នាយកដ្ឋាន និងអង្គភាពទាំងអស់ ចំណុះអគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរាប្រគល់ឱ្យ ដើម្បីជូនប្រធានអគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរាពិនិត្យ និងចុះហត្ថលេខាផ្ញើជូនរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងធ្វើរបាយការណ៍ស្តីពីស្ថានភាពចំណូល និងចំណាយរបស់អគ្គនាយកដ្ឋានអាជ្ញាធរអប្សរាជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

➢ **នាយកដ្ឋានរមណីយដ្ឋាន និងបុរាណវិទ្យា**

នាយកដ្ឋានរមណីយដ្ឋាន និងបុរាណវិទ្យាស្ថិតក្រោមការទទួលខុសត្រូវរបស់អគ្គនាយករង ០១រូប មានការិយាល័យចំណុះ ០៤គឺ ៖

ការិយាល័យសិក្សា និងការងាររៀបចំ ៖

- ផ្នែកវិធានផែនការ
- ផ្នែកប្រតិបត្តិ
- ក្រុមចល័តផ្នែកព្រៃឈើ

ការិយាល័យសិក្សា និងការងារថែទាំ ៖

- ផ្នែកវិធានផែនការ

- ផ្នែកប្រតិបត្តិ
- ក្រុមចល័តផ្នែកថែទាំ

ការិយាល័យសិក្សា និងការងារបុរាណវិទ្យា ៖

- ផ្នែកវិធានផែនការ
- ផ្នែកប្រតិបត្តិ
- ក្រុមចល័តផ្នែកបុរាណវិទ្យា

ការិយាល័យពហុបច្ចេកទេស ៖

- ផ្នែកការពាររដ្ឋបាលគតិយុត្ត និងការថែរក្សារមណីយដ្ឋានបុរាណវិទ្យា
- ផ្នែករៀបចំឯកសារលិខិតរដ្ឋបាលដើម្បីទប់ស្កាត់អំពើជួញដូរវត្ថុបុរាណខុសច្បាប់
- ផ្នែកសិក្សាវិទ្យាវិស្វកម្ម ។

ជាងនេះទៅទៀត នាយកដ្ឋាននេះបានបែងចែកជា២ គឺ នាយកដ្ឋានរមណីយដ្ឋាន និងបុរាណវិទ្យាទី១ និងនាយកដ្ឋានរមណីយដ្ឋាន និងបុរាណវិទ្យាទី២ ដែលមានតួនាទី និងភារកិច្ចដូចតទៅ[12] ៖

- ធ្វើការទំនាក់ទំនងជាមួយសមាជិកក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា ក្រសួងស្ថាប័នពាក់ព័ន្ធ អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល ដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់សាមីនាយកដ្ឋាន
- ធ្វើផែនការ និងដាក់ឱ្យអនុវត្តនូវការងាររៀបចំផ្សេងៗ នៅក្នុងរមណីយដ្ឋានអង្គរដែលទាក់ទងនិងប្រាសាទ និងទេសភាពនានាដែលមានសារៈសំខាន់ផ្នែកវប្បធម៌
- ធ្វើផែនការមេសម្រាប់ការពារ និងថែរក្សាបរិស្ថានប្រវត្តិសាស្រ្តក្នុងតំបន់ឧទ្យានអង្គរដោយរួមបញ្ចូលទាំងឯកសារស្ថានភាពនៃប្រាសាទនានា និងផែនទីបង្ហាញកន្លែង គ្រោះថ្នាក់
- ថែរក្សាការពារជាប្រចាំយ៉ាងទៀងទាត់ និងយូរអង្វែងចំពោះរមណីយដ្ឋានដែលបានទទួលចំណាត់ថ្នាក់ជាបេតិកភណ្ឌពិភពលោក
- សហការជាមួយនាយកដ្ឋានអភិវឌ្ឍទេសចរណ៍អង្គរ ដោយផ្អែកទៅលើសមត្ថកិច្ចនាយកដ្ឋានជំនាញនីមួយៗដោយយកចិត្តទុកដាក់លើការថែទាំ ការដាក់ផ្លាកសញ្ញា ធ្វើចរាចរ

[12] អនុក្រឹត្យស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា លេខ១៥ អនក្រ.បក, ១១ មិថុនា ២០០៤, មាត្រា៩។

ការដាក់ផ្លាកសញ្ញាផ្សេងៗដែលចាំបាច់ ការរៀបចំចំណតរថយន្ត មធ្យោបាយដឹកជញ្ជូនទេសចរណ៍ ការកំណត់តូប ស្តង់លក់ដូរវត្ថុអនុស្សាវរីយ៍ និងភេសជ្ជៈ ស្នាក់ការប៉ុស្ដិ៍នគរបាលការពារបេតិកភណ្ឌ បង្គន់ និងបន្ទប់ទឹកជាដើម ដើម្បីធានាឱ្យមានសោភណភាពល្អប្រសើរដល់តំបន់សៀមរាបអង្គរ និងបរិវេណនានានៃតំបន់នោះ

- រៀបចំសេចក្ដីព្រាងឯកសារ

ស្ដីពីដីធ្លីដែលស្ថិតនៅក្នុងគម្រោងរៀបចំអភិវឌ្ឍតំបន់សៀមរាប អង្គរ និងតំបន់ពាក់ព័ន្ធផ្សេងទៀតដើម្បីឱ្យគម្រោងអាចអនុវត្តបាន

- រៀបចំផែនការស្ទង់ពិនិត្យមើល និងកំណាយបុរាណវិទ្យា ព្រមទាំងចាត់វិធានការសម្រាប់បង្ការ ឬសង្គ្រោះតាមការចាំបាច់
- បង្កើតក្រុមចល័តដែលមានសមត្ថភាព និងមានឧបករណ៍ សម្ភារៈសមស្របដើម្បីរៀបចំថែទាំ និងតាមដានផ្នែកបុរាណវិទ្យា និងការគ្រប់គ្រងរមណីយដ្ឋាន
- ទទួលបណ្ដុះបណ្ដាលបុរាណវិទូ ស្ថាបត្យករ និងក្រុមអភិរក្សដែលទទួលបន្ទុកការងារនៅតំបន់ឧទ្យានអង្គរ
- គ្រប់គ្រងនិងដឹកនាំឆ្មាំប្រាសាទ កម្លាំងកម្មករសម្អាតឧទ្យាន និងកម្មករជំនាញនានាក្នុងតំបន់រមណីយដ្ឋានអង្គរ
- កំណត់ និងប្រគល់ទីតាំងរៀបចំពិធីផ្សេងៗក្នុងតំបន់អង្គរ និងតាមដានការប្រព្រឹត្តទៅនៃពិធីទាំងនោះ
- គ្រប់គ្រងទឹកដែលពាក់ព័ន្ធផ្ទាល់ និងបេតិកភណ្ឌនានាក្នុងតំបន់អង្គរ
- ធ្វើការសិក្សាវិស្វកម្មវិទ្យា
- ស្រាវជ្រាវកុលាលភាជន៍
- រៀបចំប្លង់ប្រើប្រាស់ដីធ្លីក្នុងតំបន់អង្គរ
- ចុះបញ្ជីសារពើភណ្ឌប្រាសាទទាំងអស់

នៅក្នុងតំបន់អង្គរដែលគឺជាបេតិកភណ្ឌពិភពលោក

- ស្រាវជ្រាវបេតិភណ្ឌរូបិយ និងអរូបិយ
- ត្រួតពិនិត្យ និងឃ្លាំមើលជាប្រចាំលើការសាងសង់សំណង់ ក្នុងរមណីយដ្ឋានអង្គរ (ករណីមានសំណើពង្រីកគេហដ្ឋាន ឬសំណង់ផ្សេងៗចាំបាច់ត្រូវមានប្លង់គំរូ)
- គ្រប់គ្រងប្រព័ន្ធព័ត៌មានភូមិសាស្ត្រ ជីអាយអេស

- ដឹកនាំ និងគ្រប់គ្រងកិច្ចដំណើរការរបស់មណ្ឌលអន្តរជាតិតម្កល់ឯកសារអង្គរ
- ស្តារ និងជួសជុលថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តជាអាទិ៍ ផ្លូវ ស្ពាន លូ និងប្រឡាយក្នុងតំបន់រមណីយដ្ឋានអង្គរ និងរមណីយដ្ឋានផ្សេងៗទៀតដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាជ្ញាធរអប្សរា
- ធ្វើរបាយការណ៍សរុប ស្តីពីសកម្មភាពការងាររបស់នាយកដ្ឋានសាមីប្រចាំខែ ត្រីមាស ឆមាស៩ខែ ប្រចាំឆ្នាំ និងរបាយការណ៍ស្តីពីសភាពការណ៍ចាំបាច់បន្ទាន់ពាក់ព័ន្ធទៅនិងការងាររបស់ខ្លួនជូនប្រធានអគ្គនាយកដ្ឋាន អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា។

ការបែងចែកតួនាទី និងភារកិច្ចរបស់នាយកដ្ឋានរមណីយដ្ឋាន និងបុរាណវិទ្យាទី១ និងនាយកដ្ឋានរមណីយដ្ឋាន និងបុរាណវិទ្យាទី២ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីដែលទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។

➢ **នាយកដ្ឋានវប្បធម៌ និងស្រាវជ្រាវ**

នាយកដ្ឋានវប្បធម៌ និងស្រាវជ្រាវ ស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ប្រធានអគ្គនាយកហើយមានប្រធាននាយកដ្ឋាន០១រូបទៀត គ្រប់គ្រងការិយាល័យចំនួន០៣គឺ ការិយាល័យសិក្សាស្រាវជ្រាវ និងសារពើភណ្ឌរួមមានផ្នែកគ្រប់គ្រងអរូបិយ ផ្នែកគ្រប់គ្រងរូបិយ ផ្នែកគ្រប់គ្រងបរិស្ថាន ផ្នែកគ្រប់គ្រងប្រព័ន្ធពត៌មាន ភូមិសាស្ត្រពាក់ព័ន្ធនឹងអង្គរ ការិយាល័យនិពន្ធ និងផ្សព្វផ្សាយវិទ្យាសាស្ត្រគរុកោសល្យ មាន២ផ្នែកគឺ ផ្នែកនិពន្ធវិទ្យាសាស្ត្រនិងគរុកោសល្យ និងផ្នែកផ្សព្វផ្សាយវប្បធម៌និងស្រាវជ្រាវ និងការិយាល័យមួយទៀតគឺ មណ្ឌលអន្តរជាតិតម្កល់ឯកសារអង្គរ។ ជាងនេះទៅទៀត មណ្ឌលអន្តរជាតិតម្កល់ឯកសារអង្គរមានគោលបំណងរៀបចំឯកសារ ដែលមានលក្ខណៈវិទ្យាសាស្ត្រ វប្បធម៌ និងស្រាវជ្រាវ ដោយការសហការជាមួយអង្គការយូណេស្កូ (UNESCO) ដើម្បីតម្កល់ និងថែរក្សាទុកនូវរាល់ឯកសារទាំងឡាយស្តីពីអង្គរ។ ក្នុងក្របខ័ណ្ឌនេះ មណ្ឌលអន្តរជាតិតម្កល់ឯកសារអង្គរ (C.I.D.A) មានភារកិច្ចប្រមូលរៀបចំ និងថែរក្សាទុកនូវរាល់ឯកសារទាំងឡាយ ដែលរៀបចំដោយអ្នកស្រាវជ្រាវពីបណ្តាស្ថាប័នជាតិ និងអន្តរជាតិ ព្រមទាំងទិន្នន័យនានាដែលទទួលបានពីការគ្រប់គ្រងរូបិយ អរូបិយ និងស្ថាប័ន។ ជាងនេះទៅទៀត មណ្ឌលអន្តរជាតិតម្កល់ឯកសារអង្គរ (C.I.D.A) មានពីរផ្នែកគឺ ផ្នែកបណ្ណាល័យ

និងផ្នែកបណ្ណាឯកសាររបៀបចាត់ចែងការងារ និងដំណើរការងារក្នុងរង្វង់នាយកដ្ឋាន គឺមានការប្រជុំតាមអង្គភាពតិច ឬច្រើនដងក្នុងមួយខែហើយប្រជុំការងារធំ និងលើកយកទិសដៅសម្រាប់អនុវត្តបន្តនាខែខាងមុខ[13]។

- **នាយកដ្ឋាននគរូបនីយកម្ម និងអភិវឌ្ឍតំបន់សៀមរាប អង្គរ**

នាយកដ្ឋាននគរូបនីយកម្ម និងអភិវឌ្ឍក្រុងសៀមរាបអង្គរ ស្ថិតនៅក្រោមការទទួលខុសត្រូវរបស់អគ្គនាយករង១រូប ដែលមានប្រធាននាយកដ្ឋាន១រូប ត្រូវទទួលបន្ទុកគ្រប់គ្រងការិយាល័យចំណុះ៤៖

១. ការិយាល័យសិក្សា និងរៀបចំគម្រោងអភិវឌ្ឍន៍តំបន់សៀមរាបអង្គរ

- ផ្នែកស្ថាបត្យកម្ម នគរូបនីយកម្ម និងបរិស្ថាន
- ផ្នែកហេដ្ឋារចនាសម្ព័ន្ធ

២. ការិយាល័យតាមដានគម្រោងសាងសង់សំណង់

- ផ្នែកសាងសង់
- ផ្នែកចេញលិខិតអនុញ្ញាត

៣. ការិយាល័យប្រតិបត្តិការបច្ចេកទេស

- ផ្នែកប្រតិបត្តិការការដ្ឋាន
- ផ្នែកថែទាំជួសជុល

៤. ការិយាល័យកិច្ចការភូមិបាល

- ផ្នែកតាមដានការដោះស្រាយដីធ្លី
- ផ្នែកប្រតិបត្តិការភូមិបាល

នាយកដ្ឋាននគរូបនីយកម្ម និងអភិវឌ្ឍតំបន់សៀមរាប អង្គរមានតួនាទី និងភារកិច្ចដូចតទៅ[14] ៖

- ធ្វើការទំនាក់ទំនងជាមួយសមាជិកក្រុមប្រឹក្សាភិបាលអាជ្ញាធរអប្សរា ក្រសួងស្ថាប័នដែលពាក់ព័ន្ធ អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលដែលពាក់ព័ន្ធនិងសមត្ថកិច្ចរបស់សាមីនាយកដ្ឋាន

---

[13] គេហទំព័រអ៊ីនធើណិត *អាជ្ញាធរជាតិអប្សរា* (www.apsaraauthority.gov.kh)

[14] អនុក្រឹត្យស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា លេខ១១៥ អនក្រ.បក, ១១ មិថុនា ២០០៥, មាត្រា១១។

- ចូលរួមសហការជាមួយអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលពាក់ព័ន្ធ ដើម្បីធ្វើការគិតគូរ និងលើកផែនការរៀបចំទីក្រុង ដើម្បីអភិវឌ្ឍនូវវិស័យទេសចរណ៍ប្រកបដោយនិរន្តរ-ភាព តុល្យភាព និងសមាហរណកម្មក្នុងតំបន់សៀមរាប អង្គរ ព្រមទាំងតំបន់ពាក់ព័ន្ធផ្សេងទៀត
- រៀបចំគម្រោងប្លង់មេសម្រាប់នគរូបនីយកម្មក្នុងក្រុងសៀមរាប និងកំណត់ទិសដៅសម្រាប់បែបបទប្រើប្រាស់ដីធ្លី និងបទដ្ឋានសម្រាប់សាងសង់នៅតំបន់សៀមរាប អង្គរ ដោយសហការជាមួយអាជ្ញាធរដែនដី មន្ទីរជំនាញពាក់ព័ន្ធរួចដាក់ជូនប្រធាន អគ្គនាយក អគ្គនាយកដ្ឋានអាជ្ញាធរអប្សរាពិនិត្យ និងសម្រេច
- ពិនិត្យ និងផ្ដល់យោបល់លើការចេញលិខិតអនុញ្ញាតឱ្យរុះរើ និងសាងសង់សំណង់នានាសម្រាប់តំបន់ការពារដែលបានកំណត់នៅក្នុងព្រះរាជក្រឹត្យលេខ០០១ /នស ចុះ ថ្ងៃទី ២៨ ខែមេសា ឆ្នាំ១៩៩៤ ស្ដីពីការកំណត់ និងការចាត់ចែងគ្រប់គ្រងតំបន់ សៀមរាប អង្គរ រួចដាក់ជូនប្រធានអគ្គនាយក អគ្គនាយកដ្ឋានអាជ្ញាធរអប្សរាពិនិត្យ និងសម្រេច
- តាមដាន និងការឃ្លាំមើលជាអចិន្ត្រៃយ៍ លើការស្ថាបនាបុរីទេសចរណ៍វប្បធមិអង្គរ ដោយយកចិត្តទុកដាក់លើការអនុវត្តច្បាប់ លិខិតបទដ្ឋាន និងបទប្បញ្ញត្តិផ្សេងៗជា ធរមាន
- ធ្វើរបាយការណ៍សរុប ស្ដីពីសកម្មភាពការងាររបស់នាយកដ្ឋានសាមីប្រចាំខែ ត្រីមាស ឆមាស៩ខែ ប្រចាំឆ្នាំ និងរបាយការណ៍ស្ដីពីសភាពការណ៍ចាំបាច់បន្ទាន់ពាក់ព័ន្ធទៅនិងការងាររបស់ខ្លួនជូនប្រធានអគ្គនាយកដ្ឋាន អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា។

➢ **នាយកដ្ឋានអភិវឌ្ឍទេសចរណ៍អង្គរ**

នាយកដ្ឋានអភិវឌ្ឍទេសចរណ៍អង្គរ ស្ថិតនៅក្រោមការទទួលខុសត្រូវរបស់អគ្គនាយករងមួយរូបជាមួយការិយាល័យចំនួនពីរ គឺការិយាល័យបច្ចេកទេស និងការិយាល័យពាណិជ្ជកម្ម ។ ការិយាល័យទាំងពីរនេះទទួលខុសត្រូវដោយប្រធាននាយកដ្ឋាន។

ការិយាល័យបច្ចេកទេសចែកជា០៣ផ្នែកមាន ៖ ផ្នែកគ្រប់គ្រង និងលើកតម្លៃទេសចរណ៍ និងបរិស្ថានផ្នែកគ្រប់គ្រងមគ្គុទេសក៍ អ្នកប្រកបមុខរបរទេសចរណ៍ ផ្នែកគ្រប់គ្រងការត្រួតពិនិត្យសម្បទាន និងការអនុញ្ញាតិផ្សេងៗ។ ចំណែកឯការិយាល័យពាណិជ្ជកម្មមាន៤ផ្នែកគឺ ផ្នែកផ្សព្វផ្សាយ និងលើកទឹកចិត្ត ផ្នែកទទួលភ្ញៀវទេសចរ ផ្នែកអភិវឌ្ឍសកម្មភាពកំសាន្ត និងផ្នែកផលិតផលបន្ទាប់បន្សំ។

នាយកដ្ឋានអភិវឌ្ឍទេសចរណ៍អង្គរមានតួនាទី និងភារកិច្ចដូចតទៅ[15]៖

- ធ្វើការទំនាក់ទំនងជាមួយសមាជិកក្រុមប្រឹក្សាភិបាលអាជ្ញាធរអប្សរា ក្រសួងស្ថាប័នដែលពាក់ព័ន្ធ អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលដែលពាក់ព័ន្ធនិងសមត្ថកិច្ចរបស់សាមីនាយកដ្ឋាន
- រៀបចំទិសដៅក្នុងការអភិវឌ្ឍវិស័យទេសចរណ៍សម្រាប់រយៈពេលមធ្យម និងរយៈពេលវែងនៅតំបន់សៀមរាប អង្គរ ដោយសហការជាមួយអាជ្ញាធរដែលពាក់ព័ន្ធធ្វើឱ្យស្របទៅនឹងគោលនយោបាយទេសចរណ៍របស់រាជរដ្ឋាភិបាល
- រួមចំណែកនៅក្នុងការលើកតម្លៃរមណីយដ្ឋាន និងប្រាង្គប្រាសាទនានាក្នុងតំបន់សៀមរាបអង្គរ
- រៀបចំវិធានស្តីពីការគ្រប់គ្រងទេសចរណ៍ នៅក្នុងតំបន់ឧទ្យានអង្គរ
- គ្រប់គ្រងពិធីនានាដែលរៀបចំនៅក្នុងតំបន់អង្គរ
- គ្រប់គ្រងផ្ទាល់ការធ្វើអាជីវកម្មនានា ឬតាមដានឃ្លាំមើលជាអចិន្ត្រៃយ៍លើការងារអាជីវកម្មរបស់ក្រុមហ៊ុនសម្បទាននានា ដើម្បីធានាការគ្រប់គ្រងឱ្យមានប្រសិទ្ធិ ភាព
- រកចំណូលផ្សេងៗទៀតដែលបានមកពីការប្រើប្រាស់ទ្រព្យសម្បត្តិរបស់រដ្ឋ និងការលក់ផលិតផលបន្ទាប់បន្សំទាក់ទងនិងរូបភាពអង្គរ
- ឃោសនាផ្សព្វផ្សាយ សិក្សាទីផ្សារ និងផ្តល់ព័ត៌មានសម្រាប់ធ្វើការទាក់ទាញភ្ញៀវទេសចរ ទាក់ទងនិងប្រាង្គប្រាសាទ បរិស្ថានធម្មជាតិ និងវប្បធម៌ក្នុងតំបន់រមណីយដ្ឋានអង្គរ
- ទទួលបណ្តុះបណ្តាល និងបំប៉នវិជ្ជាបន្ថែមដល់មគ្គុទេសក៍ទេសចរណ៍ សម្រាប់រមណីយដ្ឋានអង្គរ
- ធ្វើរបាយការណ៍សរុប ស្តីពីសកម្មភាពការងាររបស់នាយកដ្ឋានសាមីប្រចាំខែ ត្រីមាស ឆមាស៩ខែ ប្រចាំឆ្នាំ និងរបាយការណ៍ស្តីពីសភាពការណ៍ចាំបាច់បន្ទាន់ពាក់ព័ន្ធនិងការងាររបស់ខ្លួន ជូនប្រធានអគ្គនាយក អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា។

➢ **នាយកដ្ឋានប្រជាសាស្ត្រ និងការងារអភិវឌ្ឍ**

នាយកដ្ឋានប្រជាសាស្ត្រ និងការងារអភិវឌ្ឍន៍មានតួនាទី និងភារកិច្ចដូចតទៅ[16]៖

---

[15]អនុក្រឹត្យស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា លេខ១៥ អនក្រ.បក, ១១ មិថុនា ២០០៩, មាត្រា១០។

[16]អនុក្រឹត្យស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា លេខ១៥ អនក្រ.បក, ១១ មិថុនា ២០០៩, មាត្រា១២។

- ធ្វើការទំនាក់ទំនងជាមួយសមាជិកក្រុមប្រឹក្សាភិបាលអាជ្ញាធរអប្សរា ក្រសួងស្ថាប័នដែលពាក់ព័ន្ធ អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលដែលពាក់ព័ន្ធនិងសមត្ថកិច្ចរបស់សាមីនាយកដ្ឋាន
- វិភាគ និងវាយតម្លៃអំពីផលប៉ះពាល់ដែលបណ្តាលមកពីគម្រោងវិនិយោគ និងអភិវឌ្ឍវិស័យទេសចរណ៍ និងការអភិវឌ្ឍន៍ទាំងឡាយក្នុងតំបន់រមណីយដ្ឋានអង្គរ
- រួមចំណែកក្នុងការកំណត់មុខសញ្ញានៃគម្រោងវិនិយោគ អភិវឌ្ឍវិស័យទេសចរ និងការអនុវត្តន៍គម្រោងទាំងនោះសម្រាប់តំបន់សៀមរាប អង្គរ
- ពិនិត្យ និងតាក់តែងកិច្ចសន្យាជាមួយវិនិយោគិន និងសម្បទានិក
- ធ្វើការតាមដាន និងឃ្លាំមើលផ្នែកគតិយុត្តលើការអនុវត្តកិច្ចសន្យាដែលទាក់ទងនិងកិច្ចការវិនិយោគ និងសម្បទាន
- ធ្វើការខិតខំប្រឹងប្រែង ដើម្បីកាត់បន្ថយនូវភាពក្រីក្ររបស់ប្រជាជននៅក្នុងតំបន់សៀមរាប អង្គរ និងតំបន់ពាក់ព័ន្ធផ្សេងទៀត
- តាមដានការប្រែប្រួលនៃកំណើន និងកម្រិតជីវភាពរស់នៅរបស់ប្រជាជន ដើម្បីបង្កើនការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈជូនប្រជាជនក្នុងតំបន់សៀមរាប អង្គរ
- ធ្វើសមាហរណកម្មកសិ-ទេសចរណ៍ ដោយផ្តួចផ្តើមឱ្យមានកសិកម្មបែបជីវសាស្ត្រ និងរៀបចំឱ្យមានខ្សែសង្វាក់ទីផ្សារសម្រាប់ផលិតផលកសិកម្ម
- ធ្វើរបាយការណ៍សរុប ស្តីពីសកម្មភាពការងាររបស់នាយកដ្ឋានសាមីប្រចាំខែ ត្រីមាស ឆមាស៩ខែ ប្រចាំឆ្នាំ និងរបាយការណ៍ស្តីពីសភាពការណ៍ចាំបាច់បន្ទាន់ពាក់ព័ន្ធនិងការងាររបស់ខ្លួន ជូនប្រធានអគ្គនាយក អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា។

➢ **នាយកដ្ឋានទឹក និងព្រៃឈើ**

នាយកដ្ឋានទឹក និងព្រៃឈើ មានតួនាទី និងភារកិច្ចដូចតទៅ[17]៖

- ធ្វើការទំនាក់ទំនងជាមួយសមាជិកក្រុមប្រឹក្សាភិបាលអាជ្ញាធរអប្សរា ក្រសួងស្ថាប័នដែលពាក់ព័ន្ធ អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលដែលពាក់ព័ន្ធនិងសមត្ថកិច្ចរបស់សាមីនាយកដ្ឋាន

[17]អនុក្រឹត្យស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា លេខ១១៥ អនក្រ.បក, ១១ មិថុនា ២០០៩, មាត្រា១៣។

- ធ្វើការគ្រប់គ្រងទឹកទាំងបរិមាណ និងគុណភាពនៅក្នុងតំបន់សៀមរាប អង្គរ និងតំបន់ដែលពាក់ព័ន្ធផ្សេងទៀត
- សិក្សាអំពីរុក្ខជាតិ និងជីវិតសត្វនៅក្នុងតំបន់សៀមរាប អង្គរ និងនៅបឹងទន្លេសាប
- ធ្វើការគ្រប់គ្រងព្រៃឈើក្នុងឧទ្យានអង្គរ និងឧទ្យានផ្សេងទៀត ដែលស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរារួមមានការអភិរក្ស ថែរក្សា និងការដាំដើមឈើឡើងវិញ
- ធ្វើការសិក្សាអំពីបរិស្ថាន បរិយាកាស និងអាកាសធាតុដោយរៀបចំឱ្យមានសំណាង់ឧតុនិយមអាកាសធាតុ និងប្រមែប្រមូលទិន្នន័យដែលមានស្រាប់ក្នុងតំបន់តាមដានការប្រែប្រួលអាកាសធាតុឥទ្ធិពលដែលមានទៅលើជលសាស្ត្រនិងកសិកម្ម និងការបំពុលបរិស្ថាន ការបំពុលទឹក ការបំពុលខ្យល់ ព្រមទាំងការរំខានដោយសម្លេង
- ធ្វើការរៀបចំ និងអនុវត្តគម្រោង ISO 14001 សម្រាប់អាជ្ញាធរអប្សរា
- ធ្វើការសិក្សាដីសម្រាប់កសិកម្ម និងព្រៃឈើដើម្បីប្រើប្រាស់ឱ្យសមស្របតាមគុណភាពប្រភេទដីនីមួយៗក្នុងតំបន់សៀមរាប អង្គរ
- ធ្វើការសិក្សាអំពីការអភិវឌ្ឍប្រកបដោយនិរន្តភាព ដោយសហការសិក្សារួមគ្នាជាមួយនាយកដ្ឋានជំនាញនានាទៅលើផ្នែកខាងលើដីនិងក្រោមដី អាកាសធាតុ រុក្ខជាតិ និងប្រាសាទនានា
- ធ្វើរបាយការណ៍សរុប ស្តីពីសកម្មភាពការងាររបស់នាយកដ្ឋានសាមីប្រចាំខែ ត្រីមាស ឆមាស៩ខែ ប្រចាំឆ្នាំ និងរបាយការណ៍ស្តីពីសភាពការណ៍ចាំបាច់បន្ទាន់ពាក់ព័ន្ធនិងការងាររបស់ខ្លួន ជូនប្រធានអគ្គនាយក អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា។

➢ **អង្គភាពអន្តរាគមន៍ចំរុះបង្ក្រាបបទល្មើសព្រៃឈើ គ្រប់គ្រងដីធ្លី និងទប់ស្កាត់អំពើអនាធិបតេយ្យនៅតំបន់សៀមរាប អង្គរ**

អង្គភាពអន្តរាគមន៍ចំរុះបង្ក្រាបបទល្មើសព្រៃឈើ គ្រប់គ្រងដីធ្លី និងទប់ស្កាត់អំពើអនាធិបតេយ្យនៅតំបន់សៀមរាប អង្គរ មានតួនាទី និងភារកិច្ចដូចតទៅ[18]៖

- សហការជាមួយនាយកដ្ឋាននានារបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា ដើម្បីក្តាប់បានផែនទីប្លង់មេនៃតំបន់ទាំង៥ ដែលគ្រប់គ្រងដោយអគ្គនាយកដ្ឋានអាជ្ញាធរអប្សរា ហើយលើកផែនការ និងវិធានការក្នុងការចាត់ចែងកម្លាំងឱ្យការពារនៅតាមគោលដៅដែលបានកំណត់
- ក្តាប់សភាពការណ៍ និងស្រាវជ្រាវរកឱ្យឃើញនូវបទល្មើសដែលបម្រុងកើត ឬកើតឡើងភ្លាមៗលើការកាប់បំផ្លាញព្រៃឈើ ការរុករានដីព្រៃព័ទ្ធរបង និងការសាងសង់សំណង់នានា ដែលគ្មានលិខិតអនុញ្ញាតស្របច្បាប់ក្នុងតំបន់ត្រូវការដែលអគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរាបានកំណត់ឱ្យហើយលើកវិធានការចាត់តាំងកម្លាំងចុះដោះស្រាយ និងបង្ក្រាបជាបន្ទាន់ មិនឱ្យបាតុភាព ឬអំពើល្មើសនោះរីករាលដាលបានឡើយ។

### ១.២.២ ៖ ធនធាន និងហិរញ្ញវត្ថុរបស់អាជ្ញាធរអប្សរា

នៅរាល់គ្រប់ស្ថាប័នទាំងអស់មិនថាស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាល ឬមិនស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលនោះទេ សុទ្ធសឹងតែមានប្រភពធនធានរបស់ខ្លួនដើម្បីទ្រទ្រង់ស្ថាប័នរបស់ខ្លួន ឱ្យមានដំណើរការទៅមុខ។ ប្រភពចំណូលរបស់អាជ្ញាធរអប្សរាចែកចេញជា២ គឺ ប្រភពចំណូលទូទៅ និងប្រភពចំណូលដោយឡែក។

- **ប្រភពចំណូលទូទៅ**

ដោយសារតែអាជ្ញាធរអប្សរាគឺជាគ្រឹះស្ថានសាធារណៈដែលមានលក្ខណៈរដ្ឋបាល ដូចនេះ អាជ្ញាធរនេះត្រូវមានប្រភពចំណូលទូទៅមួយ ដែលត្រូវកំណត់ដោយព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល។ ប្រភពចំណូលទូទៅនោះរួមមាន ៖

- ធនធានដែលរដ្ឋផ្តល់ដល់គ្រឹះស្ថានដំបូង ពេលចាប់ផ្តើមបង្កើត។
- ការផ្ទេរក្នុងលក្ខណៈជាអន្តរាគមន៍សាធារណៈដែលមានចែងនៅក្នុងថវិការដ្ឋ ដូចជា ឧបត្ថម្ភធនសម្រាប់ដំណើរការ និង ឧបត្ថម្ភធនជាមូលធន។

---

[18]អនុក្រឹត្យស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា លេខ១១៥ អនក្រ.បក, ១១ មិថុនា ២០០៤, មាត្រា១៤។

- អាករដែលសហគ្រាសមានសិទ្ធិទទួលយកដោយផ្ទាល់ ហើយត្រូវបានគ្រោងដោយអនុក្រឹត្យស្តីពីការបង្កើតគ្រឹះស្ថាននេះ។
- ការផ្ទេរពន្ធ និងអាករចូលទៅក្នុងប្រាក់ចំណេញរបស់គ្រឹះស្ថានដែលចែងដោយច្បាប់ហិរញ្ញវត្ថុ។
- អំណោយ ឬអច្ច័យទានដែលគ្រឹះស្ថានបានទទួល។
- ផលនៃការងារ និងផ្តល់សេវាសម្រេច ឬផ្តល់ដោយគ្រឹះស្ថាន។
- កម្រៃនៃទ្រព្យសម្បត្តិរបស់គ្រឹះស្ថាន និងប្រាក់ចំណូលនៃការលក់ទ្រព្យសម្បត្តិទាំងនោះ។
- កម្រៃនៃទ្រព្យសម្បត្តិដែលបានប្រគល់ឱ្យគ្រឹះស្ថាន។

❖ **ប្រភពចំណូលដោយឡែក**

ក្រៅពីប្រភពចំណូលខាងលើ អាជ្ញាធរអប្សរាក៏មានប្រភពចំណូលដោយឡែកមួយទៀត ដែលកំណត់ដោយព្រះរាជក្រឹត្យ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថា**អាជ្ញាធរអប្សរា** និងត្រូវបានកែសម្រួលដោយព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ប្រភពចំណូលដែលកំណត់ដោយឡែកនេះរួមមាន[19]៖

- ការចូលទស្សនាប្រាសាទដែលស្ថិតក្នុងបរិវេណតំបន់១ ដូចមានចែងក្នុងមាត្រា៣ នៃព្រះរាជក្រឹត្យលេខ ០១/នស ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៥។
- កម្រៃបានមកពីអាជីវកម្មថតរូប ឬថតខ្សែភាពយន្តក្នុងបរិវេណតំបន់នោះ។
- ពិធីសិល្បៈ ពិធីវប្បធម៌ និងពិធីផ្សេងៗទៀត ដែលចាត់ចែងដោយអាជ្ញាធរអប្សរា ឬដោយតតិយជនដែលបានទទួលការអនុញ្ញាតពីអាជ្ញាធរជាតិអប្សរា។
- សម្បទាន ការជួល ឬការអនុញ្ញាតឱ្យប្រើដីធ្លីដែលប្រគល់ដោយអាជ្ញាធរអប្សរា។
- ប្រាក់ខ្ចីបុល ដែលធ្វើឡើងតាមការយល់ព្រមពីក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរអប្សរាអាចទទួលយកនូវទ្រព្យចលនវត្ថុ អចលនវត្ថុ ឬដីដែលគេប្រគល់ឱ្យ។
- អំណោយដែលបានមកពីមរតក និងវិភាគទានអន្តរជាតិដោយមានការយល់ព្រមពីក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរអប្សរា។

ចំពោះការគ្រប់គ្រងហិរញ្ញវត្ថុនៃអាជ្ញាធរជាតិអប្សរា គឺជាភារកិច្ចរបស់ប្រធាននាយកដ្ឋានហិរញ្ញកិច្ច និងគណនេយ្យ១រូបដែលតែងតាំងឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

[19] ព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨, ២២ មករា ១៩៩៩, មាត្រា៧។

មន្ត្រីរូបនេះដែលជាអ្នកទទួលខុសត្រូវក្នុងការគ្រប់គ្រងមូលនិធិនេះ ព្រមទាំងជាអ្នកកាន់បញ្ជីសារពើភណ្ឌរបស់ អាជ្ញាធរអប្សរា ត្រូវធ្វើសម្បថមុននឹងចូលកាន់តំណែង[20]។

ការត្រួតពិនិត្យគណនេយ្យ ត្រូវប្រគល់ឱ្យស្នងការគណនេយ្យ១រូប ដែលតែងតាំងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ស្នងការគណនេយ្យទទួលអំណាចផ្ទៀងផ្ទាត់បញ្ជីបេឡាត្រួតពិនិត្យភាពប្រក្រតីនៃគុល្យការផ្សេងៗ ព្រមទាំងភាពត្រឹមត្រូវនៃគណនេយ្យ។ ស្នងការគណនេយ្យអាចធ្វើការផ្ទៀងផ្ទាត់ និងត្រួតពិនិត្យរាល់ពេលដែលខ្លួនយល់ថាចាំបាច់។

រាល់ពេលប្រជុំក្រុមប្រឹក្សាភិបាល ស្នងការគណនេយ្យធ្វើរបាយការណ៍អំពីការងារដែលខ្លួនបានធ្វើកន្លងមក។ ប្រសិនបើខ្លួនសង្កេតឃើញមានភាពមិនប្រក្រតី និងមិនទៀងទាត់ស្នងការគណ-នេយ្យត្រូវជម្រាបជូនអង្គប្រជុំ ព្រមទាំងបញ្ចេញយោបល់លើស្ថានភាពហិរញ្ញវត្ថុនោះ។

បើមានករណីបន្ទាន់ ស្នងការគណនេយ្យអាចសុំសហប្រធានក្រុមប្រឹក្សាភិបាលឱ្យកោះហៅអញ្ជើញក្រុមប្រឹក្សាភិបាល។ ស្នងការគណនេយ្យពុំឃើញមានភាពមិនប្រក្រតីក្នុងការគ្រប់គ្រងហិរញ្ញវត្ថុនោះ ស្នងការគណនេយ្យត្រូវប្រគល់បុញ្ញកិច្ចដល់ក្រុមប្រឹក្សាភិបាលអគ្គនាយក និងនាយកហិរញ្ញវត្ថុគណនេយ្យនៃអាជ្ញាធរអប្សរា[21]។

បន្ទាប់ពីបានយល់ដឹងពីទិដ្ឋភាពទូទៅ រួចរាល់ហើយនោះ ជាបន្ទាប់មកទៀតយើងនិងចូលដល់ចំណុចសំខាន់មួយទៀតគឺ៖

[20]ព្រះរាជក្រឹត្យ ស្តីពីការបង្កើតអាជ្ញាធរអប្សរាដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថា អាជ្ញាធរ "អប្សរា" លេខ នស/រកត/០២៩៥/១២, ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥, មាត្រា១៤។

[21]ព្រះរាជក្រឹត្យស្តីពីការបង្កើតអាជ្ញាធរអប្សរាដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថា អាជ្ញាធរ "អប្សរា", លេខ នស/រកត/០២៩៥/១២, ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥, មាត្រា១៥។

# ជំពូកទី២៖

# តួនាទី និងភារកិច្ច

អាជ្ញាធរជាតិអប្សរា ដែលហៅថាអាជ្ញាធរជាតិដើម្បីការពារ និងរៀបចំតបន់អង្គរ គឺជាគ្រឹះស្ថានសាធារណៈមួយ ដែលមានលក្ខណៈរដ្ឋបាលស្របតាមព្រះរាជក្រឹត្យលេខ នស ០២៩៥/១២ ចុះនៅរាជធានីភ្នំពេញថ្ងៃទី ១៩ កម្ភៈ ១៩៩៥ ដើម្បីធ្វើការរួមចំណែកជួយដល់កិច្ចការរបស់រាជរដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា សម្រាប់វិស័យនគរូបនីយកម្មនៅតំបន់អង្គរ។ នេះបញ្ជាក់ថា អាជ្ញាធរអប្សរាពិតជាមាន **បេសកកម្ម និងសមិទ្ធផលរបស់អាជ្ញាធរអប្សរា**(២.១) ដែលវានាំឱ្យមាននូវ **បញ្ហាប្រឈម និងដំណោះស្រាយ**(២.២)។

## ២.១ បេសកកម្ម និងសមិទ្ធផល

ឆ្លងកាត់ការបង្កើតអស់រយៈពេលជាច្រើនឆ្នាំកន្លងមក យើងឃើញថាអាជ្ញាធរបានធ្វើសកម្មភាពជាច្រើន នៅក្នុងគោលដៅមួយយ៉ាងជាក់លាក់ដែលស្របទៅតាមការដឹកនាំរបស់រដ្ឋាភិបាល ។ ដើម្បីឱ្យកាន់តែច្បាស់យើងនិងសិក្សាទៅលើ **បេសកកម្ម**(២.១.១) ហើយនិង **សមិទ្ធផល**(២.១.២) របស់អាជ្ញាធរនេះ។

### ២.១.១ បេសកកម្ម

ចំពោះបេសកកម្ម តួនាទីក៏ដូចជាភារកិច្ចរបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរជាតិអប្សរាមានកំណត់ និងចែងនៅក្នុងអនុក្រឹត្យលេខ ១៥ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា។

អគ្គនាយកដ្ឋាននៃអាជ្ញាធរជាតិអប្សរា មានបេសកកម្មដូចតទៅ[22]៖

[22] អនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាន នៃអាជ្ញាធរអប្សរា, លេខ១៥ អនក្រ.បក, ១១ មិថុនា ២០០៤, មាត្រា២។

- ការពារថែរក្សា អភិរក្ស និងលើកតម្លៃបុរាណវិទ្យា វប្បធម៌ បរិស្ថាន និងប្រវត្តិសាស្ត្រនៃរមណីយដ្ឋានអង្គរដែលជាបេតិកភ័ណ្ឌពិភពលោក។
- សិក្សា និងអនុវត្តឱ្យបានសម្រេចនូវផែនការ និងកម្មវិធីរៀបចំអភិវឌ្ឍទេសចរណ៍ប្រកបដោយចីរភាពក្នុងតំបន់ទាំងប្រាំ ដែលបានកំណត់ដោយបញ្ញត្តិនៃព្រះរាជក្រឹត្យលេខ ០០១/នស ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ១៩៩៤ ស្តីពីការកំណត់ និងចាត់ចែងតំបន់សៀមរាប អង្គរ ព្រមទាំងទប់ស្កាត់បទល្មើសព្រៃឈើ ការគ្រប់គ្រងដីធ្លី និងទប់ស្កាត់អំពើអនាធិបតេយ្យនៅក្នុងតំបន់សៀមរាប អង្គរ។
- ស្វែងរក និងវាយតម្លៃប្រភពហិរញ្ញប្បទាន និងទុនវិនិយោគ ដើម្បីធ្វើឱ្យសម្រេចនូវរាល់ការងារ និងកម្មវិធីរៀបចំអភិវឌ្ឍទេសចរណ៍ដែលបានរៀបរាប់ខាងលើ។
- រួមចំណែកនៅក្នុងការអនុវត្តគោលនយោបាយ កាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល នៅក្នុងតំបន់សៀមរាប អង្គរ។
- ចូលរួមធ្វើការសហការជាមួយនិងក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា ដើម្បីផ្តល់ការអនុញ្ញាតឱ្យវិនិយោគនូវគម្រោងការទាំងឡាយណាដែលទាក់ទងទៅនឹងបេសកកម្មរបស់អាជ្ញាធរជាតិអប្សរានេះ។
- បង្កើតភាពជាដៃគូជាមួយអាជ្ញាធរខេត្ត និងអាជ្ញាធរដែនដី។
- សហការជាមួយអង្គការ មូលនិធិ និងស្ថាប័នជាតិ និងអន្តរជាតិនានាដែលមានគោលដៅដូចគ្នាទៅនឹងការងាររបស់អាជ្ញាធរជាតិអប្សរា ហើយដែលកំពុងប្រតិបត្តិការនៅក្នុងតំបន់សៀមរាប-អង្គរ។

ជាងនេះទៅទៀត ដើម្បីបំពេញបេសកកម្ម និងធ្វើការសម្រេចគោលដៅរបស់ខ្លួននៅក្នុងក្របខ័ណ្ឌកម្មវិធីប្រចាំឆ្នាំ សម្រាប់រយៈពេលកំណត់នីមួយៗអាជ្ញាធរជាតិអប្សរាត្រូវបំពេញភារកិច្ចដូចតទៅ[23]៖

- គិតគូរ និងចាត់ចែងអនុវត្តនូវរាល់ផែនការសម្រាប់រយៈពេលមធ្យម និងរយៈពេលវែងលើការថែរក្សា និងការពារប្រាសាទនានាក្នុងតំបន់សៀមរាបអង្គរ និងតំបន់ពាក់ព័ន្ធផ្សេងទៀតដែលរាជរដ្ឋាភិបាលប្រគល់ឱ្យ។
- ធ្វើអន្តរាគមចាំបាច់ និងបន្ទាន់ដើម្បីធានាកិច្ចការពារ និងស្រោចស្រង់រមណីយដ្ឋានអង្គរ។

[23]អនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាន នៃអាជ្ញាធរអប្សរា, លេខ១៥ អនក្រ.បក, ១១ មិថុនា ២០០៩, មាត្រា៣។

- បង្កើតឱ្យមានអង្គភាពដើម្បីបង្ការថែរក្សាការពារ ឬគ្រប់គ្រងប្រាសាទនានារួមទាំងទេសភាពបរិស្ថានដែលនៅជុំវិញប្រាសាទទាំងនេះ។
- ធ្វើការស្ទង់មើល និងធ្វើកំណាយបុរាណវិទ្យា។
- រួមចំណែកបង្កើនចំណេះដឹង និងការស្រាវជ្រាវអំពីវប្បធម៌ខ្មែរទាំងផ្នែករូបី និងអរូបី។
- ធ្វើការសិក្សា ដើម្បីបង្កើនបរិមាណធនធានទឹក និងរៀបចំការកសាងនូវហេដ្ឋារចនាសម្ព័ន្ធរូបវន្តចាំបាច់សំដៅធានានិរន្តរភាពនៃធនធានទឹក។
- រៀបចំដាំដើមឈើឡើងវិញ ដែលអាចធ្វើបាននៅក្នុងឧទ្យានអង្គរក៏ដូចជានៅក្នុងតំបន់សៀមរាប ជាពិសេសបង្កើតសួនច្បារ និងថ្នាលបណ្តុះកូនឈើដើម្បីការពារបរិស្ថាន និងទេសភាពវប្បធម៌។
- គិតគូរ និងចាត់ចែងអនុវត្តនូវរាល់ផែនការសម្រាប់រយៈពេលមធ្យម និងរយៈពេលវែងនៅក្នុងគោលបំណងលើកតម្លៃជំរុញការផ្សព្វផ្សាយ និងគ្រប់គ្រងពាណិជ្ជកម្មនៃតំបន់ឧទ្យាន អង្គរ។
- សហការជាមួយអាជ្ញាធរជាតិ និងអាជ្ញាធរមូលដ្ឋានដើម្បីធ្វើការបណ្តុះបណ្តាលមគ្គុទេសក៍ទេសចរណ៍ និងផ្តល់ពត៌មានដល់ភ្នាក់ងារ និងអ្នកប្រកបមុខរបរទេសចរណ៍។
- ធានាការគ្រប់គ្រងកម្រៃបានមកពីការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ ដោយអនុលោមតាមបទបញ្ញត្តិជាតិ និងវិធានអន្តរជាតិនានា។
- សហការជាមួយអាជ្ញាធរជាតិ និងអាជ្ញាធរមូលដ្ឋាន ដើម្បីរៀបចំអភិវឌ្ឍក្រុងសៀមរាបឱ្យបានល្អប្រសើរ និងមានភាពសមរម្យដោយអនុលោមតាមបទប្បញ្ញត្តិជាធរមានព្រមទាំងការយកចិត្តទុកដាក់ពីផលប៉ះពាល់ទៅលើបរិស្ថានដែលបណ្តាលមកពីកំណើនប្រជាពលរដ្ឋ និងបទប្បញ្ញត្តិជាតិ និងអន្តរជាតិស្តីពីការអភិវឌ្ឍន៍វិស័យទេសចរណ៍ផង។
- ធ្វើការសិក្សាអំពីផលប៉ះពាល់ និងវាយតម្លៃទៅលើគម្រោងវិនិយោគវិស័យទេសចរណ៍ ព្រមទាំងធ្វើការតាមដានតាមរយៈនៃការរៀបចំព្យាករណ៍ជាប្រចាំ សម្រាប់រយៈដែលបានពេលកំណត់នីមួយៗ។

- កំណត់ជ្រើសរើស និងចាត់ចែងអនុវត្តនូវគម្រោងវិនិយោគវិស័យទេសចរណ៍ ដោយអនុលោមតាមបទប្បញ្ញត្តិច្បាប់ និងវិធាននានាជាធរមាន។
- រៀបចំកិច្ចសន្យាជាមួយវិនិយោគិន និងសម្បទានិកព្រមទាំងធ្វើការដោះស្រាយរាល់កិច្ចការវិវាទទាំងឡាយដោយអនុលោមតាមច្បាប់លិខិតបទដ្ឋាន បទប្បញ្ញត្តិជាធរមាន និងវិធានអន្តរជាតិនានា។
- រួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជននៅក្នុងតំបន់សៀមរាប អង្គរដោយបង្កើនការងារ និងជំរុញកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និងពង្រឹងសមត្ថភាពបំរើការងាររបស់ប្រជាជននៅតំបន់នេះ និងតំបន់ផ្សេងៗទៀតដែលពាក់ព័ន្ធ។
- ជួយណែនាំប្រជាពលរដ្ឋក្នុងឧទ្យានឱ្យចេះការពារថែរក្សាលំនៅដ្ឋាន និងអាគារសាសនាតាមរចនាបថប្រពៃណីខ្មែរ ដោយជួយលើកកម្ពស់ជីវភាពប្រជាពលរដ្ឋទាំងនោះ។
- ធានានូវកិច្ចការពាររាល់សំណង់បុរាណនៅក្នុងតំបន់សៀមរាប អង្គរ រួមមានវត្ថុដែលមានលក្ខណៈប្រវត្តិសាស្ត្រដូចជា លំនៅដ្ឋានបុរាណ និងរាល់សំណង់ស្ថាបត្យកម្មបុរាណដែលមានតម្លៃបេតិកភណ្ឌ។
- ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការផ្នែកវិទ្យាសាស្ត្របច្ចេកវិទ្យាដែលផ្តល់ការរីកចំរើនដល់រមណីយដ្ឋានអង្គរ ប្រាសាទព្រមទាំងបរិស្ថាន ដោយអនុលោមតាមគោលនយោបាយស្តីពីកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់រាជរដ្ឋាភិបាល។
- រៀបចំប្រព័ន្ធគ្រប់គ្រង ត្រួតពិនិត្យគុណភាពនៃការធ្វើអាជីវកម្មពាណិជ្ជកម្ម និងសេវាកម្មនានាក្នុងតំបន់គោលដៅការពារបរិស្ថាន និងអភិវឌ្ឍប្រកបដោយចីរភាពក្នុងតំបន់សៀមរាប អង្គរ និងតំបន់ពាក់ព័ន្ធផ្សេងៗទៀត។
- អភិវឌ្ឍកិច្ចប្រតិបត្តិការផ្នែកវិទ្យាសាស្ត្របច្ចេកទេស ជាគុណប្រយោជន៍ដល់រមណីយដ្ឋានអង្គរ ប្រាង្គប្រាសាទព្រមទាំងបរិស្ថានជុំវិញ ដោយអនុលោមតាមគោលនយោបាយជាតិ ស្តីពីកិច្ចសហប្រតិបត្តិការអន្តរជាតិ។
- ធ្វើការបោះពុម្ព និងផ្សព្វផ្សាយឯកសារ និងរបាយការណ៍វិទ្យាសាស្ត្របច្ចេកទេស និងព្រមទាំងវប្បធម៌។

- ធ្វើរបាយការណ៍ស្តីពីសកម្មភាពរបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា ប្រចាំខែ ប្រចាំត្រីមាស៩ខែ និងប្រចាំឆ្នាំ និងសភាពការណ៍បន្ទាន់ ព្រមទាំងវិធានការនានារបស់អាជ្ញាធរអប្សរាជូនរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ[24]។

ដើម្បីសម្រេចនូវបេសកកម្មរបស់ខ្លួនអាជ្ញាធរជាតិអប្សរា ត្រូវកំណត់ឱ្យមានសៀវភៅបន្ទុកសម្រាប់អង្គការនានាដែលពាក់ព័ន្ធដល់ការគ្រប់គ្រងរមណីយដ្ឋាន និងការរៀបចំតំបន់អង្គរ។ ក្នុងន័យនេះអាជ្ញាធរជាតិអប្សរាអាចៈ

- ចុះកិច្ចសន្យា អំពីកម្មវិធីប្រចាំឆ្នាំជាមួយអង្គការទាំងឡាយដែលមានគោលការណ៍អភិវឌ្ឍតំបន់អង្គរ ។
- ចុះកិច្ចសន្យាជាមួយនិងអាជ្ញាធរខេត្ត ដែលមានគោលបំណងធ្វើការរៀបចំនគរូបនីយកម្ម ការអភិវឌ្ឍន៍ជនបទ និងផ្តល់សេវាផ្សេងៗជាយថាហេតុ។
- សហការជាមួយគ្រប់វិទ្យាស្ថាន គ្រប់អង្គការផ្សេងៗ គ្រប់មូលនិធិ និងសហាគមន៍ខ្មែរបរទេស និងអន្តរជាតិដែលដើរតាមទិសដៅឆ្លើយតបនឹងសមត្ថកិច្ចអាជ្ញាធរអប្សរា។
- សហការជាមួយក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា ក្នុងរឿងវិនិយោគគ្រប់ប្រភេទណាដែលមានការពាក់ព័ន្ធជាមួយបេសកកម្មរបស់អាជ្ញាធរអប្សរា។
- ប្រគល់សិទ្ធិធ្វើសកម្មភាពផ្សេងៗ ឬចេញច្បាប់អនុញ្ញាតកាន់កាប់ផ្តល់ការជួលដីរដ្ឋឱ្យអ្នកវិនិយោគក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់អាជ្ញាធរអប្សរា។
- ទទួលការងារពិធីការ និងរៀបចំមគ្គុទេសក៍សម្រាប់ទទួលគណៈប្រតិភូជាន់ខ្ពស់ជាតិ និងអន្តរជាតិ ដែលចូលមកទស្សនាតំបន់រមណីយដ្ឋានអង្គរ។

លើសពីនេះទៅទៀត រាជរដ្ឋាភិបាលកម្ពុជា ក៏បានចេញនូវសេចក្តីសម្រេចជាច្រើនជាបន្តបន្ទាប់ ដើម្បីធ្វើឱ្យអាជ្ញាធរជាតិអប្សរាបានបំពេញភារកិច្ចចំនួន ៣បន្ថែមទៀតរួមមានៈ

- **ភារកិច្ចទី១** ៖ គឺអាជ្ញាធរជាតិអប្សរា ត្រូវជានាវ៉ាប់រងនៅក្នុងករណីពិសេសនៃតំបន់រមណីយដ្ឋានសៀមរាបអង្គរ ដោយធ្វើការការពារ ការអភិរក្ស និងលើកតម្លៃនូវសម្បត្តិវប្បធម៌ជាតិ។

[24]អនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាន នៃអាជ្ញាធរអប្សរា, លេខ១៥ អនក្រ.បក, ១១ មិថុនា ២០០៤, មាត្រា៣។

- **ភារកិច្ចទី២** ៖ ទទួល និងដឹកនាំការងាររៀបចំ និងការអភិវឌ្ឍន៍នូវវិស័យទេសចរណ៍នៅក្នុងតំបន់ទាំង៥ នៃខេត្តសៀមរាបទាំងមូល។

❖ រមណីយដ្ឋានមានប្រាសាទ

គឺតំបន់នានាដែលមានស្ថានីយ៍បុរាណវត្ថុសំខាន់ៗជាងគេនៅក្នុងប្រទេសយើង ហើយត្រូវទទួលកិច្ចការពារកម្រិតខ្ពស់បំផុត។ ធម្មតាតំបន់ទាំងនេះមានទំហំតូចតែចំពោះអង្គរវិញ ទោះមានផ្ទៃធំធេងនោះក៏ត្រូវចាត់ចែងការពារចូលក្នុងកម្រិតខ្ពស់បំផុតនេះដែរ ដោយតំបន់នេះមានប្រាសាទ និងសំណង់បុរាណវត្ថុច្រើន[25]។

❖ ឧទ្យានបុរាណវត្ថុត្រូវការពារ

គឺតំបន់សំបូរសំណល់វត្ថុបុរាណដែលត្រូវការពារទប់ទល់ និងការប្រើប្រាស់ដីធ្លីផ្ដេសផ្ដាស និងអភិវឌ្ឍមិនសមស្រប។ ធម្មតាតំបន់ទាំងនេះស្ថិតនៅជុំវិញរមណីយដ្ឋានមានប្រាសាទ។ តំបន់ទាំងនេះច្រើនមានបុរាណវត្ថុបង្កប់ក្នុងទីនោះ។ តំបន់នេះមានសារៈសំខាន់ចម្បងដោយសារតំបន់ទ្រនាប់សម្រាប់ការពាររមណីយដ្ឋានមានប្រាសាទ[26]។

❖ ទេសភាពវប្បធម៌ត្រូវការពារ

គឺតំបន់ដែលមានលក្ខណៈជាទេសភាពត្រូវការពារដោយហេតុថា តំបន់នេះមានទិដ្ឋភាពបរមបុរាណ។ លើសពីនេះទៅទៀត បែបបទប្រើប្រាស់ដីធ្លី សំណង់លំនៅដ្ឋាន អាគារប្រវត្តិសាស្ត្រនៅទីនោះដែលជាកេរ្តិ៍ដំណែលដ៏យូរលង់ ផ្ដល់តម្លៃវប្បធម៌ខ្ពស់ ឆ្លុះបញ្ចាំងឱ្យឃើញជីវភាពរស់នៅពីអតីតកាល។ ទេសភាពវប្បធម៌នេះជាមធ្យោបាយរក្សាទស្សនៈវិស័យ ព្រមទាំងទំនាក់ទំនងរវាងទិដ្ឋភាពលេចធ្លោនានា។ ទេសភាពវប្បធម៌ត្រូវការពារនេះ ត្រូវមានការគ្រប់គ្រងដោយច្បាប់ទម្លាប់ទប់ទល់នឹងសកម្មភាពបំផ្លិចបំផ្លាញ[27]។

❖ ចំណុចមានសារៈសំខាន់ផ្នែកបុរាណវត្ថុវិទ្យា នរវិទ្យា ឬប្រវត្តិវិទ្យា

---

[25] ព្រះរាជក្រឹត្យស្ដីពីការកំណត់ និងការចាត់ចែងគ្រប់គ្រងតំបន់សៀមរាប អង្គរ, លេខ ០០១ ន.ស, ២៨ ឧសភា ១៩៩៩, មាត្រា៣។

[26] ព្រះរាជក្រឹត្យស្ដីពីការកំណត់ និងការចាត់ចែងគ្រប់គ្រងតំបន់សៀមរាប អង្គរ, លេខ ០០១ ន.ស, ២៨ ឧសភា ១៩៩៩, មាត្រា៤។

[27] ព្រះរាជក្រឹត្យស្ដីពីការកំណត់ និងការចាត់ចែងគ្រប់គ្រងតំបន់សៀមរាប អង្គរ, លេខ ០០១ ន.ស, ២៨ ឧសភា ១៩៩៩, មាត្រា៥។

គឺតំបន់ផ្សេងៗទៀតដែលមានប្រយោជន៍ខាងបុរាណវិទ្យា តែមានសារៈសំខាន់កម្រិតទាបជាងរមណីយដ្ឋានមានប្រាសាទ។ តំបន់នេះត្រូវរក្សាការពារដើម្បីជាប្រយោជន៍ដល់ការស្រាវជ្រាវការអប់រំ ឬទេសចរណ៍។ កិច្ចការពារ និងច្បាប់ទម្លាប់គ្រប់គ្រងត្រូវមានកម្រិតដូចគ្នានឹងឧទ្យានបុរាណវត្ថុដែរ[28]។

❖ បរិវេណអភិវឌ្ឍសង្គមកិច្ច និងវប្បធម៌នៃតំបន់សៀមរាប អង្គរ

បរិវេណនេះគ្របដណ្តប់ខេត្តសៀមរាបទាំងមូល។ ក្នុងគោលដៅថែរក្សាបេតិកភណ្ឌវប្បធម៌ និងធម្មជាតិត្រូវចាត់ចែងវិធានការ ដើម្បីជំរុញការអភិវឌ្ឍន៍ស្ថិតស្ថេរមួយ និងវិធានការគណនាផលប៉ះពាល់លើបរិស្ថាន[29]។

- ✓ ស្វែងរក និងវាយតម្លៃអំពីប្រភពហិរញ្ញវត្ថុ និងវិនិយោគដើម្បីឱ្យបានសម្រេចនូវការងារដែលបានរៀបរាប់ខាងលើក្នុងកម្មវិធីរៀបចំ និងការអភិវឌ្ឍន៍ទេសចរណ៍។
- ✓ ធ្វើការរួមចំណែកនៅក្នុងការអនុវត្តន៍គោលនយោបាយ កាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលនៅក្នុងតំបន់សៀមរាប អង្គរ។
- ✓ សហការជាមួយក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា ដើម្បីសុំការអនុញ្ញាតិច្បាប់ធ្វើអាជីវកម្មគ្រប់ប្រភេទដែលពាក់ព័ន្ធនឹងបេសកកម្មរបស់ខ្លួន។
- ✓ សហការជាមួយវិទ្យាស្ថាន អង្គការមូលនិធិ និងសហគមន៍បរទេស និងអន្តរជាតិដែលមានគោលដៅដូចខ្លួន។

- **ភារកិច្ចទី៣** ៖ ធានារ៉ាប់រងនូវការដ្ឋាននៃការរៀបចំតំបន់សៀមរាប អង្គរ ហើយនិងកំណត់សៀវភៅបន្ទុកនៃគម្រោង ដែលអនុវត្តដោយគ្រឹះស្ថានស្ថិតនៅក្រោមការត្រួតត្រាផ្ទាល់ជាដៃគូ ជាមួយរដ្ឋអំណាចខេត្តជាអាណាព្យាបាល និងស្ថាប័នអង្គការមូលនិធិសហគមន៍ខ្មែរ និងបរទេស ដែលបានធ្វើតាមទិសដៅ ឆ្លើយតបទៅនឹងមុខជំនាញដែលធ្វើប្រតិបត្តិការនៅក្នុងតំបន់។

មិនតែប៉ុណ្ណោះ អាជ្ញាធរជាតិអប្សរា មានភារកិច្ចទទួលបន្ទុកការពារអភិរក្ស និងទ្រទ្រង់តំបន់រមណីយដ្ឋានអង្គរ ស្របតាមបទប្បញ្ញត្តិនៃមាត្រា៥ នៃព្រះរាជក្រម នស/រកម/០១៩៦/២៦ ចុះថ្ងៃទី ២៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ព្រមទាំងកាតព្វកិច្ចអន្តរជាតិដែលតម្រូវឱ្យរមណីយដ្ឋានតំបន់អង្គរ

---

[28]ព្រះរាជក្រឹត្យស្តីពីការកំណត់ និងការចាត់ចែងគ្រប់គ្រងតំបន់សៀមរាប អង្គរ, លេខ ០០១ ន.ស, ២៨ ឧសភា ១៩៩៤, មាត្រា៦។

[29]ព្រះរាជក្រឹត្យស្តីពីការកំណត់ និងការចាត់ចែងគ្រប់គ្រងតំបន់សៀមរាប អង្គរ, លេខ ០០១ ន.ស, ២៨ ឧសភា ១៩៩៤, មាត្រា៧។

រក្សាបាននូវលក្ខណៈសម្បត្តិជាបេតិកភណ្ឌពិភពលោក ដូចនេះដើម្បីបំពេញមុខងារនេះបានល្អ នាំឱ្យអាជ្ញាធរអប្សរាទទួលបានសិទ្ធិផ្តាច់មុខក្នុងការចេញលិខិតអនុញ្ញាតសាងសង់សម្រាប់ការស្ថាបនាទាំងឡាយ ក្នុងរង្វង់តំបន់រមណីយដ្ឋានអង្គរ។ ហើយបើសំណង់មិនមានលិខិតអនុញ្ញាតពីអាជ្ញាធរអប្សរានាំឱ្យមានមោឃភាព។ រីឯសំណង់គ្មានច្បាប់វិញត្រូវរុះរើចេញដោយម្ចាស់សំណង់ល្មើសច្បាប់ ក្នុងរយៈពេល៥៥ថ្ងៃ យ៉ាងយូរគិតពីថ្ងៃជូនដំណឹង[30]។

## ២.១.២ សមិទ្ធផលរបស់អាជ្ញាធរជាតិអប្សរា

ចាប់តាំងពីឆ្នាំ១៩៩៩មក អាជ្ញាធរជាតិអប្សរាបានក្លាយជាគ្រឹះស្ថានរដ្ឋបាលសាធារណៈប្រកបដោយបុគ្គលភាពគតិយុត្តិ ដែលមានស្វ័យភាពរដ្ឋបាល និងហិរញ្ញវត្ថុ។ រាជរដ្ឋាភិបាលកម្ពុជាយកចិត្តទុកដាក់ជាពិសេសទៅនឹងការងាររបស់អាជ្ញាធរជាតិអប្សរា និងភាពជោគជ័យប្រតិបត្តិការការពារ និងការលើកតម្លៃរមណីយដ្ឋានអង្គរហើយដែលជាហេតុនាំឱ្យរមណីយដ្ឋានអង្គរត្រូវបានដកចេញពីបញ្ជីបេតិកភណ្ឌដែលប្រឈមទៅនឹងគ្រោះថ្នាក់នៅក្នុងឆ្នាំ២០០៤។ ក៏ប៉ុន្តែការលើកតម្លៃរមណីយដ្ឋានអង្គរមិនអាចសម្រេចបានគ្រប់ជ្រុងជ្រោយបានទេ ប្រសិនបើសកម្មភាពនៃការអភិរក្សមិនមានគម្រោងអភិវឌ្ឍច្បាស់លាស់ភ្ជាប់មកជាមួយ ដើម្បីលើកតម្លៃបេតិកភណ្ឌអរូបីដែលពិតជាមានទំនាក់ទំនងជាមួយអត្តសញ្ញាណនៃតំបន់អង្គរ និងសមាសធាតុសំខាន់ៗដទៃទៀតដែលមានគុណប្រយោជន៍ដល់ការរីកចំរើនរបស់ប្រជាជន។ ទោះបីជាប្រជាជនមានការលំបាកក្នុងការគិតគូរដើម្បីឱ្យមានជីវភាពល្អប្រសើរ និងមានការដាក់កំហិតឱ្យអនុវត្តតាមបទដ្ឋានបេតិកភណ្ឌក៏ដោយ ក៏ប្រជាពលរដ្ឋនៅក្នុងតំបន់ការពារនៅតែបន្តរស់នៅជាមួយប្រពៃណីរបស់គេ សម្រាប់ជាមធ្យោបាយមួយដ៏ចាំបាច់នៅក្នុងការចិញ្ចឹមជីវិត។ នៅក្នុងតំបន់អង្គរ ប្រជាជនបានភ្ជាប់ខ្លួនទៅនឹងដីស្រែចំការ ហើយពួកគេរស់នៅទីនោះ តាំងពីមុនការចុះឈ្មោះរមណីយដ្ឋានអង្គរនៅលើបញ្ជីបេតិកភណ្ឌពិភពលោកម្ល៉េះ។ ដើម្បីជាប្រយោជន៍ដល់ប្រជាជនទាំងនោះ ការអភិវឌ្ឍន៍សហគមន៍ គឺជាការចាំបាច់មិនអាចខ្វះបានស្របតាមអនុសញ្ញាឆ្នាំ១៩៧២។ នៅលើផ្ទៃដី ៤០ ០០០

[30] មាត្រា៦ ព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការកែសម្រួលបទប្បញ្ញត្តិមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរអប្សរាដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថា អាជ្ញាធរ "អប្សរា"

ហិចតានៃឧទ្យាន មានប្រជាជនរស់នៅ និងប្រកបការងារប្រមាណជា ១២៥ ០០០នាក់ និងបែងចែកជា ១១២ភូមិ។ ដើម្បីឱ្យគ្រួសារដែលមានកូនចៅចេះតែកើនឡើងមានលំនៅដ្ឋានបន្ថែមដោយ មិនធ្វើឱ្យប៉ះពាល់ដល់បូរណភាពរបស់រមណីយដ្ឋានដែលជាបេតិកភណ្ឌពិភពលោក អាជ្ញាធរជាតិអប្សរាបានរៀបចំភូមិធម្មជាតិមួយដែលស្ថិតនៅក្រៅឧទ្យានអង្គរ នៅរុនតាឯក លើផ្ទៃដី ១ ០០០ ហិចតា សម្រាប់សម្រួលដល់ការតាំងទីលំនៅរបស់ពួកគាត់។

- **ការបង្កើតរមណីយដ្ឋានធម្មជាតិ**
  - **ការបង្កើតភូមិធម្មជាតិរុនតាឯក**

អាជ្ញាធរជាតិអប្សរា មានភារកិច្ចអភិរក្សបេតិកភណ្ឌ ព្រមទាំងអភិវឌ្ឍតំបន់ឧទ្យានអង្គរទាំងមូលប្រកបដោយចីរភាព។ ច្បាប់ និងបទប្បញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជាបានកំណត់ថា ដែនដីនៃបេតិកភណ្ឌវប្បធម៌ និងប្រវត្តិសាស្ត្រជាសម្បត្តិសាធារណៈរបស់រដ្ឋ។ រាជរដ្ឋាភិបាល ក៏បានចេញសេចក្ដីសម្រេចលេខ ៧០ សសរ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៤ ដែលមានចែងថា៖ **ប្រជាពលរដ្ឋដែលមានលំនៅដ្ឋានរស់នៅយូរលង់មកហើយក្នុងតំបន់ការពារទី១ និងទី២ នៃឧទ្យានអង្គរ អាចបន្តរស់នៅតទៅទៀតបាន ដោយមិនមានការដេញឱ្យចាកចេញពីភូមិដ្ឋានឡើយ។ អ្នកភូមិទាំងនោះ អាចរុះរើ ជួសជុលផ្ទះចាស់ទ្រុឌទ្រោម ដើម្បីសាងសង់ផ្ទះថ្មី ជំនួសផ្ទះចាស់បាន ដោយមានការអនុញ្ញាតពីអាជ្ញាធរអប្សរា។ ក៏ប៉ុន្តែរាល់ការសាងសង់ផ្ទះថ្មី ត្រូវហាមឃាត់ជាដាច់ខាត។**

ក្នុងន័យនេះ រាជរដ្ឋាភិបាលមានគោលបំណងចង់ទប់ស្កាត់ការរីកដុះដាល ផ្ទះសម្បែង ថែរក្សាទេសភាពវប្បធម៌ដ៏អច្ឆរិយៈឱ្យនៅគង់វង្សតាមភាពដើម។ ហេតុនេះ គឺតម្រូវឱ្យហាមឃាត់កុំឱ្យមានអ្នកចំណូលថ្មី មកតាំងទីក្នុងឧទ្យាន។ ក៏ប៉ុន្តែទោះជាយ៉ាងនោះក្ដី ក៏ចំនួនប្រជាពលរដ្ឋនៅតែមានការកើនដែរ ដោយហេតុថាកូនចៅរបស់អ្នកស្រុកចាស់នោះ ពេលមានវ័យចម្រើនឡើងហើយពួកគេត្រូវរៀបការបង្កើតជាគ្រួសារថ្មីបន្តបន្ទាប់ ហើយតម្រូវឱ្យបន្ថែមផ្ទះសម្បែងថ្មីៗទៀត។

បន្ទាប់ពីបានបង្កើតនូវភូមិធម្មជាតិខាងលើរួចមក អាជ្ញាធរអប្សរាក៏បានជួយប្រជាជនដែលរស់នៅទីនោះដោយផ្តល់នូវថវិកាឱ្យប្រជាជនដើម្បីសង់ផ្ទះថ្ម និងប្រាប់អំពីការធ្វើស្រែតាមរបៀបGAP និងបានប្រគល់នូវគ្រាប់ពូជដំណាំ ហើយបង្ហាញពីរបៀបដាំដុះដើម្បីអភិវឌ្ឍទីនោះឱ្យក្លាយជាតំបន់ទេសចរណ៍បៃតង ព្រមទាំងបានផ្សព្វផ្សាយអំពីរមណីយដ្ឋាននោះ

នៅក្នុងគោលបំណងដើម្បីទាក់ទាញភ្ញៀវទេសចរណ៍ទៅកំសាន្តនៅទីនោះនៅពេលអនាគត ។ ចំពោះបញ្ហាសុខភាពរបស់ប្រជាពលរដ្ឋវិញ អាជ្ញាធរជាតិអប្សរាក៏បានបង្កើតនូវក្រុមគ្រូពេទ្យស្ម័គ្រចិត្តទាំងក្នុងប្រទេស និង ក្រៅប្រទេសដើម្បីចុះទៅពិនិត្យ និងព្យាបាលជូនប្រជាជនផងដែរ[31]។

សរុបមកបន្ទាប់ពីបានបង្កើត ភូមិធម្មជាតិរុនតាឯកនោះរួចមកយើងឃើញថា បានទទួលរង្វាន់ចំនួន៣ពីការប្រឡងប្រណាំង "រមណីយដ្ឋានស្អាត សេវាល្អ និងបដិសណ្ឋារកិច្ចល្អ ឆ្នាំ២០១៥-២០១៦" ដែលជាសមិទ្ធិផលដ៏ជោគជ័យមួយរបស់អាជ្ញាធរអប្សរា។

- **មណ្ឌលលំនៅដ្ឋានខ្មែរ**

មណ្ឌលលំនៅដ្ឋានខ្មែរ ដែលមានគោលបំណងសំខាន់ គឺបង្ហាញអំពីលក្ខណៈផ្ទះបុរាណខ្មែរ និងការរៀបចំសួនក្នុងដីឡូត៍ស្ថិតនៅក្នុងឧទ្យានអង្គរខាងជើងប្រាសាទបន្ទាយក្តី និងស្រះស្រង់ ត្រង់កន្លែងផ្លូវបំបែកទៅវង់ធំ និងវង់តូច។

នៅក្នុងមណ្ឌលនេះ មានអគារខ្មែរបុរាណមួយខ្នងដែលជាទីតាំងពិព័រណ៍។ អគារនោះបានសាងសង់ឡើងតាមបែបបទផ្ទះបុរាណខ្មែរ ដោយប្រើប្រាស់សម្ភារៈបុរាណធម្មតា ក៏ប៉ុន្តែមានបំពាក់នូវឧបករណ៍សម័យថ្មីខ្លះៗដែលអាចសម្រួលជីវភាពក្នុងគ្រួសារដូចជា មានធុងចម្រោះទឹកដែលធ្វើឱ្យទឹកស្អាត និងចង្រ្កានកែច្នៃដែលអាចសន្សំធ្យូងនិងអុសបានច្រើន ព្រមទាំងមានការប្រើប្រាស់ថាមពលព្រះអាទិត្យសម្រាប់បំភ្លឺទៀតផង។

នៅក្នុងផ្ទះនេះ មានរៀបចំតាំងសំណាក់ផ្ទះខ្មែរគ្រប់បែប មានផ្ទះកន្តាំង ផ្ទះរោងដោល ផ្ទះរោងឌៀង ផ្ទះប៉ិត និងផ្ទះកឹង។ អត្ថបទ និងផ្ទាំងរូបភាពស្តីអំពីពិធីសែនព្រេនអ្នកតាម្ចាស់ស្រុកសុំអនុញ្ញាតសាងសង់ ពិធីឡើងផ្ទះតាមប្រពៃណី ព្រមទាំងផ្ទាំងរូបដែលបង្ហាញពីវិវត្តន៍នៃផ្ទះខ្មែរតាំងពីសម័យអង្គររហូតមកដល់បច្ចុបន្បន្នកាលនេះ[32] ។

ទីធ្លានៅជុំវិញផ្ទះ ត្រូវបានរៀបចំធ្វើជាសួនបន្លែ ដែលរមែងមាននៅក្នុងភូមិខ្មែរធម្មតា។ ក៏ប៉ុន្តែនៅក្នុងសួននេះ មិនមានដាំតែបន្លែដែលខ្មែរយើងធ្លាប់ដាំដុះនោះទេ គឺមានដាំបន្លែមកពីបស្ចឹមប្រទេសដូចជា សាឡាដ ផ្កាស្ពៃ ការ៉ុត ជីបារាំង ប៉េងប៉ោះអ៊ីតាលីជាដើមដែលអាចលក់ឱ្យទៅភោជនីយដ្ឋាន

[31] សៀវភៅកិច្ចការពាររមណីយដ្ឋានអង្គរ និងបញ្ហាដីធ្លី ខែឧសភា ឆ្នាំ២០០៥

[32] សៀវភៅកិច្ចការពាររមណីយដ្ឋានអង្គរ និងបញ្ហាដីធ្លី ខែឧសភា ឆ្នាំ២០០៥

និងសណ្ឋាគារធំៗនៅក្រុងសៀមរាបជំនួសការនាំចូលពីបរទេស។ ផ្កា និងដើមឈើហូបផ្លែក៏មានដាំជាហូរហែដែរ។ ទីនេះមានអនុវត្តការដាំដុះតាមធម្មជាតិ ហេតុនេះស្ថានីយ៍កសិកម្មតូចមួយក៏ត្រូវបានបង្កើតឡើងដើម្បីផលិតជីកំប៉ុស។ នៅខាងក្រោយផ្ទះមានត្រពាំងតូចមួយសម្រាប់ចិញ្ចឹមត្រីផងដែរ។

របងធម្មជាតិ ត្រូវបានរៀបចំនៅជុំវិញមណ្ឌលដោយមានប្រភេទនៃការដើមឈើហើយគេអាចយក ស្លឹក ផ្កា ផ្លែ ទៅប្រើប្រាស់នៅក្នុងការដាំស្លទៀតផង។ គេអាចកាត់មែកឈើនោះទៅប្រើប្រាស់ជាអុសសម្រាប់ចំអិនអាហារបាន ដោយមិនចាំបាច់ទៅរុករានរកអុសក្នុងព្រៃនៃឧទ្យានអង្គរទៀតទេ។

មធ្យោបាយបែបងាយស្រួលទាំងនេះ អាចធ្វើឱ្យប្រជាពលរដ្ឋបានយល់កាន់តែច្បាស់ពីផលប្រយោជន៍ដែលគាត់អាចទាញយកពីដីធ្លីដែលគាត់មាន ដើម្បីផលិតកែច្នៃយកកម្រៃមកលើកស្ទួយកម្រិតជីវភាពរបស់គាត់ដោយមិនចាំបាច់លក់ដូរដីធ្លីនោះឱ្យទៅអ្នកដទៃ និងរុករានបំពានទៅលើឧទ្យានអង្គរទេ។ មណ្ឌលនេះបានសម្ភោធដាក់ឱ្យសាធារណៈជនចូលទស្សនាដោយសេរីតាំងពីខែវិច្ឆិកា ឆ្នាំ២០១០មក។

❖ **កិច្ចការសំណង់**

អាជ្ញាធរជាតិអប្សរា មានភារកិច្ចណែនាំប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ការពារឱ្យរៀបចំលំនៅដ្ឋានរបស់ខ្លួនទៅតាម "លំនាំជាផ្ទះខ្មែរ" ដែលធ្លាប់តែមាននៅពាសពេញផ្ទៃព្រះនគរ។

ផ្ទះខ្មែរតែងតែមានជើងសសរខ្ពស់ពីដី ព្រោះធាតុអាកាសក្ដៅ និងទឹកភ្លៀងពេលវស្សាតម្រូវឱ្យធ្វើបែបនេះ ហើយនាំឱ្យមានខ្យល់ចេញចូលស្រួលទប់ទល់នឹងកំដៅ និងការពារកុំឱ្យទឹកលិចដល់ក្ដារក្រាល។ គេប្រើទីតាំងក្រោមផ្ទះនេះសម្រាប់ដាក់រទេះចងគោ ចងអង្រឹង ដាក់គ្រែអង្គុយកម្សាន្ត ឬដាំស្លម្ហូបអាហារ។ គួរជៀសវាងកុំធ្វើសសរខ្ពស់ពេកនាំឱ្យពិបាកទប់នឹងខ្យល់ខ្លាំង អាចរលំស្រួលបង្កជាគ្រោះថ្នាក់។ ម្យ៉ាងវិញទៀត នាំតែអស់ឈើ ឬតដ្ឋ ស៊ីម៉ង់ត៍ ខាតប្រាក់កាសច្រើន។ រីឯសោភ័ណភាពទៀតសោត ក៏មិនល្អមើលដែរ ជើងសសរកម្រិតត្រឹម ២,៥០ ម៉ែត្រជាការប្រសើរ[33]។

[33] សៀវភៅកិច្ចការពាររមណីយដ្ឋានអង្គរ និងបញ្ហាដីធ្លី ខែឧសភា ឆ្នាំ២០០៥

ចាប់តាំងពីឆ្នាំ១៩៩០មក ខ្មែរយើងមានទោចក្រយានយន្ត ម៉ូតូ ប្រើច្រើនគ្នា។ អ្នកខ្លះគេយកក្តារធ្វើជាស្ពានជម្រាលពីដីរហូតដល់លើផ្ទះ ដើម្បីរុញម៉ូតូទៅទុកក្នុងផ្ទះខាងលើនៅពេលយប់ការពារកុំឱ្យបាត់បង់។ តែនាពេលឥឡូវនេះ យើងសឹងតែមិនឃើញមានស្ពានជម្រាលទៀតទេ ព្រោះគេបាននាំគ្នាយកក្តារ ឬឥដ្ឋមកព័ទ្ធជាជញ្ជាំងនៅជាន់ខាងក្រោមផ្ទះ ដើម្បីធ្វើជាឃ្លាំងទុកដាក់ម៉ូតូ និងឧបករណ៍ខ្លះទៀតដែលធ្ងន់ៗ។ ជាងនេះទៅទៀត ការរៀបជញ្ជាំងខាងក្រោមនេះនាំឱ្យផ្ទះរឹងរិតតែមាំអាចទប់ទល់និងខ្យល់ខ្លាំងបាន។ ក៏ប៉ុន្តែយើងមិនគប្បីបិទជញ្ជាំងឱ្យពេញផ្ទៃផ្ទះទាំងអស់ទេត្រូវតែរក្សាការបើកចំហរមួយ ឬពីរល្វែងនៅក្រោមផ្ទះដើម្បីប្រើប្រាស់តាមលំនាំបុរាណ។

រីឯផ្ទះតៀមជាប់និងដី មិនមែនជាបែបផ្ទានផ្ទះខ្មែរបុរាណទេគឺច្រើនតែជាផ្ទះជនជាតិចិន ឬវៀតណាមដែលគេនៅជាផ្ទះផង និងធ្វើជាតៀមលក់គ្រឿងឧបភោគបរិភោគផង ឬជាផ្ទះវីឡា (Villa) បែបអឺរ៉ុបដែលគេសាងសង់ក្នុងក្រុង។ យើងពុំអាចសង់ផ្ទះបែបនេះនៅក្នុងតំបន់ការពារនៃឧទ្យានអង្គរបានទេ ព្រោះនាំឱ្យសាបរលាបបាត់បង់អត្តសញ្ញាណជាតិយើង[34]។

ម៉្យាងវិញទៀត មានផ្ទះល្វែងមួយជាន់ ឬច្រើនជាន់ដែលសង់ជាប់ផ្ទាល់និងដីគឺបារាំងគេបាននាំពីបរទេសមកសង់តែជុំវិញផ្សារកណ្តាលក្រុងសម្រាប់ឱ្យម្ចាស់គេនៅខាងលើ ហើយសម្រាប់លក់ឥវ៉ាន់នៅជាន់ផ្ទាល់ដី។ ផ្ទះល្វែងប្រភេទនេះ ក៏ពុំគួរសាងសង់ក្នុងតំបន់ការពារនៃឧទ្យានអង្គរដែរ។

ដើម្បីថែរក្សា "លំនាំបុរាណ" និងទេសភាពឧទ្យានយើងត្រូវតែគិតដល់ពណ៌សម្បុរនៃផ្ទះទៀតផង។ ដំបូលត្រូវធ្វើអំពីក្បឿងក្រហម ឬស៊ីម៉ង់ត៍ ឬហ្វ៊ីប្រូ ឬស័ង្កសីពណ៌ក្រហម ឬបៃតង។ ពុំគួរប្រើស័ង្កសីពណ៌សនោះទេ។ រីឯជញ្ជាំង ឬទ្វារបង្អួច ដែលធ្វើអំពីឈើត្រូវទុកសាច់ឈើធម្មជាតិ ឬមួយលាបពណ៌ដូចឈើ។ ចំណែកឯ ជញ្ជាំងឥដ្ឋនៅខាងក្រោម អាចលាបពណ៌ស៊ីម៉ង់ត៍ ឬពណ៌ដូចច្រែះដីលែងឱ្យស្រគាំនិងពណ៌ឈើ។ គួរជៀសវាងជាដាច់ខាតនូវពណ៌ស ឬពងមាន់ ឬស៊ីជម្ពូរ ឬពណ៌ដទៃទៀតដែលមានលក្ខណៈឆើតឆាយ។ ជាទីបញ្ចប់ ដើម្បីអនាម័យក្នុងគ្រួសារ និងភូមិស្អាត ប្រជាពលរដ្ឋត្រូវនាំគ្នាធ្វើបង្គន់ ទោះនៅក្រោមផ្ទះក្តី លើផ្ទះក្តី ឬនៅក្នុងដីឡូត៍ក្តី។ នាយកដ្ឋានរៀបចំដែនដី និងលំនៅដ្ឋានបានរៀបចំក្រដាសផ្ទត់ចំនួន ០៩ សម្រាប់ណែនាំ

---

[34] សៀវភៅកិច្ចការពាររមណីយដ្ឋានអង្គរ និងបញ្ញាជីថ្លី ខែឧសភា ឆ្នាំ២០០៥

ប្រជាពលរដ្ឋក្នុងការសាងសង់ផ្ទះ និងរបងដីឡូត៍។ មិនតែប៉ុណ្ណោះ បានធ្វើក្រដាសផ្ទត់ពិសេសមួយទៀតស្តីពី គោលការណ៍ថែរក្សាអគារក្នុងវត្តអារាម។

❖ **ការរៀបចំ និងគ្រប់គ្រងដែនដីដែនដី**

ការរៀបចំដែនដី និងគ្រប់គ្រងដែនដីវាទាមទារឱ្យមានការយកចិត្តទុកដាក់ខ្ពស់ ទាំងការងារដីធ្លី ការរៀបចំគ្រប់គ្រងសំណង់លំនៅដ្ឋាន ការដោះស្រាយទំនាស់ដោយគោរពទៅតាមច្បាប់ ការហាមឃាត់ការសាងសង់បន្ថែមចំនួនផ្ទះ ការជុសជុល ការសាងសង់សំណង់ថ្មីជំនួសឱ្យសំណង់ចាស់ដែលតម្រូវឱ្យមានការសុំការអនុញ្ញាតជាមុនពីអាជ្ញាធរជាតិអប្សរា។ នៅក្នុងនោះដែរការបង្កើតនូវភ្នាក់ងារ ប្រតិបត្តិការ និងត្រួតពិនិត្យរាល់ការងាររៀបចំ និងការងារគ្រប់គ្រងដែនដីក្នុងតំបន់អង្គរ គឺជាយន្តការមួយដែលត្រូវធ្វើជាចាំបាច់។

អាស្រ័យដូចនេះហើយ ទើបការងាររៀបចំ និងគ្រប់គ្រងដែនដីអាជ្ញាធរអប្សរានៅឆ្នាំ ២០០៤ បានបង្កើតនាយកដ្ឋានថ្មីមួយ ដែលមានឈ្មោះថា នាយកដ្ឋានរមណីដ្ឋាន និងបុរាណវិទ្យាទី២ ។ ក្រោយមកនៅឆ្នាំ២០០៨ ទើបមានការរៀបចំរចនាសម្ព័ន្ធនៃអាជ្ញាធរអប្សរាឡើងវិញ ហើយនាយកដ្ឋាន នោះត្រូវបានប្តូរឈ្មោះមកជា នាយកដ្ឋានរៀបចំដែនដី និង គ្រប់គ្រងលំនៅដ្ឋាននៅក្នុងតំបន់ឧទ្យាន អង្គរ (រ ដ ល) រហូតមកដល់សព្វថ្ងៃនេះ[35]។ ហើយនាយកដ្ឋាននេះមានតួនាទី និងភារកិច្ចដូចជា៖

- ចូលរួមធ្វើបែបបទធ្វើប័ណ្ណកាន់កាប់ និងចុះបញ្ជីដីធ្លីឱ្យសមស្របជាមួយនិងទិន្នន័យសុរិយោដី និងតាមប្បញ្ញាត្តិជាធរមាន។
- ចូលរួមរៀបចំផែនការប្រើប្រាស់ដីធ្លីក្នុងតំបន់ការពារនៃឧទ្យានអង្គរ។
- បង្កើតស្លាកសញ្ញានៅក្នុងរមណីយដ្ឋានអង្គរ និងស្លាកពតិមានដាក់នៅក្នុងឧទ្យានអង្គរ ទាំងមូលដោយសហការជាមួយនាយកដ្ឋានដែលពាក់ព័ន្ធ។
- ចូលរួមគ្រប់គ្រងដោយសុវត្ថិភាព មានសមធម៌ និងគោរពដល់តម្លៃនៃបេតិកភណ្ឌ ក្នុងការចេញប័ណ្ណអនុញ្ញាតឱ្យសាងសង់។
- ពិនិត្យសំណើសុំសាងសង់ និងរៀបចំប័ណ្ណអនុញ្ញាតសាងសង់ទៅតាមបទប្បញ្ញត្តិដែលមានជាធរមានព្រមទាំងតាមដានពិនិត្យ

[35] គេហទំព័រអ៊ីនធើណិត *អាជ្ញាធរជាតិអប្សរា* (www.apsaraauthority.gov.kh)

ការសាងសង់
និងចេញលិខិតបញ្ជាក់ថាការសាងសង់នោះត្រឹមត្រូវតាមការកំណត់របស់អាជ្ញាធរអប្សរា។

- ការចូលរួមរៀបចំមណ្ឌលសកម្មភាពតូចៗ សម្រាប់អ្នកភូមិក្នុងតំបន់ការពារឧទ្យានអង្គរ។
- ផ្សព្វផ្សាយប្រគេនដល់ព្រះសង្ឃ ឱ្យស្គាល់អំពីតម្លៃនៃបេតិកភណ្ឌ និងសាសនាក្នុងការថែរក្សាអាគារចាស់ៗព្រមទាំងរូបគំនូរបុរាណដែលមាននៅតាមវត្តអារាម។
- ធ្វើការសហការជាមួយនាយកដ្ឋានដែលពាក់ព័ន្ធក្នុងការអង្កេតផ្នែកវប្បធម៌ និងជាតិពិន្ទុវិទ្យាពីប្រជាពលរដ្ឋដែលរស់នៅក្នុងឧទ្យានអង្គរ។
- ចូលរួមក្នុងការគាំទ្រក្នុងការអនុវត្តគម្រោងអភិវឌ្ឍសហគមន៍។
- ចូលរួមជម្រុញការអប់រំខាងសង្គម និងការបណ្តុះបណ្តាលវិជ្ជាជីវៈនៅតាមជនបទ។

ចាប់តាំងពីឆ្នាំ២០០៥រហូតមក នាយកដ្ឋានរៀបចំដែនដី និងគ្រប់គ្រងលំនៅដ្ឋាននៅក្នុងតំបន់ឧទ្យានអង្គរបានចាត់ក្រុមកម្លាំងវាស់វែងដីធ្លីទៅធ្វើការសម្រង់ស្ថិតិដីធ្លី នៅក្នុងតំបន់តាមភូមិម្តងមួយៗរហូតមកដល់សព្វថ្ងៃនេះធ្វើបាន១៣ភូមិហើយ រីឯភូមិដទៃទៀតបាននិងកំពុងធ្វើជាបន្តបន្ទាប់[36]។ គួររំលឹកផងដែរថា តាមច្បាប់និងបទប្បញ្ញត្តិជាធរមាន ផ្ទៃដីទាំមូលដែលស្ថិតនៅក្នុងឧទ្យានអង្គរជាកម្មសិទ្ធិសាធារណៈរបស់រដ្ឋ។ ក៏ប៉ុន្តែរដ្ឋបានអនុញ្ញាតឱ្យប្រជាពលរដ្ឋ ឬសហគមន៍ប្រើប្រាស់ក្នុងលក្ខណៈនៃច្បាប់។

ដីធ្លីក្នុងឧទ្យានត្រូវបានចាត់ជាបួនផ្នែកគឺៈ

១ ដីធ្លីដែលអ្នកស្រុកប្រើប្រាស់ដើម្បីសង់លំនៅដ្ឋានក្នុងភូមិ(ដីភូមិ)

២ ដីស្រែចំការដែលអ្នកស្រុកប្រើប្រាស់ដាំដុះ

៣ ដីដែលរដ្ឋ ឬសហគមន៍ប្រើប្រាស់

៤ និងដីដែលជាវាលព្រៃប្រាសាទដែលគ្រប់គ្រងដោយអាជ្ញាធរអប្សរា។

### ❖ កិច្ចការពារថែរក្សាប្រាសាទបុរាណ

ចំពោះបញ្ហាទាក់ទងនិងប្រាសាទបុរាណ អាជ្ញាធរជាតិអប្សរាក៏មានតួនាទីនៅក្នុងការថែរក្សាការពារ និងអភិរក្សប្រាសាទទាំងនោះឱ្យមានភាពគង់វង្សស្ថិតស្ថេរ ដូចជា អាជ្ញាធរជាតិអប្សរា ជួសជុលប្រាសាទបុរាណចាស់ដូចជា ប្រាសាទដែលត្រូវជួយសង្គ្រោះបន្ទាន់

[36] គេហទំព័រអ៊ីនធើណិត *អាជ្ញាធរជាតិអប្សរា* (www.apsaraauthority.gov.kh)

ទល់ទ្រប្រាសាទដោយសហការជាមួយស្ថាប័នដែលពាក់ព័ន្ធ ឱ្យមកជួយធ្វើការជួសជុល។ ឧទាហរណ៍ ដូចជាប្រាសាទបាពួន ប្រាសាទសួរព្រ័ត្រ ប្រាសាទនាងដប់ពីរ ប្រាសាទបាក់ខែង ប្រាសាទអង្គរ ប្រាសាទបន្ទាយស្រី ដែលប្រទេសស្វីសជាអ្នកជួយជួសជុល ហើយអាឡឺម៉ង់ជាអ្នកជួយជួសជុលចម្លាក់អប្សរាតាមជញ្ជាំងពុកផុយ បាញ់ការ និងបាញ់ថ្នាំខាងក្នុង។ ចំណែកឯប្រទេសជប៉ុន ជួយជួសជុលប្រាសាទបាយ័នដែលគេថតចំពីលើអាកាសមកកន្លែងណាផ្អៀង គឺគេយកឈើទល់ទ្រកន្លែងខ្លះរឹតដែក។ ប្រាសាទដែលត្រូវដួលរលំបែរមកជាឈប់រលំ ដែលនោះគឺជាស្នាដៃរបស់អាជ្ញាធរជាតិអប្សរា[37]។

❖ **ការអភិរក្សព្រៃឈើ**

អាជ្ញាធរជាតិអប្សរា បានដើរតួនាទីជាអ្នកថែរក្សាការពាររារាំងដល់ការកាប់បំផ្លាញព្រៃឈើ ជាពិសេសនៅក្នុងតំបន់សៀមរាប អង្គរ។ គ្រប់ប្រភេទដើមឈើទាំងអស់ដែលមាននៅក្នុងឧទ្យានអង្គរ សុទ្ធតែមានដាក់ឈ្មោះ និងបង់លេខសម្គាល់ផងដែរដើម្បីងាយស្រួលនៅក្នុងការធ្វើស្ថិតិ ។ ចំណែកឯបញ្ហាដើមឈើដែលដុះនៅលើប្រាសាទ ឬតាមជញ្ជាំងប្រាសាទដែលអាចប៉ះពាល់ដល់ប្រាសាទយ៉ាងធ្ងន់ធ្ងរ អាជ្ញាធរជាតិអប្សរាក៏មានវិធានការណ៍នៅក្នុងការកាប់មែក ឬស្លឹក ដើម្បីកាត់បន្ថយទម្ងន់ និងការពារកុំឱ្យមានការដួលរលំទៅលើប្រាសាទ។ ចំពោះដើមឈើខ្លះទៀត អាជ្ញាធរអប្សរាក៏បានធ្វើការកាប់គាស់យកចេញពីតំបន់ប្រាសាទ។ ឧទាហរណ៍ ការដកដើមត្នោតចេញពីរមណីយដ្ឋានអង្គរ។ លទ្ធផលដ៏គួរឱ្យកត់សម្គាល់មួយទៀត គឺការងារផ្សព្វផ្សាយ និងអប់រំប្រជាពលរដ្ឋអំពីការងារអភិរក្សព្រៃឈើ និងបេតិកភណ្ឌក្នុងតំបន់ការពារកោះកេរ។ តាមរបាយការណ៍ខាងលើនេះបានបញ្ជាក់ថា ក្រុមការងារបានចុះធ្វើការផ្សព្វផ្សាយបានចំនួន៣ភូមិ ពាក់ព័ន្ធសំខាន់ៗ គឺភូមិរំចេក ភូមិស្រយ៉ង់ខាងត្បូង និងភូមិស្រយ៉ង់ខាងជើង ដែលស្ថិតនៅក្នុងឃុំស្រយ៉ង់ ស្រុកគូលែន ខេត្តព្រះវិហារ។ ប្រជាពលរដ្ឋប្រមាណ៨០%បានមកចូលរួមស្តាប់ និងបានយល់ដឹងកាន់តែច្បាស់អំពីតម្លៃនៃការងារអភិរក្សព្រៃឈើ ហើយពួកគាត់ភាគច្រើនបានសន្យាចូលរួមសហការនិងថែរក្សាព្រៃឈើជាមួយក្រុមគណៈកម្មការច

[37]គេហទំព័រអ៊ីនធើណិត *អាជ្ញាធរជាតិអប្សរា* (www.apsaraauthority.gov.kh)

ម្រុះនេះ[38]។ ទោះជាយ៉ាងណាក្តី គណៈកម្មការចម្រុះនេះនៅតែចង់ទទួលបានលទ្ធផលដែលល្អប្រសើរជាងនេះ ដោយព្យាយាមកាត់បន្ថយឱ្យខានតែបានទៅលើបទល្មើសដោយមិនលើកលែងចំពោះអ្នកប្រព្រឹត្ត ណាមួយឡើយ ហើយក្រុមការងារផ្សព្វផ្សាយនៃគណៈកម្មការគ្រោងនឹងពង្រីកវិសាលភាពផ្សព្វផ្សាយទៅកាន់ឃុំមួយចំនួនទៀត ដែលនៅក្បែរនឹងតំបន់ការពារនៃប្រាសាទកោះកេរ ព្រោះជនល្មើសមួយចំនួនក៏មកពីបណ្តាឃុំទាំងនោះផងដែរ។ ទន្ទឹមនឹងនេះ ស្មារតីនៃកិច្ចប្រជុំរបស់គណៈកម្មការចម្រុះនេះក៏បានសម្តែងនូវការអរគុណ និងការគាំទ្រយ៉ាងពេញទំហឹងរបស់ឯកឧត្តមអគ្គនាយកនៃអាជ្ញាធរជាតិអប្សរា ដែលតែងតែតាមដានការងារ ផ្តល់អនុសាសន៍ដឹកនាំការងារ និងបានចុះមកពង្រឹងស្មារតីក្រុមអភិរក្សព្រៃឈើ ដែលជាកត្តាជំរុញឱ្យការងារយាមល្បាតមានប្រសិទ្ធភាព និងទទួលបានលទ្ធផលកាន់តែល្អប្រសើរឡើង។

### ❖ ហេដ្ឋារចនាសម្ព័ន្ធ និងកិច្ចការពារបរិស្ថាន

ចំពោះបញ្ហាហេដ្ឋារចនាសម្ព័ន្ធវិញ អាជ្ញាធរអប្សរាក៏បានគិតគូរអំពីបញ្ហាផ្សេងៗដូចជា ៖

- កសាងផ្លូវពីតំបន់មួយទៅតំបន់មួយ និងជុសជុលផ្លូវនៅក្នុងតំបន់សៀមរាបអង្គរ (ផ្លូវពីមុខប្រាសាទអង្គរវត្តទៅប្រាសាទបាយ័ន និងផ្លូវមិត្តភាពកម្ពុជា-កូរ៉េពីរខ្សែ ដែលត្រូវបានជួសជុលឡើងវិញដោយអាជ្ញាធរជាតិអប្សរា ត្រូវបានសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការហើយ នាព្រឹកថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៦នេះ។ អាជ្ញាធរជាតិអប្សរាបញ្ចប់ការជួសជុលផ្លូវខាងមុខប្រាសាទអង្គរវត្តទៅព្រលានយន្តហោះ) គួរបញ្ជាក់ថា ពេលគម្រោងរៀបចំផ្លូវវាងមុខប្រាសាទអង្គរវត្តចាប់ផ្តើមអនុវត្ត ការធ្វើដំណើរដោយយានយន្តគ្រប់ប្រភេទឆ្លងកាត់កំណាត់ផ្លូវមុខអង្គរវត្តទៅអង្គរធំឬពីអង្គរធំមកអង្គរវត្ត ត្រូវហាមមិនឱ្យឆ្លងកាត់ឡើយដោយតម្រូវឱ្យធ្វើដំណើរតាមផ្លូវវាងផ្សេង ដែលរៀបចំដោយអាជ្ញាធរជាតិអប្សរា។ ដោយឡែកកំណាត់ផ្លូវនៅមុខអង្គរវត្ត អនុញ្ញាតបានសម្រាប់តែកង់ ថ្មើរជើង ឡានសង្គ្រោះបន្ទាន់ ឡានទឹក

[38] សៀវភៅកិច្ចការពាររមណីយដ្ឋានអង្គរ និងបញ្ហាដីធ្លី ខែឧសភា ឆ្នាំ២០០៥

និងឡានគណៈប្រតិភូធំៗរបស់ជាតិ និងអន្តរជាតិដែលមកធ្វើការទស្សនកិច្ចផ្លូវការម្តងម្កាលឆ្លងកាត់ប៉ុណ្ណោះ[39]

- បំពាក់អំពូលអគ្គីសនីតាមបង្គោលភ្លើងនៅតាមដងវិថីនានា
- ការរៀបចំប្រព័ន្ធលូ ស្តារប្រលាយទឹកជូនប្រជាពលរដ្ឋ ព្រមទាំងធ្វើទំនប់ទឹកនៅបារាយណ៍ទឹកថ្លា
- រៀបចំបញ្ហាបរិស្ថានក្នុងតំបន់អង្គរដូចជា ដាក់ធុងសំរាមតាមប្រាង្គប្រាសាទនានា
- បង្កើតឱ្យមានសួនច្បារនៅតាមដងផ្លូវផ្សេងៗ និងបង្កើតជាពាក្យស្លោកផ្សេងៗក្នុងគោលដៅថែរក្សា និងការពារបរិស្ថាន
- រៀបចំឱ្យមានប្រព័ន្ធទឹកស្អាត
- ណែនាំឱ្យប្រជាជនកាត់បន្ថយការប្រើប្រាស់ជីគីមីងាកមកប្រើជីធម្មជាតិ ដើម្បីជួយទ្រទ្រង់ដល់បរិស្ថាន
- បង្កើតឱ្យមានមណ្ឌលទេសចរណ៍ ដូចជាកន្លែងលក់វត្ថុអនុស្សាវរីយ៍ជូនភ្ញៀវទេសចរ

### ❖ កសិកម្ម និង សហគមន៍

វិស័យកសិកម្ម គឺជាវិស័យសំខាន់បំផុតរបស់ប្រទេសកម្ពុជា ដោយសារតែប្រជាពលរដ្ឋពី៨០ ទៅ៩០ភាគរយប្រកបរបរនេះ ហើយអាជ្ញាធរជាតិអប្សរាបាននិងកំពុងធ្វើឱ្យកសិកម្មរីកចំរើននៅជុំវិញអង្គរដែរដើម្បីដោះស្រាយការងារជូនប្រជាពលរដ្ឋនៅជុំវិញតំបន់អង្គរ និងយកផលិតផលកសិកម្មទៅបំរើវិស័យទេសចរណ៍។ នៅក្នុងបរិវេណតំបន់អង្គរយើងសង្កេតឃើញមានប្រជាជនដែលរស់នៅហើយបានប្រកបរបរកសិកម្មនេះ អាជ្ញាធរជាតិអប្សរាបានបង្ហាត់បង្រៀនឱ្យប្រជាជនធ្វើកសិកម្មបែបធម្មជាតិ កុំប្រើប្រាស់ជីគីមីព្រោះវាអាចប៉ះពាល់ដល់សុខភាព។ បន្ថែមពីនោះ អាជ្ញាធរជាតិអប្សរាក៏មានមន្ត្រីជំនាញផលិតជីកំប៉ុសនិងជីអ៊ីអឹម លោក **ឈីវ ណាំ** អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍កសិកម្មដែលមានបទពិសោធន៍យូរឆ្នាំ បានណែនាំពីរបៀបប្រើប្រាស់ជីដល់ប្រជាជន ព្រមទាំងបង្រៀនប្រជាជនឱ្យចេះធ្វើជីកំប៉ុស និងជីអ៊ីអឹម ដើម្បីផ្គត់ផ្គង់ដល់ដីកសិកម្មរបស់ខ្លួនដែលជាកត្តាមួយអាចជួយដល់បរិស្ថាន និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ[40]។ មិនត្រឹមតែប៉ុណ្ណោះ អាជ្ញាធរជាតិអប្សរាក៏បានបង្កើតនាយកដ្ឋានមួយឈ្មោះថា នាយកដ្ឋានប្រជាសាស្ត្រ

[39] គេហទំព័រអ៊ីនធើណិត *អាជ្ញាធរជាតិអប្សរា* (www.apsaraauthority.gov.kh)

[40] សៀវភៅកិច្ចការពាររមណីយដ្ឋានអង្គរ និងបញ្ហាដីធ្លី ខែឧសភា ឆ្នាំ២០០៥

និងការងារអភិវឌ្ឍដែលដឹកនាំដោយលោក **តាន់ ប៊ុនស៊ុយ** ដើម្បីធ្វើឱ្យតំបន់ជុំវិញ សៀមរាប អង្គរក្លាយជាខ្សែក្រវ៉ាត់បៃតងដើម្បីរួមចំណែកក្នុងការផលិត។ សព្វថ្ងៃលោកកំពុងសិក្សាការងារសំខាន់ពីរគឺទី១៖ ការប្រើប្រាស់ភក់ទន្លេសាបដើម្បីដាំដុះឱ្យបានល្អផលិតបន្លែ ផ្លែឈើ និងទី២គឺ៖ ការស្រាវជ្រាវក្នុងការបង្កើតអង់ស៊ីម ជាវត្ថុម៉្យាងដើម្បីដាក់បន្លែ ផ្លែឈើទៅគ្មានជាតិពុល[41]។

ចំណែកឯខាងសហគមន៍វិញ អាជ្ញាធរជាតិអប្សរាបានចូលរួមយ៉ាងសកម្មក្នុងការជួយជ្រោមជ្រែងបង្កើតឱ្យមានសហគមន៍សិប្បកម្ម និងសហគមន៍រទេះគោសម្រាប់ដឹកភ្ញៀវដើរលេងកម្សាន្តតាមភូមិរបស់ពួកគាត់ផ្ទាល់ ព្រមទាំងជួយផ្សព្វផ្សាយព័ត៌មានដល់ក្រុមហ៊ុនទេសចរណ៍ និងមគ្គុទ្ទេសក៍ទេសចរណ៍ដើម្បីប្រាប់និងនាំភ្ញៀវទេសចរមកទស្សនានិងជិះរទេះគោទៀតផង។ មិនត្រឹមតែប៉ុណ្ណោះ វាក៏អាចទាញយកប្រាក់ចំណូលបន្ថែមសម្រាប់ជួយផ្គត់ផ្គង់ក្រុមគ្រួសាររបស់ប្រជាពលរដ្ឋ និងថែមទាំងជួយថែរក្សានូវទំនៀមទម្លាប់សិប្បកម្មបុរាណដែលជាអត្តសញ្ញាណជាតិយើង និងជាកេរ្តិ៍ដំណែលដូនតាតាំងពីយូរលង់ណាស់មកហើយ ទុកសម្រាប់ឱ្យកូនចៅជំនាន់ក្រោយបានស្គាល់ ក៏ដូចជាបង្ហាញអន្តរជាតិឱ្យគេស្គាល់កម្ពុជាកាន់តែច្បាស់ឡើង[42]។

### ❖ ទេសចរណ៍ និង វប្បធម៌

អាជ្ញាធរជាតិអប្សរា បានខិតខំធ្វើយ៉ាងណាដើម្បីទាក់ទាញលំហូរចំនួនភ្ញៀវទេសចរឱ្យមកទស្សនានៅតំបន់អង្គរដ៏បវរមួយនេះ ក្នុងនោះដែរអាជ្ញាធរនេះបានបង្កើតនូវរមណីយដ្ឋានផ្សេងៗដូចជា សារមន្ទីរ កន្លែងលក់វត្ថុអនុស្សាវរីយ៍ តំបន់វប្បធម៌ប្រវត្តិសាស្ត្រ (ភូមិវប្បធម៌ដែលបានបង្ហាញពីរូបសំណាក់បុព្វបុរសពីជំនាន់ដើម និងជាទីកន្លែងដ៏សំខាន់ៗនៅក្នុងប្រទេសកម្ពុជា) ដើម្បីឱ្យភ្ញៀវទេសចរទាំងអស់បានទស្សនាកំសាន្តពីវប្បធម៌ អរិយធម៌ សិល្បៈ របាំ វាក៏ជាផ្នែកមួយនៃការផ្សព្វ ផ្សាយទៅពិភពលោកដ៏ទៃទៀតឱ្យបានដឹង។ លើសពីនេះទៅទៀត អាជ្ញាធរនេះក៏បានធ្វើការសហការជាមួយនិងវិស័យបដិសណ្ឋាកិច្ច

---

[41] សៀវភៅកិច្ចការពាររមណីយដ្ឋានអង្គរ និងបញ្ហាដីធ្លី ខែឧសភា ឆ្នាំ២០០៥

[42] គេហទំព័រអ៊ីនធើណិត *អាជ្ញាធរជាតិអប្សរា* (www.apsaraauthority.gov.kh)

ដែលពាក់ព័ន្ធដើម្បីបង្កើតឱ្យមាននូវទីកន្លែងស្នាក់នៅរបស់ពួកគេ (សណ្ឋាគារ ផ្ទះសំណាក់) ការហូបចុក (ភោជនីយដ្ឋាន) កន្លែងកម្សាន្ត (ក្លឹប បៀរហ្គាដិន) សេវាសុខភាពមួយចំនួន និងសន្តិសុខយ៉ាងពេញលេញដល់ពួកគេ ក្នុងរយៈពេលដំណើរកម្សាន្តមួយដែលមិនអាចបំភ្លេចបាន។

❖ **ការគ្រប់គ្រងទឹក**

ទឹកគឺជាប្រភពមួយដ៏សំខាន់សម្រាប់កិច្ចការអភិរក្សប្រាង្គប្រាសាទ ក៏ដូចជាការលើកតម្លៃទេសភាពវប្បធម៌របស់តំបន់ឧទ្យានអង្គរទាំងមូល។ ដើម្បីឆ្លើយតបចំពោះការកង្វល់ពីបញ្ហាខ្វះទឹកនេះ ឯកឧត្តម **ហង់ ៣៧** អគ្គនាយករងទទួលបន្ទុកនាយកដ្ឋានគ្រប់គ្រងទឹក បានបញ្ជាក់ឱ្យដឹងថា អាជ្ញាធរជាតិអប្សរាមិនមានការព្រួយបារម្ភទេ ចំពោះការរក្សាទឹកទុកដើម្បីអភិរក្សប្រាង្គប្រាសាទក្នុងឧទ្យានអង្គរ ដោយហេតុថា កន្លងមកអាជ្ញាធរជាតិអប្សរាបានស្តារប្រើប្រាស់ឡើងវិញបានល្អនូវប្រព័ន្ធធារាសាស្ត្របុរាណ ហើយប្រព័ន្ធនេះបានបង្ហាញពីប្រសិទ្ធភាពក្នុងការរំដោះទឹកជំនន់ចេញពីរមណីយដ្ឋានអង្គរ ក៏ដូចជាតំបន់ក្រុងសៀមរាបទាំងមូល[43]។ មិនតែប៉ុណ្ណោះ ការស្តារឡើងវិញនូវប្រព័ន្ធប្រឡាយតូចៗជាច្រើនទៀត ដែលអាចធានាបាននូវការបញ្ចូលទឹកក្នុងកសិណប្រាសាទ ក៏ដូចជាបារាយណ៍បុរាណជាដើមនេះដែលអាចធ្វើឱ្យស្ថានភាពទឹកមានការគ្រប់គ្រងបានល្អ ចំពោះតំបន់ឧទ្យានអង្គរដែលជាបេតិកភណ្ឌពិភពលោក។ ឯកឧត្តមបានបន្ថែមថា កសិណអង្គរធំ កសិណអង្គរវត្ត និងបារាយណ៍ជ័យតដាកជាដើមនោះ ស្ថានភាពទឹកនៅមានលក្ខណៈល្អប្រសើរហើយទឹកក្រោមដីដែលមានក្នុងតំបន់ជុំវិញប្រាសាទធំៗក៏មិនមានបញ្ហាចោទដែរក្នុងពេលបច្ចុប្បន្ន ក៏ដូចជានៅក្នុងរយៈពេលមួយខែ ឬពីរខែទៀតទម្រាំរដូវវស្សាចូលមកដល់។ តែទោះជាក្នុងពេលបច្ចុប្បន្ននេះ ការគ្រប់គ្រងទឹកមានភាពល្អប្រសើរយ៉ាងណាក៏ដោយ អាជ្ញាធរជាតិអប្សរានៅតែបន្តការយកចិត្តទុកដាក់បន្ថែមទៀត ដោយហេតុថាពីមួយថ្ងៃទៅមួយថ្ងៃធម្មជាតិក៏មានការប្រែប្រួល មនុស្សរស់នៅ និងប្រើប្រាស់ទឹកក៏មានការកើនឡើង។ ចំពោះការប្រើប្រាស់ទឹកបារាយណ៍ ដែលជាអាងស្តុកទឹកដ៏ធំមួយដោយផ្ទាល់នេះ

[43] សៀវភៅកិច្ចការពាររមណីយដ្ឋានអង្គរ និងបញ្ហាដីធ្លី ខែឧសភា ឆ្នាំ២០០៥

អាចជួបនឹងបញ្ហាប្រឈមតែយើងកំពុងជំរុញឱ្យប្រជាពលរដ្ឋដាំដំណាំរួមផ្សំផ្សេងៗវិញដើម្បីកាត់បន្ថយការប្រើប្រាស់ទឹកនេះដោយផ្ទាល់ ហើយទុកទឹកបារាយណ៍នេះសម្រាប់ផ្គត់ផ្គង់ការប្រើប្រាស់ក្នុងទីក្រុងវិញ។

❖ **សណ្តាប់ធ្នាប់ និងសន្តិសុខសង្គម**

ជាការពិតណាស់ ការរៀបចំសណ្តាប់ធ្នាប់អ្នកលក់ដូរនៅក្នុងបរិវេណប្រាសាទ គឺជាភាពចាំបាច់បំផុតមួយដែលអាជ្ញាធរជាតិអប្សរានិងកម្លាំងពាក់ព័ន្ធ បាននឹងកំពុងដោះស្រាយនិងរៀបចំជាបន្តបន្ទាប់ឱ្យបានល្អប្រសើរ ព្រោះតំបន់អង្គរគឺជាសម្បត្តិបេតិកភណ្ឌពិភពលោក និងជាតំបន់ទេសចរណ៍ដ៏ល្បីល្បាញលើពិភពលោក ដែលមានភ្ញៀវទេសចរចូលមកទស្សនាឥតដាច់ជាច្រើនលាននាក់ក្នុងមួយឆ្នាំៗ។ ចំពោះការរៀបចំសណ្តាប់ធ្នាប់នេះផងដែរ អាជ្ញាធរ និងកម្លាំងដែលពាក់ព័ន្ធមិនត្រឹមតែបានរៀបចំតែនៅក្នុងតំបន់ប្រាសាទនោះទេ ការរៀបចំនេះក៏បានធ្វើឡើងនៅក្នុងទីក្រុងទាំងមូលផងដែរ។ ការរៀបចំនេះវាមានន័យទូលាយណាស់ពោលគឺ ធ្វើការការពារទាំងសន្តិសុខ សុវត្ថិភាពផ្សេងៗដល់ភ្ញៀវទេសចរ តាំងពីពេលដែលពួកគេបានមកដល់ទឹកដីនៃទីក្រុងអង្គរមកម្ល៉េះ។

❖ **កិច្ចសហប្រតិបត្តិការអន្តរជាតិ**

អាជ្ញាធរជាតិអប្សរាបានធ្វើការសហប្រតិបត្តិការ ជាមួយដៃគូជាច្រើនក្នុងកិច្ចការពារតំបន់អង្គរនេះ កិច្ចសហការទាំងនោះរួមមានបណ្តាប្រទេសជាច្រើនដូចជា **អូស្ត្រាលី** (គម្រោងគ្រប់គ្រងបេតិកភណ្ឌអង្គរ គម្រោងការស្រាវជ្រាវបុរាណវិទ្យាស្តីពីមហាអង្គរ គម្រោងវាលស្រែទៅជាបុរី គម្រោងរស់នៅជាមួយបេតិកភណ្ឌផ្សេងៗ) **ចិន** (គម្រោងការអភិរក្សប្រាសាទចៅសាយទេវតា គម្រោងជុសជុល និងអភិរក្សប្រាសាទតាកែវ) **សាធារណៈរដ្ឋឆេក** (ការជុសជុលប្រសាទភិមានអាកាស ការស្រាវជ្រាវលើការវិភាគថ្មផ្សេងៗ) **អង់គ្លេស** (គម្រោងភ្នំគូលែន គម្រោងLiDAR សំរាប់បុរាណវិទ្យាខ្មែរ)[44]។ល។ ដែលគម្រោង និងកិច្ចសហប្រតិបត្តិការទាំងនោះសុទ្ធសឹងតែមានបញ្ជាក់ពីកាលបរិច្ឆេទទឹកប្រាក់ក្នុងការដឹកនាំគម្រោងណាមួយឱ្យបានច្បាស់លាស់ចំគោលដៅ ដែលបានបញ្ជាក់ពីទីកន្លែងដែលត្រូវធ្វើការ

[44] សៀវភៅកិច្ចការពាររមណីយដ្ឋានអង្គរ និងបញ្ហាដីធ្លី ខែឧសភា ឆ្នាំ២០០៥

និងទទួលការយល់ព្រមពីអាជ្ញាធរអប្សរា ព្រមទាំងរាជរដ្ឋាភិបាលផងដែរ។ ក្រៅពីកិច្ចសហប្រតិបត្តិការជាមួយប្រទេសក៏នៅមានការសហការជាមួយគណៈកម្មាធិការផ្សេងៗដូចជា **អាយស៊ីស៊ីអង្គរ** (ICC) (ជាពាក្យកាត់មកពីភាសាអង់គ្លេស International Coordination Committee) ដែលមានន័យជាភាសាខ្មែរថា គណៈកម្មាធិការអន្តរជាតិ សម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍន៍តំបន់អង្គរ) និង ស្ថាប័នមួយចំនួនទៀត[45]។

❖ **ការបង្កើតសារមន្ទីរ**

សារមន្ទីរ គឺជាកន្លែងមួយដែលត្រូវបានគេបង្កើត ដើម្បីប្រមូលយកនូវវត្ថុបុរាណផ្សេងៗយកមករក្សាទុក ដើម្បីទុកឱ្យកូនចៅជំនាន់ក្រោយបានសិក្សាស្វែងយល់ ដែលក្នុងនោះគេបង្កើតបានសារមន្ទីរសំខាន់ៗដូចជា ៖

✓ **សារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ** ៖ សារមន្ទីរនេះកសាងឡើងក្រោមកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរជាតិអប្សរា និងសាកលវិទ្យាល័យសូហ្វីយ៉ា ដោយ"មូលនិធិនៃក្លឹប១%" របស់ក្រុមហ៊ុនអ៊ីអុង ដើម្បីដាក់តាំង និងតម្កល់ទុកជាវត្ថុបុរាណដែលបានរកឃើញក្នុងពេលសិក្សាស្រាវជ្រាវរបស់សាកលវិទ្យាល័យសូហ្វីយ៉ា។ ចាប់តាំងពីបើកដំណើរការទទួលភ្ញៀវចូលទស្សនាពីឆ្នាំ២០០៨មក សារមន្ទីរបានពង្រីកការតាំងពិព័រណ៍សមុច្ច័យរបស់ខ្លួនជាបន្តបន្ទាប់។ សព្វថ្ងៃនេះ សារមន្ទីរមានពិព័រណ៍អចិន្ត្រៃយ៍ ចំនួនបីដែលសុទ្ធសឹងតែជាលទ្ធផលនៃកំណាយស្រាវជ្រាវក្នុងតំបន់អង្គរ។ ពិព័រណ៍វត្ថុដែលយកចេញពីក្រោមដីទាំងនេះ នឹងនាំអស់លោកអ្នកឱ្យយល់កាន់តែច្បាស់ពីប្រាសាទនៅលើដី ដែលអស់លោកអ្នកបានទស្សនារួចមកហើយ ឬដែលអ្នកនឹងទៅទស្សនា។ លោកអ្នកនឹងទទួលបានការពន្យល់ជាភាសាខ្មែរ និងអង់គ្លេសពីមគ្គុទ្ទេសក៍ដែលបានបញ្ចប់ថ្នាក់បរិញ្ញាបត្របុរាណវិទ្យា[46]។

✓ **សារមន្ទីរកុលាលភាជន៍** ៖ តាំងពីយូរណាស់មកហើយ ការស្រាវជ្រាវស្តីពីអរិយធម៌អង្គរ ច្រើនផ្តោតតែទៅលើការសិក្សាអំពីសិលាចារឹក និងជាពិសេសផ្តោតទៅលើប្រាង្គប្រាសាទ និងសិល្បៈតែប៉ុណ្ណោះ។ ចំណែកឯការសិក្សាស្រាវជ្រាវស្តីពីកុលាលភាជន៍ គេពុំសូវមានការយកចិត្តទុកដាក់ទេហើយទើបតែគិតគូរនាពេលចុងក្រោយនេះទេ។ គេត្រូវរងចាំរហូតដល់ដើមទសវត្ស៦០

[45] គេហទំព័រអ៊ីនធើណិត អាជ្ញាធរជាតិអប្សរា

[46] គេហទំព័រអ៊ីនធើណិត អាជ្ញាធរជាតិអប្សរា

ទើបលោក **ប៊ែរណា ហ្វីលីប គ្រោលីយេ** (Bernard-Philippe Groslier) បានចាប់ផ្តើមធ្វើការសិក្សាអំពីកុលាលភាជន៍។ តែជាអកុសល ការស្រាវជ្រាវនោះក៏ត្រូវផ្អាកទៅទៀត ដោយសារព្រឹត្តិការណ៍ប្រទូសរ៉ាយនៅស្រុកខ្មែរយើង គឺរហូតមកដល់ពាក់កណ្តាលទសវត្ស៩០នេះ ទើបអ្នកស្រាវជ្រាវបានដឹងអំពីទីតាំងនៃឡបុរាណខ្មែរមួយចំនួន។ នៅដើមទសវត្ស៨០ គឺនាពេលដែលប្រទេសខ្មែរយើងកំពុងរឹករវរដោយសារសង្គ្រាម គេបានរៀបចំធ្វើពិព័រណ៍មួយស្តីពីកុលាលភាជន៍ខ្មែរនៅទីក្រុងសិង្ហបុរី ដោយគេបានប្រមូលផ្តុំកុលាលភាជន៍ ចំនួនប្រហែលមួយរយ ពីមជ្ឈដ្ឋានឯកជនមកតាំងបង្ហាញ។ អ្នកប្រាជ្ញបានចាត់ទុកថា ពិតជាមានកុលាលភាជន៍ខ្មែរ ដែលមានរចនាបថសិល្បៈប្លែកពីកុលាលភាជន៍ឯទៀតៗ ជាពិសេសមានឧស្សាហាកម្មដ៏រីកចំរើនតាំងពីដើមសម័យអង្គររហូតដល់ពេលដែលអង្គរត្រូវបានបោះបង់ចោល[47]។

ឧស្សាហាកម្ម កុលាលភាជន៍ខ្មែរ បានផលិតរបស់របរសម្រាប់បូជាសាសនា និងឧបករណ៍សម្រាប់ប្រជាពលរដ្ឋប្រើប្រាស់រៀងរាល់ថ្ងៃទៀតផង គឺវត្ថុទាំងនោះហើយ ដែលជាសក្ខីភាពឆ្លុះបញ្ចាំងឱ្យដឹងពីការរស់នៅរបស់សហគមន៍ខ្មែរ។

អង្គការដ៏ល្បីល្បាញពីរនៃប្រទេសជប៉ុន គឺវិទ្យាស្ថានណារ៉ា "Nara Institute" និងសាកលវិទ្យាល័យសូហ្វីយ៉ា "Sophia University" បានមកសហការជាមួយអាជ្ញាធរអប្សរា ចាប់ផ្តើមធ្វើកំណាយស្រាវជ្រាវស្តីពីរចនាសម្ព័ន្ធឡ ដំណើរការឡបុរាណ និងលទ្ធផលកុលាលភាជន៍នៅភូមិតានី នាឆ្នាំ១៩៩៦[48]។

✓ **សារមន្ទីរវាយនភ័ណ្ឌប្រពៃណីអាស៊ី អិម ជី ស៊ី** ៖ ផ្តើមបង្កើតឡើងដោយ ៦ប្រទេស ដោយរួមមានប្រទេស កម្ពុជា ឡាវ ឥណ្ឌា មីយ៉ាន់ម៉ា ថៃ និង វៀតណាម។ រដ្ឋមន្ត្រីនៃប្រទេសឥណ្ឌាក្នុងអំឡុងពេលដំណើរទស្សនកិច្ចមកកាន់ប្រទេសកម្ពុជានៅខែមេសាឆ្នាំ 2002 លោកបានប្រកាសផ្តល់នូវជំនួយឥតសំណងសម្រាប់ការបង្កើត "សារមន្ទីរវាយនភ័ណ្ឌប្រពៃណីអាស៊ី អិម ជី ស៊ី (MGC)" នៅខេត្តសៀមរាប ប្រទេសកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាបានបែងចែកដីមួយហិកតានៅក្នុងទីតាំងដល់សំខាន់មួយនៅក្នុងខេត្តសៀមរាបសម្រាប់គម្រោងនេះ។ ចំណែកឯគោលបំណងក្នុងការបង្កើតសារមន្ទីរវាយនភ័ណ្ឌប្រពៃណីអាស៊ី អិម ជី ស៊ី គឺធ្វើឡើងដើម្បីចូលរួមកិច្ចសហប្រតិបត្តិការក្នុងវិស័យទេសចរណ៍ វប្បធម៌ និងសម្រាប់ការអប់រំស្រាវជ្រាវជាដើម[49]។

---

[47]គេហទំព័រអ៊ីនធើណិត *អាជ្ញាធរជាតិអប្សរា* (www.apsaraauthority.gov.kh)

[48]គេហទំព័រអ៊ីនធើណិត *អាជ្ញាធរជាតិអប្សរា* (www.apsaraauthority.gov.kh)

[49]គេហទំព័រអ៊ីនធើណិត *អាជ្ញាធរជាតិអប្សរា* (www.apsaraauthority.gov.kh)

## ២.២ បញ្ហាប្រឈម និងដំណោះស្រាយ

យើងដឹងហើយថាការអភិវឌ្ឍន៍តែងតែជួបនិងផលប៉ះពាល់ទៅដល់មជ្ឈដ្ឋានជុំវិញ មិនថានៅទីកន្លែងណាក៏ដោយវាក៏មិនអាចជៀសផុតពី **បញ្ហាប្រឈម(២.២.១)** ប៉ុន្តែយើងក៏ត្រូវគិតពី **ដំណោះស្រាយ(២.២.២)** ឱ្យបានឆាប់រហ័ស និងទាន់ពេលវេលាឱ្យអ្នកដែលទទួលរងការប៉ះពាល់ផងដែរ។

### ២.២.១ បញ្ហាប្រឈម

- **ចំពោះការបង្កើតរមណីយដ្ឋានធម្មជាតិ**

យើងឃើញថាប្រជាជននៅក្នុងតំបន់អង្គរកំពុងមានកំណើនយ៉ាងឆាប់រហ័ស ហើយវាក៏អាចបង្កនូវផលវិបាកមួយចំនួនធំដល់ការអភិរក្សតំបន់នោះ ដោយសារតែទីនោះមិនអាចឱ្យមានប្រជាជនច្រើនលើសលប់ពេកទេវាអាចប៉ះពាល់ដល់សន្តិសុខសណ្តាប់ធ្នាប់ ម្យ៉ាងវិញទៀត កាលណាមានប្រជាជនរស់នៅច្រើនពេកជាមូលហេតុមួយនាំឱ្យមានបញ្ហាជាច្រើនដូចជា កង្វះលំនៅដ្ឋាន ខ្វះសេវាសាធារណៈដីស្រែចំការប្រកបរបរកសិកម្មចិញ្ចឹមជីវិត។ល។ ដោយមើលឃើញថា មានមូលហេតុច្រើនដូចនេះហើយ ទើបវាទាមទារឱ្យមានការបង្កើតនូវទីកន្លែងណាមួយដើម្បីធ្វើការជម្លៀសប្រជាជនខ្លះឱ្យទៅចាប់ផ្តើមនូវជីវភាពថ្មីរបស់ពួកគេ ក៏ដូចជាជួយក្នុងការរៀបចំតំបន់អង្គរឱ្យកាន់តែមានភាពទាក់ទាញផងដែរ។

- **ចំពោះកិច្ចការសំណង់**

ដោយសារតែកំណើនប្រជាជន បានកើនឡើងយ៉ាងឆាប់រហ័សនៅក្នុងតំបន់ឧទ្យានអង្គរ ជាហេតុនាំឱ្យមានតម្រូវការផ្សេងៗមានការកើនឡើងផងដែរ ដូចជាទីជម្រករបស់ពួកគេដែលជាកត្តាមួយដែលនាំឱ្យមាននូវការសាងសង់ខុសបច្ចេកទេស (សំណង់អនាធិបតេយ្យ) សំណង់ដែលសាងសង់ឡើងខុសពីការអនុញ្ញាតរបស់អាជ្ញាធរ (នាយកដ្ឋានសណ្តាប់ធ្នាប់ និងសហប្រតិបត្តិការរបស់អាជ្ញាធរជាតិអប្សរា សម្រេចដកហូតសម្ភារៈសំណង់មួយចំនួនពីម្ចាស់សំណង់ ឈ្មោះ **កែក ពូក** នៅភូមិចំបក់ ឃុំរលួស ស្រុកប្រាសាទបាគងដែលបានសាងសង់ខុសទៅនឹងផ្ទះខ្មែរ ដែលក្រុមជំនាញបានណែនាំ និងអនុញ្ញាតឱ្យធ្វើ) ការលួចលាក់សាងសង់សំណង់ (ក្រុមការងារនាយកដ្ឋានសណ្តាប់ធ្នាប់ និងកិច្ចសហប្រតិបត្តិការនៃអាជ្ញាធរជាតិអប្សរាចំនួន១០នាក់ បានធ្វើការចុះដកហូតសម្ភារៈសំណង់របស់លោកស្រី **ខូយ សុផល** អាយុ៣៦ឆ្នាំ

មានមុខរបរជាអ្នកលក់គ្រឿងសំណង់នៅក្នុងភូមិសណ្តាន់ សង្កាត់ទឹកវិល ក្រុងសៀមរាប ដែលលួចលាក់ធ្វើផ្ទះខុសច្បាប់ក្នុងតំបន់ឧទ្យានអង្គរជារៀងរាល់យប់)[50]។ ទាក់ទងទៅនិងបញ្ហាខាងលើនេះ ទោះបីជាមានការហាមឃាត់ពីសំណាក់អាជ្ញាធរយ៉ាងណាក៏ដោយ ក៏ប្រជាពលរដ្ឋមួយចំនួនតូចនៅតែមានការរឹងទទឹងបន្តនូវការសាងសង់របស់ខ្លួន ដែលនាំឱ្យមានការចាត់វិធានការណ៍ចុះអន្តរាគមពីសំណាក់អាជ្ញាធរដែលមានសមត្ថកិច្ច។

- **ចំពោះការការពារថែរក្សាប្រាសាទបុរាណ**

ចំពោះការការពារថែរក្សាប្រាសាទបុរាណ អាជ្ញាធរក៏បានធ្វើការគិតគូរយ៉ាងយកចិត្តទុកដាក់បំផុតប៉ុន្តែវាក៏នៅតែមាននូវផលអវិជ្ជមានខ្លះៗដែរ ដូចជា មានការធ្លាក់បាក់បែកនូវក្បូរក្បាច់រចនា និងផ្ទាំងសិលាផ្សេងៗនៅតាមប្រាសាទ បញ្ហាគ្រោះធម្មជាតិ ដូចជាខ្យល់ព្យុះ ទឹកជំនន់ជាដើមដែលនាំឱ្យមានប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅដល់ប្រាសាទ។ មួយវិញទៀត ចំពោះការជុសជុលយើងក៏ខ្វះខាតនូវប្រេភពធនធានមនុស្ស ខ្វះជំនាញស្ថាបត្យករដែលមានស្នាដៃដែលជាហេតុតម្រូវឱ្យយើងត្រូវទទួលយកស្ថាបនិកជាជនជាតិផ្សេងៗធ្វើការជុលជុលប្រាសាទបុរាណខ្មែរយើង។

- **ចំពោះការអភិរក្សព្រៃឈើ**

រមណីយដ្ឋានអង្គរដែលមានទំហំ៤០១គីឡូម៉ែត្រក្រឡា បានគ្របដណ្តប់ទៅដោយព្រៃឈើ៥.៧៣៧ហិកតា និងដីមិនមានគម្របព្រៃឈើ ៣៤.៣៧៨ហិចតា ព្រមទាំងមានប្រាសាទចំនួន៩១។ តាមប្រាសាទនីមួយៗមានដើមឈើដុះចម្រុះលាយឡំគ្នាជាច្រើននៅក្នុងបរិវេណប្រាសាទទាំងអស់នោះ។ ទន្ទឹមនឹងផ្តល់ប្រយោជន៍ដល់មនុស្ស និងប្រាសាទ ព្រៃឈើក៏អាចបង្កគ្រោះថ្នាក់មួយចំនួនផងដែរ ដូចជា ការដួលរលំ ឬបាក់មែកប៉ះពាល់ដល់រចនាសម្ព័ន្ធប្រាសាទ ឬមនុស្សដែលឆ្លងកាត់ជាដើម[51]។ ការផ្សព្វផ្សាយគឺជាកត្តាមួយសំខាន់ ប៉ុន្តែទោះបីមានការចុះផ្សព្វផ្សាយដល់ប្រជាពលរដ្ឋយ៉ាងណាក៏ដោយក៏នៅមានប្រជាពលរដ្ឋខ្លះពុំបានអនុវត្តទៅតាម ហើយនៅតែបន្តកាប់បំផ្លាញនូវព្រៃដែលអាជ្ញាធរនេះបានធ្វើការអភិរក្ស។

---

[50]គេហទំព័រអ៊ីនធើណិត *អាជ្ញាធរជាតិអប្សរា* (www.apsaraauthority.gov.kh)

[51] គេហទំព័រអ៊ីនធើណិត *អាជ្ញាធរជាតិអប្សរា* (www.apsaraauthority.gov.kh)

ជាក់ស្តែង នៅគ្រប់តំបន់ដែលអភិរក្សព្រៃឈើដែលបានកំណត់ដោយអាជ្ញាធរជាតិអប្សរា ប្រសិនបើប្រជាជននៅតែបន្តធ្វើការកាប់បំផ្លាញវានាំឱ្យមានផលប៉ះពាល់ដល់បរិស្ថាន និងអាចជួបទៅនិងគ្រោះធម្មជាតិ។ វាក៏អាចមានផលប៉ះពាល់មួយចំនួនដល់ប្រាសាទ ដោយសារតែព្រៃឈើវាផ្សារភ្ជាប់និងទឹក ហើយទឹកគឺជាបញ្ហាចម្បងទាក់ទងនិងប្រាសាទ បើកាប់ព្រៃជុំវិញប្រាសាទអស់ក៏ទឹកមិនអាចនៅបានដែរ។

- **ចំពោះហេដ្ឋារចនាសម្ព័ន្ធ និង កិច្ចការពារបរិស្ថាន**

បន្ទាប់ពីមាននូវការកសាងហេដ្ឋារចនាសម្ព័ន្ធជាច្រើនកន្លងមក យើងក៏ឃើញមាននូវបញ្ហាប្រឈមខ្លះៗផងដែរ ដូចជាការដឹកជញ្ជូនរបស់ប្រជាពលរដ្ឋ យើងឃើញថាពួកគាត់នៅតែមានការដឹកជញ្ជូនលើសទម្ងន់ដែលច្បាប់បានធ្វើការកំណត់ និងការធ្វើដំណើរឆ្លងកាត់ពុំស្របនិងផ្លូវដែលអាជ្ញាធរនេះបានធ្វើការរៀបចំឱ្យមានផ្លូវជិះម៉ូតូ-រថយន្តដោយឡែក និងផ្លូវកង់-ថ្មើរជើងដោយឡែក ដើម្បីសម្រួលដល់វិស័យទេសចរណ៍។

ចំណែកឯបរិស្ថាន កំពុងតែជួបប្រទះនូវការបំពុលយ៉ាងធ្ងន់ធ្ងរពីសំណាក់ភ្ញៀវទេសចរ និងប្រជាពលរដ្ឋដែលរស់នៅទីនោះដោយសារតែពួកគេពុំសូវយកចិត្តទុកដាក់ និងមិនមានចំណេះដឹងគ្រប់គ្រាន់លើបញ្ហាបរិស្ថាន។ ម៉្យាងវិញទៀត ទាក់ទងទៅនិងការគ្រប់គ្រងសំណល់គ្រប់ប្រភេទ យើងឃើញថានៅមានកម្រិតនៅឡើយ ពោលគឺទាក់ទងនិងការវេចខ្ចប់ ការដឹកជញ្ជូន ការបែងចែកសំណល់ កន្លែងទុកដាក់កាកសំណល់ទាំងអស់នោះពុំទាន់ត្រឹមត្រូវនៅឡើយទេ។ ដោយសារតែតំបន់នោះវាជារមណីយដ្ឋានទេសចរណ៍មួយលំដាប់ថ្នាក់ពិភពលោក ហេតុដូច្នេះហើយ វាទាមទារឱ្យបរិស្ថានក៏ត្រូវតែមានលក្ខណៈល្អប្រសើរទៅតាមនោះដែរ។

ជាងនោះទៅទៀត នៅក្នុងឧទ្យានអង្គរក៏នៅតែឃើញមានសត្វពាហនៈចូលមកស៊ីស្មៅនៅកន្លែងហាមឃាត់ជាញឹកញយ បើទោះបីជាធ្លាប់មានការហាមប្រាម និងអំពាវនាវពីសំណាក់អាជ្ញាធរជាតិអប្សរា ចំពោះម្ចាស់សត្វពាហនៈទាំងនោះឱ្យមើលសត្វពាហនៈរបស់ខ្លួនឱ្យបានល្អ[52]។

- **កសិកម្ម**

ចំណែកឯបញ្ហាប្រឈមដែលទាក់ទងទៅនិងផ្នែកកសិកម្មគឺ បណ្តាលមកពីប្រជាពលរដ្ឋពុំទាន់មានចំណេះដឹងគ្រប់គ្រាន់ទាក់ទងទៅនិងការដាំដុះ បង្កបង្កើនផលដែលអាចនាំឱ្យសេដ្ឋកិច្ចរបស់ប្រទេសមានការធ្លាក់ចុះមួយកម្រិតផងដែរ

[52] គេហទំព័រអ៊ីនធើណិត *អាជ្ញាធរជាតិអប្សរា* (www.apsaraauthority.gov.kh)

ដោយសារតែមានការចំណាយទៅលើការទិញសាច់ បន្លែ ផ្លែឈើ និងសម្ភារៈប្រើប្រាស់ពីខាងក្រៅប្រទេស។ ម៉្យាងទៀត ប្រជាពលរដ្ឋខ្លះទោះបីមានការខិតខំបង្ហាត់បង្រៀនពីសំណាក់អាជ្ញាធរដែលពាក់ព័ន្ធយ៉ាងណាក៏ដោយ ក៏ពួកគាត់នៅតែបន្តធ្វើកសិកម្មទៅតាមបែបបុរាណ និងប្រជាពលរដ្ឋខ្លះទៀតនៅតែបន្តការប្រើប្រាស់ជីគីមីដែលនាំឱ្យប៉ះពាល់ដល់បរិស្ថានយ៉ាងធ្ងន់ធ្ងរ និងសុខុមាលភាពរបស់អ្នកប្រើប្រាស់[53]។

❖ **ទេសចរណ៍ និង វប្បធម៌**

ដូចដែរយើងបានដឹងហើយថា អង្គរ មានន័យសំខាន់ណាស់ទៅលើសេដ្ឋកិច្ចចំពោះបងប្អូននៅក្នុងខេត្តសៀមរាប ហើយមានន័យសំខាន់សម្រាប់សេដ្ឋកិច្ចទាំងមូល។ ផ្ទុយទៅវិញ បើយើងបាត់បង់អង្គរ អង្គរថយតម្លៃ គឺស្មើនិងយើងបាត់បង់សេដ្ឋកិច្ចដែរ គឺសេដ្ឋកិច្ចសម្រាប់ប្រទេសទាំងមូលទៀតផង និងសេដ្ឋកិច្ចសម្រាប់ប្រជាពលរដ្ឋនៅក្នុងខេត្តសៀមរាប។ បើទេសចរណ៍មានការថយចុះ ភ្ញៀវសណ្ឋាគារក៏ត្រូវធ្លាក់ចុះត្រូវខាតដែរ និងអ្នកដែលធ្វើការនៅតាមសណ្ឋាគារក៏ត្រូវបាត់បង់ការងារ ហើយជុំវិញនេះមានការងារច្រើនណាស់ដូចជា លក់តវ៉ាន់ លក់វត្ថុអនុស្សាវរីយ៍ជាដើម។

ទោះបីជាមានការរៀបចំនូវបដិសណ្ឋារកិច្ចយ៉ាងណាក៏ដោយ ក៏នៅតែមានបញ្ហាខ្លះបានកើតឡើងរួមមាន បញ្ហាតម្លៃ សេវាកម្ម គុណភាព និងបរិមាណជាដើម។ បញ្ហាទាំងនេះកើតចេញពីយើងដែលជាម្ចាស់ផ្ទះ ធ្វើឱ្យអ្នកទេសចរមានការមិនពេញចិត្ត ជាហេតុនាំឱ្យមានតំហាយនៃភ្ញៀវទេសចរដែលនាំឱ្យថវិកាជាតិធ្លាក់ចុះ និងបាត់បង់ចំណូលមួយផ្នែករបស់ប្រជាពលរដ្ឋផងដែរ។

ចំពោះភ្ញៀវទេសចរវិញ ក៏មានភ្ញៀវមួយចំនួនមិនព្រមគោរពទៅតាមគោលការណ៍ដែលអាជ្ញាធរបានដាក់ឱ្យផងដែរ (ហាមមិនឱ្យស្លៀកពាក់សិចស៊ី និងពាក់ស្បែកជើងកែងក្នុងប្រាសាទ) ដែលនាំឱ្យមានផលប៉ះពាល់ដល់ប្រាសាទ និងវប្បធម៌អរិយធម៌ជាតិខ្មែរ[54]។ មិនត្រឹមតែប៉ុណ្ណោះ ក្រុមហ៊ុនមួយចំនួនក៏បានធ្វើអាជីវកម្មនៅក្នុងតំបន់នោះដែលផ្ទុយពីទំនៀមទម្លាប់ប្រពៃណីរបស់ខ្មែរ (ការថតរូបអាសអាភាសនៅក្នុងបរិវេណអង្គរ ដើម្បីផ្សព្វផ្សាយពីផលិតផលរបស់ខ្លួនជាដើម)។

---

[53] សៀវភៅកិច្ចការពាររមណីយដ្ឋានអង្គរ និងបញ្ហាដីធ្លី ខែ ឧសភា ឆ្នាំ២០០៥

[54] គេហទំព័រអ៊ីនធើណិត *អាជ្ញាធរជាតិអប្សរា* (www.apsaraauthority.gov.kh)

❖ **ការគ្រប់គ្រងទឹក**

បើយើងធ្វើការសង្កេតមើលពីទឹកវិញ យើងដឹងហើយថានៅកម្ពុជាយើងបានចែកជា ២រដូវកាលធំៗ គឺរដូវប្រាំង និងរដូវវស្សា ដែលបច្ចុប្បន្ននេះគ្រោះរាំងស្ងួតមានរយៈកាលយូរជាងរដូវវស្សា ទោះបីនៅក្នុងរដូវវស្សាក៏មានកូនរដូវប្រាំងក្នុងនោះដែរដែលនាំឱ្យកើតមានគ្រោះរាំងស្ងួត ខ្វះខាតទឹកប្រើប្រាស់ ខ្វះខាតទឹកក្នុងការធ្វើកសិកម្ម និងដាំដំណាំក្នុងការប្រកបរបរចិញ្ចឹមជីវិតផ្សេងៗ។ ទាក់ទងនិងបញ្ហានេះដែរ ពេលខ្លះអាជ្ញាធរជាតិអប្សរាបានចេញសេចក្តីប្រកាសផ្សេងៗ ដើម្បីទប់ស្កាត់បានការបង្ហូរទឹកពីទីកន្លែងមួយទៅទីកន្លែងមួយទៀត។ អ្វីដែលពិសេសជាងនេះទៅទៀត ទឹកនៅក្នុងបរិវេណអង្គរ វាជាគ្រឹះមួយដ៏សំខាន់ដើម្បីទប់លំនឹងដល់ប្រាសាទឱ្យមានភាពរឹងមាំគង់វង្សឱ្យបានយូរអង្វែង ប៉ុន្តែពេលខ្លះវាបានជួបបញ្ហាដោយទឹកនៅជុំវិញប្រាសាទបានស្រកស្រុតហួសពីសមាមាត្រដែលជាតម្រូវការរបស់គ្រឹះអង្គរ។ រីឯក្នុងខែវស្សាវិញ អាចនឹងមានភ្លៀងច្រើនពេកក្លាយជាទឹកជំនន់ជន់លិចទៅវិញ។ ហេតុដូចនេះ វាទាមទារឱ្យអាជ្ញាធរជាតិអប្សរា និងក្រសួងដែលពាក់ព័ន្ធធ្វើការដោះស្រាយ ព្រមទាំងចាត់វិធានការទៅលើបញ្ហាទាំងនោះ។

❖ **សណ្តាប់ធ្នាប់ សន្តិសុខសង្គម**

ក្នុងពេលកន្លងមកនេះ មានភ្ញៀវទេសចរជាតិនិងអន្តរជាតិជាច្រើន តែងតែរិះគន់និងត្អូញត្អែរពីការដាក់លក់ភេសជ្ជៈ និងវត្ថុអនុស្សាវរីយ៍គ្មានសណ្តាប់ធ្នាប់ ហើយទន្ទឹមនឹងនេះដែរ ក៏មានមគ្គុទ្ទេសក៍ទេសចរណ៍មួយចំនួនធំបានរិះគន់ និងរាយការណ៍ពីការរំខាន និងជេរប្រមាថដល់ភ្ញៀវទេសចរដែលមិនព្រមទិញវត្ថុអនុស្សាវរីយ៍ផងដែរ[55]។ ចំពោះបញ្ហាសន្តិសុខសុវត្ថិភាពវិញ ទោះបីមានការការពារយ៉ាងណាក៏ដោយ ក៏យើងនៅតែសង្កេតឃើញពីភាពមិនប្រក្រតីមួយចំនួនដូចជា អំពើចោរកម្ម គ្រោះថ្នាក់ចរាចរណ៍។ល។

**២.២.២ ដំណោះស្រាយ**

[55] គេហទំព័រអ៊ីនធើណិត *អាជ្ញាធរជាតិអប្សរា* (www.apsaraauthority.gov.kh)

បន្ទាប់ពីយើងបានមើលឃើញពីសមិទ្ធផល និងបញ្ហាប្រឈមទាំងអស់កន្លងមកដែលអាជ្ញាធរបានជួបប្រទះ ពេលនេះយើងមកមើលពីដំណោះស្រាយ ថាតើវាមានដំណោះស្រាយយ៉ាងណាខ្លះទៅលើបញ្ហាទាំងអស់នោះ។ ដំណោះស្រាយសំខាន់ៗរបស់អាជ្ញាធរអប្សរារួមមាន ៖

- ដំណោះស្រាយចំពោះការបង្កើតរមណីយដ្ឋានធម្មជាតិ

ដោយសារតែកំណើនប្រជាជនមានការកើនឡើងយ៉ាងឆាប់រហ័ស និងដោយមិនអាចឱ្យមានប្រជាជនច្រើនលើសលប់ពេករស់នៅតំបន់ឧទ្យានអង្គរក៏នាំឱ្យមានបញ្ហាកំណើនប្រជាជនកើតមានឡើង ដែលរាជរដ្ឋាភិបាលបានពិចារណារកឃើញដំណោះស្រាយថ្មីមួយគឺត្រូវបង្កើតតំបន់អភិវឌ្ឍថ្មីមួយទៀតដែលស្ថិតនៅក្រៅតំបន់ឧទ្យានការពារហើយសម្រាប់ឱ្យគ្រួសារថ្មីថ្មោងទៅតាំងទីលំនៅស្ថានថ្មីនៅទីនោះ។ ការបំបែកគ្រួសារឱ្យទៅរស់នៅទីតាំងថ្មីនេះគឺត្រូវបានធ្វើឡើងដោយមានការស្ម័គ្រចិត្តឥតមានការបង្ខិតបង្ខំអ្វីឡើយ។ គ្រួសារថ្មីណាដែលមិនចង់បែកផ្ទះសម្បែងពីគ្រួសារដើមរបស់ខ្លួន អាចបន្តការរស់នៅជាមួយឪពុកម្តាយតទៅទៀត គ្រាន់តែមិនអាចសង់ផ្ទះថ្មីបន្ថែមនៅក្នុងតំបន់ការពារតែប៉ុណ្ណោះ។

ដូចនេះ រាជរដ្ឋាភិបាល បានដោះស្រាយដីទំហំ ១,០១២ ហិចតា នៅក្រៅតំបន់ការពារប៉ែកខាងកើតក្នុងឃុំរុនតាឯក ស្រុកបន្ទាយស្រី ខេត្តសៀមរាប ចំងាយប្រមាណជា២០គីឡូម៉ែតពីក្រុងអង្គរ[56]។ គម្រោងរៀបចំអភិវឌ្ឍភូមិធម្មជាតិរុនតាឯកក៏បានចាប់បដិសន្ធិឡើងក្នុងខណៈនោះ។ គេអាចបង្កើតជាច្រើនក្រុមលំនៅដ្ឋាននៅក្បែរមាត់បឹងធម្មជាតិ។ ជាដំណាក់ការទី១ ក្រុមជាលាធំត្រូវបានរៀបចំសម្រាប់ប្រមាណ ២០០គ្រួសារ។

នាពេលបច្ចុបន្បន្ន ៧៥គ្រួសារបានកសាងផ្ទះ និងរស់នៅជាប្រចាំដោយបានទទួលការឧបត្ថម្ភពីអាជ្ញាធរអប្សរានូវឈើ ស័ង្កសី ជើងសសរ និងចានបង្គន់អនាម័យ។ ក្រៅពីនោះ ប្រជាជនបានទទួលការឧបត្ថម្ភផ្នែកកសិកម្ម ដូចជាគ្រាប់ពូជបន្លែ និងមាន់ទាផង។ រីឯដីសម្រាប់ធ្វើការដាំដុះ ក៏បានចែកជូនគ្រប់គ្រួសារសរុបទៅគ្រួសារនីមួយៗបានទទួលដីទំហំប្រមាណ១ហិចតា។ ហេដ្ឋារចនាសម្ព័ន្ធដូចជា ប្រព័ន្ធទឹក

[56] ខែក ខេមរ៉ាត, វីដេអូឯកសារ កម្មវិធីសមធម៌ទី១៨០ ពន្ធលើអចលនទ្រព្យ + អាជ្ញាធរអប្សរា, ទូរទស្សន៍ជាតិកម្ពុជា, មិនា ២០០១

ផ្លូវថ្នល់ សាលារៀន ក៏បានសាងសង់រួចជាស្រេច។ ប្រជាជនក៏បានរៀបចំជាសហគមន៍ ហើយមានការរៀបចំសម្រាប់ទទួលភ្ញៀវបរទេសស្នាក់នៅក្នុងផ្ទះអ្នកស្រុកបានទៀតផង[57]។

- ចំពោះដំណោះស្រាយបញ្ហាសំណង់វិញ ដោយសារតែតំបន់ឧទ្យានអង្គរ គឺជាតំបន់មួយដែលត្រូវបានគេអភិរក្សដើម្បីបង្ហាញពីទំនៀមទម្លាប់ខ្មែរ ហេតុដូចនេះហើយ ទាក់ទងនិងបញ្ហាសំណង់ លំនៅស្ថានផ្សេងៗក៏ត្រូវតែមានលក្ខណៈជារបៀបខ្មែរផងដែរ។ ចំពោះសំណង់ដែលពុំបានគោរពទៅតាមបែបបទជាខ្មែរ អាជ្ញាធរជាតិអប្សរាបានសហការជាមួយអាជ្ញាធរដែលពាក់ព័ន្ធធ្វើការដោះស្រាយ ដោយណែនាំឱ្យប្រជាពលរដ្ឋយល់ដឹងក្នុងការសាងសង់សំណង់ទៅតាមបែបខ្មែរ និងស្របទៅតាមទីតាំងភូមិសាស្ត្រដែលបានអនុញ្ញាតដោយអាជ្ញាធរ។ ប៉ុន្តែប្រសិនបើពួកគេនៅតែមិនព្រមគោរពតាមហើយនៅតែបន្តការសាងសង់ អាជ្ញាធរក៏មានវិធានការមួយចំនួនដូចជា ចេញសេចក្តីជូនដំណឹង ចេញលិខិតស្នាមផ្សេងៗ ដើម្បីបញ្ឈប់កែប្រែសំណង់នោះ ឬធ្វើការរុះរើ រឹបអូសជាដើម[58]។

- ការអភិរក្សថែរក្សាប្រាសាទបុរាណ

ដោយសារតែប្រាសាទបុរាណយើងមានអាយុកាលយូរ វាតែងតែមាននូវការបាក់បែកខ្លះៗពីកត្តាផ្សេងៗទាក់ទងទៅនិងបញ្ហានេះដែរ អាជ្ញាធរជាតិអប្សរាក៏បានរៀបចំនូវវគ្គបណ្តុះបណ្តាល ដើម្បីបង្កើនសមត្ថភាពខាងផ្នែកធនធានមនុស្ស និង បានបញ្ជូនសិក្ខាកាមឱ្យទៅសិក្សាស្រាវជ្រាវនៅក្រៅប្រទេស ដើម្បីការអភិវឌ្ឍន៍ប្រទេសនៅពេលអនាគត[59]។ ចំពោះបញ្ហាធម្មជាតិវិញដើម្បីបង្ការកុំឱ្យលិច ឬដក់ទឹកនៅតាមផ្លូវដើរ ឬបរិវេណផ្សេងៗក្នុងប្រាសាទនោះ អាជ្ញាធរជាតិអប្សរាបានធ្វើការជួសជុលប្រព័ន្ធបង្ហូរទឹកបុរាណដែលមានស្រាប់មួយចំនួនដើម្បីប្រើប្រាស់ឡើងវិញ ចំណែកតាមផ្លូវដើរក្នុងបរិវេណប្រាសាទមួយចំនួនជាផ្លូវដីដែលមានតាំងពីបរមបុរាណមកនោះ អាជ្ញាធរជាតិអប្សរាបានលើកដីបន្ថែមឱ្យខ្ពស់បន្តិច

---

[57] គេហទំព័រអ៊ីនធើណិត *អាជ្ញាធរជាតិអប្សរា* (www.apsaraauthority.gov.kh)

[58] សៀវភៅកិច្ចការពាររមណីយដ្ឋានអង្គរ និងបញ្ហាដីធ្លី ខែឧសភា ឆ្នាំ២០០៥

[59] គេហទំព័រអ៊ីនធើណិត *អាជ្ញាធរជាតិអប្សរា* (www.apsaraauthority.gov.kh)

ហើយធ្វើប្រឡាយអមសងខាងផ្លូវដើម្បីបង្ហូរទឹកចេញតាមប្រឡាយបុរាណដែលមានស្រាប់ ឬប្រឡាយដែលបានរៀបចំថ្មី[60]។

- ចំពោះបញ្ហាព្រៃឈើ បន្ទាប់ពីមានសមិទ្ធផល និង បញ្ហាប្រឈមជាច្រើនកន្លងមក យើងឃើញថាក្នុងដំណោះស្រាយនោះគឺ ទទួលបាននូវផ្លែផ្កាដ៏ល្អមួយកម្រិតគឺដោយសារប្រជាជនមានការជ្រួតជ្រាបពីបញ្ហានេះ និងសារៈប្រយោជន៍នៃព្រៃឈើ ប៉ុន្តែកន្លែងអភិរក្សខ្លះទៀតក៏តម្រូវឱ្យមានកងកម្លាំងដើម្បីចាំការពារជាប់ជានិច្ចផងដែរ ហើយស្ថាប័នដែលពាក់ព័ន្ធបានធ្វើការដាក់ទណ្ឌកម្មចំពោះរាល់បទល្មើសដែលបុគ្គលនោះបានប្រព្រឹត្ត និងជំរុញលើកទឹកចិត្តឱ្យប្រជាជនដាំដើមឈើបន្ថែមឡើងវិញ។

- បញ្ហាបរិស្ថាន គឺជាធាតុដ៏សំខាន់ដែលធ្វើឱ្យរមណីយដ្ឋានអង្គរមានសម្រស់ស្រស់បំព្រង ទាក់ទាញនូវចំណាប់អារម្មណ៍របស់ភ្ញៀវទេសចរមកទស្សនាកាន់តែខ្លាំងបន្ថែមទៅលើប្រាង្គប្រាសាទបុរាណដ៏ល្អឯកដែលមានស្រាប់។ អាជ្ញាធរជាតិអប្សរាបានយកចិត្តទុកដាក់ជាខ្លាំងទៅលើបញ្ហានេះ។ ដូច្នេះហើយតាំងពីឆ្នាំ២០០៤មក អាជ្ញាធរជាតិអប្សរាបានចុះឈ្មោះដើម្បីទទួលការវាយតម្លៃបរិស្ថានពីស្ថាប័នធានាគុណភាពជប៉ុន ហៅកាត់ថាJQA និងទទួលបានវិញ្ញាបនបត្រ ISO14001 ពីស្ថាប័ននេះរយៈពេល៤លើករួចមកហើយ[61]។ នៅក្នុងន័យនេះ អាជ្ញាធរជាតិអប្សរា បានធ្វើសកម្មភាពការពារថែរក្សាបរិស្ថានជាច្រើនទម្រង់ ដូចជាការបង្កើតអង្គភាពប្រព័ន្ធគ្រប់គ្រងបរិស្ថាន EMS ការបណ្តុះបណ្តាលអំពីបរិស្ថានតាមគ្រឹះស្ថានសិក្សាក្នុងតំបន់រមណីយដ្ឋានអង្គរ និងអប់រំប្រជាពលរដ្ឋ ព្រះសង្ឃអំពីការថែរក្សាបរិស្ថានជាដើម និងជៀសវាងនូវការបំផ្លាញព្រៃឈើរាល់គ្រប់រូបភាព ។ ក្រៅពីនេះមានការរៀបចំកម្មវិធីបរិស្ថានប្រចាំឆ្នាំ និងបានចូលរួមជាមួយនិងស្ថាប័នការពារបរិស្ថានផ្សេងៗទៀតជាប្រចាំ[62]។

- បញ្ហាកសិកម្ម អាជ្ញាធរជាតិអប្សរាបានសហការជាមួយស្ថាប័នដែលពាក់ព័ន្ធ និងកំពុងខិតខំចុះជួយដល់ប្រជាជន ក្នុងការពន្យល់ណែនាំដល់ប្រជាពលរដ្ឋឱ្យបានយល់ដឹងច្បាស់ពី

---

[60] សៀវភៅកិច្ចការពាររមណីយដ្ឋានអង្គរ និងបញ្ហាដីធ្លី ខែឧសភា ឆ្នាំ២០០៥

[61] គេហទំព័រអ៊ីនធើណិត *អាជ្ញាធរជាតិអប្សរា* (www.apsaraauthority.gov.kh)

[62] សៀវភៅកិច្ចការពាររមណីយដ្ឋានអង្គរ និងបញ្ហាដីធ្លី ខែឧសភា ឆ្នាំ២០០៥

សារៈប្រយោជន៍នៃការធ្វើកសិកម្មតាមបែបទំនើប និងបានផ្តល់នូវគ្រាប់ពូជល្អៗ ព្រមទាំងបង្រៀនពីរបៀបដាំដុះដល់ពួកគាត់ផងដែរ។ ជាងនេះទៅទៀត ចំពោះផលិតផលដែលបានពីការការដាំដុះរបស់ពួកគាត់ គឺត្រូវលើកទឹកចិត្តដល់ប្រជាកសិករដោយស្វែងរកនូវទីផ្សារទទួលទិញនូវផលិតផលនោះនៅក្នុងតម្លៃសមរម្យមួយ ដែលវាគឺជាកត្តាមួយដែលអាចជួយជំរុញឱ្យពួកគាត់មានទឹកចិត្តបន្តធ្វើទៀត ហើយក៏អាចជួយដល់សេដ្ឋកិច្ចរបស់ពួកគាត់ និងប្រទេសជាតិឱ្យកាន់តែប្រសើរឡើងផងដែរ[63]។

- ចំពោះបញ្ហាទេសចរណ៍ និងវប្បធម៌ ដំណោះស្រាយមួយដ៏ល្អបំផុតទៅលើបញ្ហាប្រឈមកន្លងមកគឺ រឹតបន្តឹងទៅលើលក្ខន្តិកៈផ្សេងៗដែលអាជ្ញាធរបានកំណត់។
- ពាក់ព័ន្ធបញ្ហាការគ្រប់គ្រងទឹក រយៈកាលកន្លងមកអាជ្ញាធរជាតិអប្សរា និងក្រសួងដែលពាក់ព័ន្ធបានធ្វើការដោះស្រាយ និងចាត់វិធានការលើបញ្ហាទាំងនោះផងដែរដោយអាជ្ញាធរជាតិអប្សរាបានធ្វើការជីកស្រះទឹក ជីកអណ្តូងទឹក ធ្វើការស្តារឡើងវិញនូវអាងស្តុកទឹកចាស់ៗមួយចំនួនទៀតដូចជាទន្លេស្ងួត ដែលស្ថិតនៅខាងលិចប្រាសាទព្រះខ័ន និងបារាយណ៍ឥន្ទ្រតដាកជាដើមដើម្បីធានាឱ្យមានភាពសមាមាត្រជាមួយនឹងកំណើនភ្ញៀវទេសចរក្នុងពេលអនាគត និងតម្រូវការរបស់ប្រជាពលរដ្ឋសំរាប់ទុកឱ្យប្រជាជនប្រើប្រាស់ ក៏ដូចជាធ្វើជាគ្រឹះរបស់ប្រាសាទផងដែរ ។ ពេលខ្លះដោយមើលឃើញពីភាពចាំបាច់ពីទឹកនៅបារាយណ៍ ដែលវាមានទំនាក់ទំនងជាមួយនិងគ្រឹះប្រាសាទនោះ។ ពេលខ្លះដោយសារការអនុវត្តន៍ទៅតាមសារាចរណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីកង្វះខាតទឹកប្រើប្រាស់ដោយសាររដូវប្រាំងឆ្នាំនេះអូសបន្លាយពេលយូរ នាយកដ្ឋានគ្រប់គ្រងទឹកនៃអាជ្ញាធរជាតិអប្សរា នៅព្រឹកថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៦នេះ បានប្រកាសផ្អាកការផ្គត់ផ្គង់ទឹកជូនសហគមន៍ ដែលប្រើប្រាស់ទឹកបារាយណ៍សម្រាប់ស្រោចស្រពដំណាំកសិកម្ម។ ការប្រកាសផ្អាកនៅពេលនេះ គឺដើម្បីរក្សាទឹកខ្លះឱ្យនៅសល់នៅបាតបារាយណ៍ជាជម្រាបសម្រាប់ផ្គត់ផ្គង់អណ្តូង និងប្រភពទឹកប្រើប្រាស់ប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ[64]។

[63] សៀវភៅកិច្ចការពាររមណីយដ្ឋានអង្គរ និងបញ្ហាដីធ្លី ខែឧសភា ឆ្នាំ២០០៥

[64] គេហទំព័រអ៊ីនធើណិត *អាជ្ញាធរជាតិអប្សរា* (www.apsaraauthority.gov.kh)

នេះគឺជាការសរបញ្ជាក់អំពីដំណោះស្រាយមួយទៅលើការថែរក្សាគ្រឹះរបស់ប្រាសាទ។ អាជ្ញាធរជាតិអប្សរា និងអង្គភាពដែលពាក់ព័ន្ធបានបង្កើត និងថែរក្សានូវទីតាំងសំណង់ទ្វារទឹក និងអាងស្តុកទឹកជាច្រើនដែលមានដូចជា ស្រះស្រង់ ក្រាំងក្រូច វង់ទស្សនាចរបារាយណ៍ខាងជើង សំណង់បញ្ចូលទឹកបារាយណ៍ខាងជើង សំណង់ទ្វារទឹកតាសោម សំណង់ស្ទាក់ខ្យាច់អង្គរវត្ត ប្រាសាទព្រះខ័ន ប្រាសាទនាគព័ន្ធ បារាយណ៍ខាងលិច សំណង់បង្ហៀរទឹកបារាយណ៍ខាងលិច សំណង់ទ្វារទឹកចេញ សំណង់បែងចែកទឹក និងប្រព័ន្ធស្រោចស្រពបារាយណ៍ខាងលិចដោយផ្តោតសំខាន់ទៅលើប្រវត្តិ និងមុខងារសំណង់នីមួយៗ ប្រព័ន្ធប្រឡាយ ការបញ្ចូលទឹក ការគ្រប់គ្រងទឹក ការងារជួសជុល និងស្តារឡើងវិញនូវប្រព័ន្ធផ្លូវទឹកបុរាណផងដែរ[65]។

- ដំណោះស្រាយអំពីបញ្ហាសន្តិសុខ និងសណ្តាប់ធ្នាប់នេះ យើងសង្កេតឃើញថាមានចំណាត់ការមួយចំនួនដោយបានចាត់នូវភ្នាក់ងារជំនាញរបស់អាជ្ញាធរជាតិអប្សរា សហការជាមួយនិងកម្លាំងពាក់ព័ន្ធតែងតែចុះទៅធ្វើការពន្យល់ណែនាំទៅដល់ពួកគាត់ អំពីផលប៉ះពាល់ដល់ សណ្តាប់ធ្នាប់ និងទេសភាពតំបន់ទេសចរណ៍ក៏ដូចជាប៉ះពាល់ និងរំខានដល់ការទស្សនារបស់ភ្ញៀវទេសចរ នឹងបានណែនាំឱ្យប្តូរទីតាំងលក់ទៅកន្លែងសមរម្យតែបើពួកគាត់មិនព្រមធ្វើតាមការរៀបចំនោះទេ អាជ្ញាធរក៏បានធ្វើការរុះរើទីតាំងទាំងនេះគឺដើម្បីការពារសណ្តាប់ធ្នាប់ និងលើកកម្ពស់គុណតម្លៃប្រាសាទឱ្យសាកសមជាតំបន់ទេសចរណ៍វប្បធម៌ ដែលជាសម្បត្តិបេតិកភណ្ឌពិភពលោក និងដើម្បីធានាការអភិវឌ្ឍន៍វិស័យទេសចរណ៍ប្រកបដោយចីរភាព។ ចំណែកឯការរៀបចំសណ្តាប់ធ្នាប់ទូទៅក្នុងក្រុង និង តំបន់កម្សាន្តផ្សេងៗក៏មានការរឹតបន្តឹងផ្នែកច្បាប់ផងដែរ។

## សន្និដ្ឋាន

អាជ្ញាធរជាតិអប្សរាត្រូវបានគេបង្កើតឡើង មិនមែនគ្រាន់តែសំរាប់គ្រប់គ្រងនូវអប្សរាដែលជារូបសិលាថ្មដែលនៅជាប់និងប្រាង្គប្រាសាទនោះទេ ពោលគឺវាបង្កើតឡើងនៅក្នុងគោលបំណង អភិរក្ស ការពារ ជុលជុល និងអភិវឌ្ឍនៅក្នុងតំបន់អង្គរទាំងអស់។

[65]គេហទំព័រអ៊ីនធើណិត *អាជ្ញាធរជាតិអប្សរា* (www.apsaraauthority.gov.kh)

អាជ្ញាធរមួយនេះបង្កើតឡើងនៅក្នុងគោលដៅមួយដែលមានចក្ខុវិស័យធំទូលាយក្នុងដែនសមត្ថកិច្ចមួយច្បាស់លាស់ វាត្រូវបានចូលរួមសហការ ប្រតិបត្តិការជាមួយនិងក្រសួងស្ថាប័នពាក់ព័ន្ធជាច្រើន ដើម្បីធ្វើយ៉ាងណាឱ្យប្រាសាទគង់វង្សហើយក៏ មានការអភិវឌ្ឍន៍នៅក្នុងតំបន់នោះផងដែរ។ ក្រៅពីការយកចិត្តទុកដាក់លើការងារអភិរក្ស និងអភិវឌ្ឍប្រកបដោយចីរភាពក្នុងតំបន់រមណីយដ្ឋានអង្គរ ក្នុងនោះទៀតសោតអាជ្ញាធរជាតិអប្សរាក៏បានធ្វើសកម្មភាពមួយចំនួនក្នុងគោលដៅដើម្បីសង្គមដើម្បីមនុស្សធម៌ទៅលើគ្រប់វិស័យទាំងអស់ដោយរួមមានការសហការជាមួយគ្រូពេទ្យស្ម័គ្រចិត្តមកពីបណ្តាប្រទេសផ្សេងៗ ដើម្បីរៀបចំកម្មវិធីត្រួតពិនិត្យសុខភាពជូនប្រជាជនក្នុងតំបន់អង្គរដោយឥតគិតថ្លៃ។ ម៉្យាងវិញទៀតអាជ្ញាធរជាតិអប្សរាក៏បានយកចិត្តទុកដាក់ជាប្រចាំចំពោះសុខទុក្ខបងប្អូនប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់រមណីយដ្ឋាននោះផងដែរ នៅពេលដែលពួកគាត់ជួបទុក្ខនូវលំបាកដោយបាននាំយកជាអំណោយខ្លះៗទៅជូនគ្រួសារណាដែលទទួលរងអគ្គីភ័យឆេះផ្ទះ គ្រោះទឹកជំនន់ ខ្យល់ព្យុះ និងនាំយកនូវកញ្ចប់ថវិកាសម្រាប់ទ្រទ្រង់ម្តាយនិងទារកនៅពេលដែលគាត់បានសម្រាលបុត្រនៅតាមមន្ទីរពេទ្យ និងនៅតាមមណ្ឌលសុខភាពព្រមទាំងបានផ្តល់ជំនួយដល់មនុស្សចាស់ជរា កុមារកំព្រា ជនពិការ និងបុគ្គលដែលគ្មានទីពឹងជាច្រើនទៀត។

បន្ទាប់ពីយើងបានបង្កើតអាជ្ញាធរនេះអស់រយៈកាលប្រមាណជាង២៣ឆ្នាំកន្លងមក យើងបានឃើញយ៉ាងជាក់ច្បាស់ពីសមិទ្ធផលជាច្រើនដែលបានរៀបរាប់ក្នុងខ្លឹមសារខាងលើ វាបានសរបញ្ជាក់ឱ្យយើងឃើញថាអាជ្ញាធរនេះ មិនត្រឹមតែគិតគូរប្រាង្គប្រាសាទថ្មនោះទេ សុខទុក្ខរបស់ប្រជាពលរដ្ឋក៏ជាកត្តាមួយដែលសំខាន់នៅក្នុងគោលដៅអភិវឌ្ឍនូវផែនការគោលរបស់អាជ្ញាធរនេះផងដែរ។ ចំពោះការបង្កើតអាជ្ញាធរអប្សរាពិតជាមានសារៈសំខាន់ខ្លាំង ដោយសារតែស្ថាប័នមួយនេះធ្វើការគ្រប់គ្រងលើតំបន់អង្គរ ហើយអង្គរជាអច្ឆរិយៈភាពមួយសំរាប់ប្រទេសហើយបានទាក់ទាញនូវប្រភពចំណូលមួយយ៉ាងសំខាន់សម្រាប់ប្រទេស និងប្រជាពលរដ្ឋទាំងអស់។ ម្យ៉ាងទៀតវាក៏ជាមោទនៈភាពមួយដែរ ដោយសារតែយើងបានឃើញពីការលះបង់អស់ពីកម្លាំងកាយចិត្តគិតគូរគ្រប់ជំហានសំខាន់ៗសម្រា

ប់ដំណើរការទៅក្នុងពេលអនាគត។ អាជ្ញាធរជាតិអប្សរាក៏បានខិតខំក្នុងការធ្វើទំនាក់ទំនងមិនថាជាមួយស្ថាប័នជាតិ និងស្ថាប័នអន្តរជាតិនានាដើម្បីធ្វើយ៉ាងណាឱ្យមានការជ្រោមជ្រែងដោយបានផ្តល់ជាមធ្យោបាយផ្សេងៗក្នុងគោលដៅបណ្តុះបណ្តាល បង្ហាត់បង្រៀន ឬក៏ការផ្តល់ជាជំនួយផ្សេងៗក្នុងការបង្កើនធនធានមនុស្សដើម្បី អភិរក្ស និងអភិវឌ្ឍក្នុងតំបន់អង្គរ។

ការបង្កើតអាជ្ញាធរនេះក៏អាចបញ្ចៀសនូវវិវាទមួយចំនួននៃសមត្ថកិច្ចរបស់អាជ្ញាធរដែលពាក់ព័ន្ធ ហើយក៏ធ្វើឱ្យអាជ្ញាធរមួយនេះមានសមត្ថកិច្ចពេញលេញក្នុងការដោះស្រាយនូវបញ្ហា ដែលបានកើតឡើងនៅក្នុងតំបន់នេះឱ្យបានឆាប់រហ័ស និងទាន់ពេលវេលាក្នុងការស្វែងរកដំណោះស្រាយដល់បុគ្គលដែលបានពាក់ព័ន្ធ និងទប់ស្កាត់នូវរាល់បទល្មើសទាំងឡាយដែលបានកើត និងបម្រុងនឹងកើតនៅពេលអនាគត។

សរុបមកការបង្កើតអាជ្ញារធរនេះឡើង ដោយសារតែគេមើលឃើញពីសារៈសំខាន់មិនអាចខ្វះបានក្នុងការស្វែងរកនូវស្ថាប័នមួយធ្វើជាអាណាព្យាបាលដើម្បីគ្រប់គ្រង និងធ្វើសកម្មភាពឱ្យបានចំគោលដៅ ហើយយើងក៏សូមកោតសរសើរចំពោះរាល់កិច្ចខិតខំប្រឹងប្រែង និងសមិទ្ធផលដែលទទួលបានការសម្រេចកន្លងមក។

# អនុសាសន៍

ដូចដែរយើងបានដឹងហើយថា ការបង្កើតអាជ្ញាធរជាតិអប្សរា ពិតជាមានសារៈសំខាន់ណាស់ សម្រាប់ប្រជាជនគ្រប់រូប ព្រោះថាអាជ្ញាធរនេះបានបង្កើតឡើងក្នុងគោលបំណងដើម្បីការពារ ថែរក្សា អភិរក្ស និងអភិវឌ្ឍ ជាពិសេសគឺផ្តោតទៅលើសំណង់បុរាណដែលបុព្វបុរសយើងបានបន្សល់ទុកឱ្យកូនចៅជំនាន់ក្រោយរហូតមកដល់សព្វថ្ងៃនេះ។ មិនត្រឹមតែប៉ុណ្ណោះ អាជ្ញាធរមួយនេះគឺជាគ្រឹះស្ថានសាធារណៈប្រកបដោយបុគ្គលភាពគតិយុត្ត ស្វ័យភាពរដ្ឋបាល និងហិរញ្ញវត្ថុថែមទៀតផង ដូចនេះអាជ្ញាធរនេះមានតួនាទី និងភារកិច្ចជាច្រើនក្នុងកិច្ចការពារ ថែរក្សា និងអភិវឌ្ឍប្រាសាទ និងហេដ្ឋារចនាសម្ព័ន្ធនៃខេត្តសៀមរាបទាំងមូលផងដែរ។

ជាក់ស្តែង នៅក្នុងសង្គមយើងសព្វថ្ងៃនេះ ការយល់ដឹងអំពីតួនាទី និងភារកិច្ចនៃអាជ្ញាធរជាតិអប្សរានេះ មិនទាន់ទូលំទូលាយនៅឡើយទេចំពោះប្រជាជនខ្មែរយើងទាំងមូលដែលជាហេតុធ្វើឱ្យការលើកតម្កើងនៃតម្លៃបេតិកភណ្ឌទាំងអស់នោះពុំសូវមាននោះទេ មាននិស្សិតតិចតួចណាស់ដែលបានយល់ដឹងពីអាជ្ញាធរនេះ ក៏ដូចជាប្រជាជនខ្មែរទាំងមូលស្ទើរតែមិនទាន់ស្គាល់ពីគុណប្រយោជន៍នៃអាជ្ញាធរនេះផងទាំងដែលអាជ្ញាធរនេះមានតួនាទី និងភារកិច្ចយ៉ាងសំខាន់ក្នុងការការពារសម្បត្តិបេតិកភណ្ឌរបស់យើងទាំងអស់គ្នា។ យ៉ាងណាមិញ យើងគប្បីធ្វើការសិក្សាស្វែងយល់បន្ថែម និងនាំគ្នាជួយអភិរក្សបន្ថែម ជាពិសេសរាជរដ្ឋាភិបាលកម្ពុជាគួរយកចិត្តទុកដាក់ឱ្យកាន់តែខ្លាំងឡើងបន្ថែមទៀត ពាក់ព័ន្ធនិងការដឹកនាំ និងគ្រប់គ្រងអាជ្ញាធរនេះឱ្យកាន់តែរលូនទៅមុខជាបន្តបន្ទាប់។

ជាសារវន្តែ ក្នុងនាមយើងជាបញ្ញវន្តជំនាន់ក្រោយនេះរស់នៅក្នុងបរិបទសង្គមមួយដែលពោរពេញទៅដោយស

ន្តិភាពដែលផ្តល់តម្លៃទៅលើចំណេះដឹង និងការអភិវឌ្ឍន៍ យើងគប្បីសិក្សាស្វែងយល់ឱ្យកាន់តែច្បាស់ពីប្រវត្តិសាស្ត្រខ្មែររបស់យើង វប្បធម៌ អរិយធម៌ ដែលជាផ្ទាលមួយដែលបង្ហាញអំពីអត្តសញ្ញាណរបស់ជាតិ ដើម្បីជាយន្តការមួយដែលឈានទៅរកការអភិរក្ស ថែរក្សាសម្បត្តិវប្បធម៌ដែលយើងមានឱ្យបានគង់វង្សយូរអង្វែង សរបញ្ជាក់ឱ្យឃើញថា យើងបានឱ្យតម្លៃទៅលើសម្បត្តិវប្បធម៌របស់យើង និងធ្វើការចូលរួមចំណែកជាមួយនិងអាជ្ញាធរនេះក្នុងការជួយការពារ ថែរក្សាសម្បត្តិវប្បធម៌របស់យើង។ ជាពិសេសនោះ យើងគប្បីសិក្សាស្វែងយល់ឱ្យកាន់តែច្បាស់លាស់អំពីព្រឹត្តិការណ៍របស់សង្គម និងដំណើរការរបស់សង្គមយើងសព្វថ្ងៃ។ មិនត្រឹមតែប៉ុណ្ណោះ គួរសិក្សាអំពីអាជ្ញាធរទាំងឡាញដែលត្រូវបានរដ្ឋាភិបាលបង្កើតឡើង និងចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការតាមដានការងាររបស់អាជ្ញាធរទាំងនោះ។

ជាចុងក្រោយ ក្នុងនាមយើងទាំងអស់គ្នាជាយុវជន យុវតីខ្មែរជំនាន់ក្រោយ យើងគប្បីនាំគ្នាព្យាយាមខិតខំសិក្សារៀនសូត្រ និងរួបរួមគ្នាជាមួយអាជ្ញាធរជាតិអប្សរាក្នុងកិច្ចការការពារ អភិរក្ស និងអភិវឌ្ឍតំបន់ឧទ្យានអង្គរ និងប្រាង្គប្រាសាទបុរាណរបស់ខ្មែរយើងដែលបុព្វបុរសបានបន្សល់ទុកមកឱ្យបានគង់វង្សយូរអង្វែង ជាពិសេសការពារឱ្យបានពីការកាប់បំផ្លាញព្រៃឈើ ក៏ដូចជាការឈ្លានពានពីសំណាក់បុគ្គល ដែលបានលួចកាប់គាស់លួចយករូបចម្លាក់ក្បូរក្បាច់នានាពីប្រាសាទរបស់យើង ហើយយើងខ្ញុំក៏សូមធ្វើការសំណូមពរទៅដល់ប្រមុខរាជរដ្ឋាភិបាល ក៏ដូចជាប្រធានអាជ្ញាធរជាតិអប្សរាមេត្តាបន្តពង្រឹងនូវសកម្មភាពរបស់ខ្លួន ដើម្បីលើកស្ទួយកេរ្តិ៍ដំណែលវប្បធម៌ជាតិរបស់យើងឱ្យកាន់តែមានការទទួលស្គាល់នៅលើឆាកអន្តរជាតិ និងជាពិសេសនោះបញ្ជាក់ឱ្យឃើញថា យើងក៏មានអាជ្ញាធរមួយដែលពោរពេញទៅដោយសមត្ថភាពក្នុងការអភិវឌ្ឍន៍ និងកែប្រែមុខមាត់ថ្មីក្នុងការដឹកនាំទៅរកតែភាពរីកចម្រើនយ៉ាងឧត្តុង្គឧត្តម។

# ឯកសារយោង

❖ **ព្រះរាជក្រម ព្រះរាជក្រឹត្យ**

➢ ព្រះរាជក្រឹត្យលេខ ០០១នស ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៤ ស្តីពីការកំណត់ និងការចាត់ចែងគ្រប់គ្រងតំបន់សៀមរាប អង្គរ

➢ ព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពារ និងរៀបចំតំបន់អង្គរហៅថាអាជ្ញាធរ "អប្សរា"

➢ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ១៩៩៦ ប្រកាសឲ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌ

➢ ព្រះរាជក្រឹត្យលេខ នសរកត០១៩៩/១៨ ស្តីពីការកែសម្រួលបទប្បញ្ញត្តិមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត ០២៩១២ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថាអាជ្ញាធរ "អប្សរា" ឲ្យស្របជាមួយបទប្បញ្ញត្តិនៃ ព្រះរាជក្រឹត្យលេខនសរកត១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈ គតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល

❖ **អនុក្រឹត្យ**

➢ អនុក្រឹត្យលេខ ៦០អនក្រ បក ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការបង្កើតស្នងការដ្ឋាន ពិសេសការពារបេតិកភណ្ឌ

➢ អនុក្រឹត្យលេខ ៩៨ អនក្រ.បក ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ស្តីពីការអនុវត្តកិច្ចការពារ បេតិកភណ្ឌ

➢ អនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា

❖ **ប្រកាស**

➢ ប្រកាសលេខ ៨៩ ប្រក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៤ ស្តីពីការកំណត់ និងបែងចែកភារៈកិច្ចជូន នាយកដ្ឋានរមណីដ្ឋាន និងបុរាណវិទ្យាទី១ និងនាយកដ្ឋានរមណីយដ្ឋាន និងបុរាណវិទ្យាទី២ នៃអាជ្ញាធរអប្សរា

- **សេចក្តីសម្រេច**

  - សេចក្តីសម្រេចលេខ ៧០ សសរ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្តីពីការកំណត់បទដ្ឋាន និងការប្រើប្រាស់ដីធ្លីនៅតំបន់១ និងតំបន់២ នៅក្នុងតំបន់រមណីយដ្ឋានសៀមរាប អង្គរ

- **សៀវភៅផ្សេងៗ**

  - និតិនគរូបនីយវិទ្យា របស់លោកបណ្ឌិត **អ៊ុន សកក្កដា** នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ឆ្នាំ២០១៥
  - សៀវភៅ សិក្ខាសាលា ស្តីពីកិច្ចការពាររមណីយដ្ឋានអង្គរ និង បញ្ហាដីធ្លី ឆ្នាំ២០០៥
  - សៀវភៅទាក់ទងនឹង នីតិក្រមពាក់ព័ន្ធនឹងសមត្ថកិច្ចនៃអាជ្ញាធរអប្សរា ឆ្នាំ២០០៦

- **ឯកសារដែលបានស្វែងរកបន្ថែមពីប្រភពអ៊ីនធើណេត**

  - www.apsaraauthority.gov.kh
  - www.facebook.com/apsaraautorite/photos/pcb
  - www.unesdocv.unesco.org

# បញ្ជីឧបសម្ព័ន្ធ

- និមិត្តសញ្ញាអាជ្ញាធរជាតិអប្សរា
- រចនាសម្ព័ន្ធអាជ្ញាធរអប្សរា
- **ឧបសម្ព័ន្ធ១៖** ព្រះរាជក្រឹត្យ ស្តីពីការកំណត់ និងការចាត់ចែងគ្រប់គ្រងតំបន់សៀមរាប អង្គរ
- **ឧបសម្ព័ន្ធ២៖** ព្រះរាជក្រឹត្យបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថា អាជ្ញាធរ "អប្សរា"
- **ឧបសម្ព័ន្ធ៣៖** អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា
- **ឧបសម្ព័ន្ធ៤៖** សេចក្តីសម្រេច ស្តីពីការកំណត់បទដ្ឋាននៃការប្រើប្រាស់ដីធ្លីនៅតំបន់១ និងតំបន់២ ក្នុងតំបន់រមណីយដ្ឋានសៀមរាប អង្គរ
- **ឧបសម្ព័ន្ធ៥៖** ប្រកាស ស្តីពីការកំណត់ និងបែងចែកភារកិច្ចជូន នាយកដ្ឋានរមណីយដ្ឋាន និងបុរាណវិទ្យាទី១ និងនាយកដ្ឋានរមណីយដ្ឋាន និងបុរាណវិទ្យាទី២ នៃអាជ្ញាធរអប្សរា
- រូបភាពខ្លះៗនៃសមិទ្ធផលរបស់អាជ្ញាធរជាតិអប្សរា

# និមិត្តសញ្ញានៃអាជ្ញាធរជាតិអប្សរា

អាជ្ញាធរជាតិអប្សរា

A P S A R A

ព្រះរាជាណាចក្រកម្ពុជា
ROYAUME DU CAMDOGE

ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION ROI

អាជ្ញាធរអប្សរា
APSARA
លេខ៖ ៤១៣ /សរ.សជណា
១៦

# សេចក្តីជូនដំណឹង
## ស្តីពី
## ការកំណត់ឱ្យភ្ញៀវទេសចរ ស្លៀកពាក់សមរម្យក្នុងអំឡុងពេលចូលទស្សនារមណីយដ្ឋានអង្គរ

អគ្គនាយកដ្ឋាន អាជ្ញាធរជាតិអប្សរា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់គ្រប់ក្រសួង មន្ទីរ ស្ថាប័នជាតិ-អន្តរជាតិ សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ សមាគមសណ្ឋាគារ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ មគ្គុទ្ទេសក៍ទេសចរណ៍ និងក្រុមហ៊ុនទេសចរណ៍ មេត្តាជ្រាបថា ដើម្បីលើកតម្លៃរមណីយដ្ឋានអង្គរឱ្យសក្តិសមជាទីសក្ការៈនៃដួងព្រលឹងវប្បធម៌ជាតិ និងជាសម្បត្តិបេតិកភណ្ឌពិភពលោកដ៏ល្បីល្បាញ ដែលទាក់ទាញភ្ញៀវទេសចរមកទស្សនាកាន់តែច្រើន និងដើម្បីគ្រប់គ្រងតំបន់អង្គរប្រកបដោយចីរភាព អាជ្ញាធរជាតិអប្សរាកន្លងមកបានផ្សព្វផ្សាយដាក់ឱ្យអនុវត្តជាផ្លូវការ **ក្រមប្រតិបត្តិអង្គរ** កាលពីថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៥ និងបានចេញសេចក្តីជូនដំណឹងដល់ស្ថាប័នពាក់ព័ន្ធឱ្យជួយផ្សព្វផ្សាយបន្តព្រមទាំងបានធ្វើការផ្សព្វផ្សាយតាមរយៈបណ្តាញព័ត៌មានក្នុង និងក្រៅប្រទេសជាច្រើន ហើយទទួលបានសហការ និងគាំទ្រពីសំណាក់សាធារណៈជនទូទៅ វិស័យឯកជន និងថ្នាក់ដឹកនាំជាន់ខ្ពស់រាជរដ្ឋាភិបាល កម្ពុជា ជាក់ស្តែង **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានបង្ហាញការគាំទ្រ **ក្រមប្រតិបត្តិអង្គរ** តាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម Facebook ផងដែរ។ អាជ្ញាធរជាតិអប្សរានឹងជម្រុញការអនុវត្ត **ក្រមប្រតិបត្តិអង្គរ** នេះឱ្យកាន់តែមានប្រសិទ្ធភាព ក្នុងគោលបំណងបង្ការ និង ទប់ស្កាត់ការប្រព្រឹត្តមិនសមរម្យរបស់ភ្ញៀវទេសចរខណៈពេលចូលទស្សនាក្នុងរមណីយដ្ឋានអង្គរ ដែលជាហេតុបង្កឱ្យមានផលប៉ះពាល់ដល់ប្រាសាទ បរិស្ថាន និងសហគមម្ចាស់ស្រុក ជាពិសេសទាក់ទងនឹងការស្លៀកពាក់របស់ភ្ញៀវឱ្យបានសមរម្យពេលចូលទស្សនារមណីយដ្ឋានអង្គរ។ អាជ្ញាធរជាតិអប្សរានឹងចាត់វិធានការចាប់ពីថ្ងៃទី០៤ ខែសីហា ឆ្នាំ ២០១៦ តទៅ ដោយតម្រូវឱ្យភ្ញៀវទេសចរគ្រប់រូបត្រូវតែស្លៀកពាក់ឱ្យបានសមរម្យខណៈពេលមកទិញសំបុត្រ ដើម្បីចូលទស្សនារមណីយដ្ឋានអង្គរ។

អាជ្ញាធរជាតិអប្សរាសង្ឃឹមនឹងជឿជាក់ថាគ្រប់ក្រសួង មន្ទីរ ស្ថាប័នជាតិ-អន្តរជាតិ សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ សមាគមសណ្ឋាគារ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ មគ្គុទ្ទេសក៍ទេសចរណ៍ និងក្រុមហ៊ុនទេសចរណ៍ និងផ្សព្វផ្សាយឱ្យមានប្រសិទ្ធភាពខ្ពស់តាមស្មារតីនៃសេចក្តីជូនដំណឹងនេះ។

សៀមរាប ថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០១៦

**អគ្គនាយក**

**ស៊ុំ ម៉ាប់**

**ចម្លងជូន៖**

- ក្រសួង-មន្ទីរទេសចរណ៍
- សាលាខេត្ត-ក្រុងសៀមរាប
- គ្រប់នាយកដ្ឋានចំនុះអាជ្ញាធរជាតិអប្សរា
- អង្គភាពនគរបាលការពារបេតិកភណ្ឌខេត្តសៀមរាប
- អង្គភាពនគបាលទេសចរណ៍ ប្រចាំខេត្តសៀមរាប
- សមាគម ទីភ្នាក់ងារទេសចរណ៍
- សមាគម សណ្ឋាគារកម្ពុជា
- សមាគម មគ្គុទ្ទេសក៍ទេសចរណ៍
- សមាគម ដឹកជញ្ជូនភ្ញៀវទេសចរ
- គ្រឹះស្ថានអង្គរ
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA

ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

អាជ្ញាធរជាតិអប្សរា
APSARA
N°. ៣៧២/រប.អជអ
១៦

# សេចក្តីជូនដំណឹង

## ស្តីពីការតម្រូវឱ្យរុះរើសំណង់គ្រប់ប្រភេទនៅតាមបណ្តោយខ្លងទំនប់ស្រះស្រង់ខាងត្បូង ស្ថិតក្នុងភូមិស្រះស្រង់ខាងត្បូង សង្កាត់នគរធំ ក្រុង-ខេត្តសៀមរាប (តំបន់១)

ក្នុងគោលដៅថែរក្សា និងការពារស្លាកស្នាមបុរាណវិទ្យាដូចជា៖ រចនាសម្ព័ន្ធទំនប់ជុំវិញស្រះស្រង់ ប្រឡាយ ត្រពាំងបុរាណ និងរចនាសម្ព័ន្ធដទៃទៀតដែលមានទំនាក់ទំនងនឹងប្រាសាទបន្ទាយក្តី និងដើម្បីរក្សាបរិស្ថានបានល្អ គ្មានក្លិនស្អុយ និងសំរាមជាដើម អគ្គនាយកដ្ឋានអាជ្ញាធរជាតិអប្សរា សូមជម្រាបជូនដំណឹងដល់បងប្អូនដែលបាននឹងកំពុងរស់នៅ និងប្រកបអាជីវកម្មដោយគ្មានច្បាប់អនុញ្ញាត តាមបណ្តោយខ្លងទំនប់ស្រះស្រង់ទាំងអស់ ត្រូវរុះរើនូវសំណង់គ្រប់ប្រភេទដែលបានសង់រំលោភបំពានលើទំនប់ស្រះស្រង់ គិតចាប់ពីថ្ងៃទទួលបានសេចក្តីជូនដំណឹងនេះ រហូតដល់ **ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦ ជាកំហិត**។ ក្នុងករណីបងប្អូន ពុំព្រមអនុវត្តតាមសេចក្តីជូនដំណឹងនេះ អគ្គនាយកដ្ឋានអាជ្ញាធរជាតិអប្សរាសហការជាមួយស្ថាប័នពាក់ព័ន្ធ នឹងចាត់វិធានការរដ្ឋបាលទៅតាមស្ថានភាពជាក់ស្តែង និងពុំទទួលខុសត្រូវចំពោះការខាតបង់ផ្សេងៗឡើយ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមបងប្អូនអាជីវករទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ៕

សៀមរាប ថ្ងៃទី២៧ ខែ មិថុនា ឆ្នាំ២០១៦
**អគ្គនាយក**

**ស៊ុំ ម៉ាប់**

ចម្លងជូន៖
-ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរអប្សរា «ដើម្បីគោរពជូនជ្រាបជាព័ត៌មាន»
-សាលាខេត្តសៀមរាប
-សាលាដំបូងខេត្តសៀមរាប
-ស្នងការដ្ឋាននគរបាលខេត្តសៀមរាប
-ក្រុមមេធាវីអាជ្ញាធរជាតិអប្សរា
-ក្រុមការងារMP
«ដើម្បីជូនជ្រាបជាព័ត៌មាន និងសូមកិច្ចសហការ»
-គ្រប់នាយកដ្ឋានចំណុះអាជ្ញាធរអប្សរា
-អង្គភាពនគរបាលការពារបេតិកភណ្ឌប្រចាំខេត្តសៀមរាប
-អង្គភាពនគរបាលទេសចរណ៍ប្រចាំខេត្តសៀមរាប
-សាលាក្រុងសៀមរាប
-អធិការដ្ឋាននគរបាលក្រុងសៀមរាប
-សាលាសង្កាត់នគរធំ
-ប៉ុស្តិ៍នគរបាលរដ្ឋបាលសង្កាត់នគរធំ
-ប្រធាន និងអនុប្រធានភូមិស្រះស្រង់ខាងត្បូង
«ដើម្បីមុខការ និងសហការ»
-ឯកសារ-កាលប្បវត្តិ



Available languages 한국어 English 中文 Français 日本語
អាជ្ញាធរអប្សរា APSARA
ក្រមប្រតិបត្តិអង្គរ
អង្គរសូមស្វាគមន៍!
ឧទ្យានអង្គរជាអតីតរាជធានីចក្រភពខ្មែរចាប់ពីសតវត្សទី៩ ដល់សតវត្សទី១៥ និងជារាជធានីមួយធំជាងគេនៅលើពិភពលោកនៅសតវត្សទី១២។ បច្ចុប្បន្ននេះ ឧទ្យានអង្គរនៅតែជាបូជនីយដ្ឋានសម្រាប់ពុទ្ធសាសនិកនិងប្រជាពលរដ្ឋ ដែលតែងមកគោរពបូជាសំពះបន់ស្រន់ជារៀងរាល់ថ្ងៃ ហើយជាទីលំនៅឋានរបស់ប្រជាពលរដ្ឋប្រមាណ ១៣០ ០០០នាក់ផងដែរ។
អាជ្ញាធរជាតិអប្សរាគឺជាស្ថាប័នទទួលខុសត្រូវក្នុងការអភិរក្សនិងអភិវឌ្ឍឧទ្យានអង្គរ ចាប់តាំងពីឆ្នាំ១៩៩៥មក។ គោលដៅមួយក្នុងចំណោមគោលដៅទាំងឡាយរបស់យើងគឺធ្វើយ៉ាងណាឱ្យធានាបាននូវសុវត្ថិភាពរបស់ភ្ញៀវ បទពិសោធន៍ទស្សនា និងការគោរពដល់សហគមន៍របស់យើង។ ក្រមប្រតិបត្តិអង្គរនេះត្រូវបានតាក់តែងឡើងដោយមានការសហការជាមួយអ្នកស្រុកអង្គរ ភ្ញៀវទេសចរ មគ្គុទ្ទេសក៍ទេសចរណ៍ និងក្រុមការងារជួសជុលប្រាសាទ។
ដើម្បីរួមចំណែកជួយអភិរក្សឧទ្យានអង្គរសម្រាប់មនុស្សជំនាន់ក្រោយ និងធ្វើឱ្យបទពិសោធន៍ទស្សនារបស់លោកអ្នកកាន់តែប្រសើរ សូមមេត្តាគោរពតាមក្រមប្រតិបត្តិអង្គរដូចខាងក្រោម៖
ទីសក្ការៈបូជា
ការស្លៀកពាក់ ឬការប្រព្រឹត្តផ្ទុយពីវប្បធម៌ខ្មែរ ការនិយាយខ្លាំងៗ សកម្មភាពឡូឡា គឺជាសកម្មភាពមិនសមរម្យចំពោះតំបន់អង្គរ ហើយអាចរំខានដល់ការទស្សនារបស់ភ្ញៀវទេសចរដទៃទៀត។ សូមមេត្តាទស្សនាដោយភាពស្ងប់ស្ងាត់ និងគោរពភ្ញៀវដទៃ។
ទីតាំងហាមឃាត់
ដើម្បីសុវត្ថិភាពផ្ទាល់ខ្លួនរបស់លោកអ្នក និងដើម្បីអភិរក្សតំបន់អង្គរ សូមមេត្តាគោរពស្លាកសញ្ញានៅតាមប្រាសាទ។ សូមប្រយ័ត្ននៅពេលទស្សនា និងហាមឡើងលើគំនរថ្ម។
ការពិសាបារី និង ការចោលសំរាម
ក្នុងនាមជាសមាជិកអង្គការសុខភាពពិភពលោក ឧទ្យានអង្គរគឺជារមណីយដ្ឋានគ្មានផ្សែងបារីតាំងពីឆ្នាំ២០១២។ ការពិសាបារីអាចរំខានដល់អ្នកដទៃនិងអាចបណ្ដាលឱ្យមានអគ្គិភ័យ។ ដើម្បីចូលរួមការពារបរិស្ថានសូមមេត្តាកុំជក់បារី និងចោលសំរាម។
សម្លៀកបំពាក់
អាវកលាភ្លៀក ចំហាដើមទ្រូង ខោនិងសំពត់ខ្លីលើជង្គង់សុទ្ធតែជាសម្លៀកបំពាក់ ដែលមិនសមរម្យនៅក្នុងវប្បធម៌ខ្មែរ និងត្រូវហាមឃាត់ដាច់ខាតនៅតាមទីសក្ការៈ។ ត្រូវស្លៀកពាក់សមរម្យនៅគ្រប់ទីកន្លែងក្នុងឧទ្យានអង្គរ។
ការឱ្យស្ករគ្រាប់ឬវត្ថុកា ដល់កុមារ
ការទិញរបស់របរ ការឱ្យស្ករគ្រាប់ឬវត្ថុកាដល់កុមារអាចជំរុញឱ្យកុមារមិនទៅសាលារៀន ហើយជំរុញឱ្យពួកគេមានទំលាប់សុំទាន។ បើចង់ជួយកុមារ សូមផ្ដល់អំណោយដល់អង្គការមនុស្សធម៌ដែលគេទទួលស្គាល់ថាជាអង្គការល្អ។
ប្រាង្គប្រាសាទ
ការប៉ះរូបចម្លាក់ ការអង្គុយលើកន្លែងដែលមានសភាពទ្រុឌទ្រោម ការផ្អែកលើសំណង់ប្រាសាទ ការផ្លាស់ប្ដូរទីតាំងឬយកថ្មបុរាណ និងការគូសវាសលើថ្មជាដើមត្រូវបានហាមឃាត់ដាច់ខាត។ កាបូបស្ពាយក្រោយខ្នង ឆត្រមានដងមុតស្រួច ជើងទ្រម៉ាស៊ីនថត និងស្បែកជើងកែងខ្ពស់ មិនគួរយកឬពាក់ចូលក្នុងប្រាសាទឡើយ។
ព្រះសង្ឃ
នៅប្រទេសកម្ពុជា ព្រះសង្ឃជាបុគ្គលសក្ការៈ។ ប្រសិនបើលោកអ្នកចង់ថតរូប សូមមេត្តាសុំការអនុញ្ញាតពីព្រះសង្ឃជាមុនសិន។ ស្ត្រីមិនត្រូវប៉ះ ឈរ ឬអង្គុយកៀកព្រះសង្ឃឡើយ។
រាល់ការលួច ការធ្វើឱ្យបាក់បែកឬខូចខាតថ្មប្រាសាទ ក៏ដូចជាសកម្មភាពអាសអាភាសនិងអាក្រាតកាយនៅទីសាធារណៈជាអំពើល្មើសច្បាប់។
សហការដោយ :
UNWTO
សូមផ្ដល់យោបល់របស់លោកអ្នក តាមរយៈគេហទំព័រ ឬ QR code នេះ។ សូមអរគុណ!
www.apsaraauthority.gov.kh/survey
www.apsaraauthority.gov.kh
 គាំទ្រដោយ :
SOKHA
CAMBODIA AIRPORTS
APSARA © 2015